# ការអនុវត្តជាក់ស្ដែងនៃដំណើរការពិនិត្យ និង អនុម័តច្បាប់នៅសភាកម្ពុជា





# ការអនុវត្តជាក់ស្តែង

# នៃដំណើរការពិនិត្យ និងអនុម័តច្បាប់

# នៅសភាកម្ពុជា

# អារម្ភកថា

សៀវភៅស្តីពី « **ការអនុវត្តជាក់ស្តែងនៃដំណើរការពិនិត្យ និងអនុម័តច្បាប់នៅសភាកម្ពុជា** » ដែល សម្តេច ព្រះអង្គម្ចាស់ លោកជំទាវ ឯកឧត្តម លោក លោកស្រី និងនិស្សិត កំពុងអាននេះ គឺជាស្នាដៃលើកដំបូងរបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងរដ្ឋសភា ដែលបានរួមគ្នាស្រាវជ្រាវ និងចងក្រងទុកជាស្នាដៃខាងកិច្ចការសភា។

ដំណើរការធ្វើច្បាប់នៅកម្ពុជា ជាប្រធានបទទូទៅមួយដែលត្រូវបានអ្នកនិពន្ធជាច្រើន ធ្លាប់បានតាក់តែង និងចងក្រងជាសៀវភៅសម្រាប់បង្រៀននិស្សិតនៅមហាវិទ្យាល័យ និងអ្នកសិក្សាស្រាវជ្រាវ ប៉ុន្តែ ឯកសារដែលលោកអ្នកកំពុងតែអាននេះគឺជាស្នាដៃស្រាវជ្រាវ និងចងក្រងដោយមន្ត្រីសភាសុទ្ធសាធ ដោយពួកគាត់បានឆ្លងកាត់ការអនុវត្តជាក់ស្តែងប្រចាំថ្ងៃ និងមានបទពិសោធន៍យូរឆ្នាំលើកិច្ចការសភា។ សៀវភៅនេះ បរិយាយអំពីតួនាទីធ្វើច្បាប់របស់សមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា ដោយអនុលោមតាមគោលការណ៍ និងនីតិវិធីជាក់ស្តែងនានា ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងឯកសារពាក់ព័ន្ធដទៃទៀតដែលមិនបានសរសេរហៅថា ***នីតិវិធីមិនសរសេរ*** ហើយដែលត្រូវបានអនុវត្តដោយសមាជិកសភា និងមន្ត្រីសភា។

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានរដ្ឋសភា សូមកោតសរសើរ និងថ្លែងអំណរគុណជាអនេកចំពោះសិក្ខាកាមជាមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងរដ្ឋសភាដែលបានឆ្លៀត ពេលសរសេរ ចងក្រងឯកសារបណ្តើ និងបំពេញការងារបណ្តើ ក្នុងអំឡុងពេលរៀនវគ្គសិក្សា **«បច្ចេកទេសនៃការតាក់តែងច្បាប់»** ប្រកបដោយស្មារតីយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់រហូតដល់សម្រេចបានស្នាដៃដ៏មានសារៈសំខាន់នេះ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវិទ្យាស្ថានសភាកម្ពុជា (PIC) ដែលជាដៃគូរសហប្រត្តិបត្តិ ការមិនអាចខ្វះបានរបស់សភាកម្ពុជា ដោយបានរួមចំណែកជួយអភិវឌ្ឍន៍ធនធានមនុស្សដល់អគ្គលេខាធិការដ្ឋាននៃសភាកម្ពុជា និងមន្ត្រីសភាក្នុងតំបន់ តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់លើមុខវិជ្ជាសំខាន់ៗ ដែលជាតម្រូវការចាំបាច់ក្នុងការផ្តល់សេវាគាំទ្រទាំងផ្នែកបច្ចេកទេស និងនីតិវិធីដល់សមាជិកព្រឹទ្ធសភា និងសមាជិករដ្ឋសភា។

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានរដ្ឋសភាសង្ឃឹមថា សៀវភៅនេះប្រាដកជាមានសារៈសំខាន់ និងមានអត្ថប្រយោជន៍ដល់សមាជិកសភា និងមន្ត្រីសភាសម្រាប់ជាជំនួយស្មារតីក្នុងការអនុវត្តមុខងារនីតិកម្មរបស់ខ្លួនដោយឡែកៗពីគ្នា ដោយហេតុថា នីតិវិធីនៃការបំពេញការងារសភាដែលមានបរិយាយក្នុងសៀវភៅនេះ ក៏អាចជាទុនរួមចំណែកដល់សមាជិកសភា និងមន្ត្រីសភាបានមួយកម្រិតថែមទៀត ក្នុងការបំពេញមុខងារ តួនាទី និងភារកិច្ចរបស់ខ្លួនស្របតាមរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុង និងច្បាប់ជាធរមាន ក៏ដូចជាបទពិសោធន៍ជាក់ស្តែងដែលមិនមានចែងនៅក្នុងវិធានសភា។ ជាងនេះទៅទៀត សៀវភៅនេះ ក៏អាចផ្តល់ជាប្រយោជន៍ដល់អ្នកសិក្សាស្រាវជ្រាវទាំងឡាយសម្រាប់បង្កើននូវចំណេះដឹង ក៏ដូចជាការស្វែងយល់លើការងារជាក់ស្តែងអំពីដំណើរការពិនិត្យ និងអនុម័តច្បាប់ក្នុងក្របខណ្ឌសភាកម្ពុជាដែលអនុវត្តដោយសមាជិកសភា និងមន្ត្រីសភាកម្ពុជា។

ថ្ងៃ សុក្រ ១២រោច ខែចេត្រ ឆ្នាំឆ្លូវ ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០២១

**អគ្គលេខាធិការព្រឹទ្ធសភា**

**អ៊ុំ សារិទ្ធ**

**អគ្គលេខាធិការរដ្ឋសភា**

**ឡេង ប៉េងឡុង**

# មាតិកា

**អារម្ភកថា**
**សេចក្តីផ្តើម** ........ 1
ក. ហេតុអ្វីបានជាមានសៀវភៅនេះ ? ........ 1
ខ. សារៈសំខាន់នៃឯកសារនេះ ........ 1
គ. វិសាលភាព និងវិធីសាស្ត្រនៃការស្រាវជ្រាវ ........ 1
**ប្រវត្តិនៃសភាកម្ពុជា** ........ 4
I. **មុខងារចម្បងរបស់សភាកម្ពុជា** ........ 6
១. មុខងារនីតិកម្ម ........ 6
២. មុខងារតំណាង ........ 6
៣. មុខងារតាមដានការអនុវត្តច្បាប់ ........ 7
II. **គោលការណ៍សំខាន់ៗក្នុងដំណើរការនីតិកម្ម** ........ 12
១. សិទ្ធិនៃការផ្តួចផ្តើមធ្វើច្បាប់ និងគោលការណ៍អនុម័តច្បាប់ ........ 12
១.១. សិទ្ធិនៃការផ្តួចផ្តើមធ្វើច្បាប់ ........ 12
១.២. គោលការណ៍នៃការអនុម័ត ........ 16
១.៣. ខ្លឹមសារ និងទម្រង់នៃសេចក្តីស្នើច្បាប់ផ្តួចផ្តើមដោយសមាជិករដ្ឋសភា ឬសមាជិកព្រឹទ្ធសភា. 19
២. បទប្បញ្ញត្តិហាមឃាត់ ........ 33
៣. គោលការណ៍ និងទ្រឹស្តីនៃការធ្វើច្បាប់ឱ្យបានល្អ ........ 34
៣. ១. សមាសធាតុនៃការធ្វើច្បាប់ឱ្យបានល្អ ........ 34
៣.២. ការវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA) ........ 36
III. **តួអង្គសំខាន់ៗក្នុងដំណើរការនីតិកម្មកម្ពុជា** ........ 42
១. រាជរដ្ឋាភិបាល ........ 42
២. រដ្ឋសភា និងព្រឹទ្ធសភា ........ 42

២.១. គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងព្រឹទ្ធសភា ...... 43

២.២. គណៈកម្មការនានារបស់រដ្ឋសភា និងព្រឹទ្ធសភា ...... 43

២.៣. កិច្ចប្រជុំពេញអង្គរដ្ឋសភា និងព្រឹទ្ធសភា ...... 44

៣. ក្រុមប្រឹក្សាធម្មនុញ្ញ ...... 44

៤. ព្រះមហាក្សត្រ ...... 45

IV. **ដំណាក់កាលនៃការពិនិត្យ និងអនុម័តសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់** ...... 46

១. នីតិវិធីនៃការពិនិត្យ និងអនុម័តនៅរដ្ឋសភា ...... 46

២. នីតិវិធីនៃការពិនិត្យ និងឱ្យយោបល់នៅព្រឹទ្ធសភា ...... 60

៣. សេវាគាំទ្ររបស់រដ្ឋសភា និងព្រឹទ្ធសភា ...... 76

៣.១. អគ្គលេខាធិការដ្ឋានរដ្ឋសភា ...... 76

៣.២. អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ...... 77

V. **ដំណើរការបង្វិលទៅបង្វិលមក** ...... 81

VI. **ការចូលជាធរមាននៃច្បាប់** ...... 82

**សេចក្ដីសន្និដ្ឋាន** ...... 84

**ឯកសារពិគ្រោះ** ...... 87

**សេចក្ដីថ្លែងអំណរគុណ** ...... 89

# សេចក្តីផ្តើម

## ក. ហេតុអ្វីបានជាមានសៀវភៅនេះ?

ផ្តើមចេញពីវគ្គបណ្តុះបណ្តាលស្តីពី «**បច្ចេកទេសនៃការតាក់តែងច្បាប់**» រៀបចំឡើងដោយវិទ្យាស្ថានសភាកម្ពុជា (PIC) ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ ២០១៨ សម្រាប់មន្ត្រីអគ្គលេខាធិការដ្ឋានសភាទាំងពីរ សិក្ខាកាមក៏បានផ្តួចផ្តើមគំនិតរៀបចំ និងចងក្រងឯកសារមួយដោយឱ្យឈ្មោះថា «**ការអនុវត្តជាក់ស្តែងនៃដំណើរការពិនិត្យ និងអនុម័តច្បាប់នៅសភាកម្ពុជា**» ក្នុងគោលបំណងរំលេចនូវទ្រឹស្តី និងគោលការណ៍មួយចំនួនលើការអនុវត្តមុខងារនីតិកម្មរបស់សភាកម្ពុជា ព្រមទាំងបង្ហាញនូវបទពិសោធន៍នៃការអនុវត្តជាក់ស្តែងលើកិច្ចការសភារបស់សិក្ខាកាមនៅតាមបណ្តាការដ្ឋានការងាររៀងខ្លួន។

## ខ. សារៈសំខាន់នៃឯកសារនេះ

ឯកសារនេះ បានប្រមូលផ្តុំនូវគោលការណ៍សំខាន់ៗក្នុងដំណើរការនីតិកម្មតែក្នុងក្របខណ្ឌរដ្ឋសភានិងព្រឹទ្ធសភាប៉ុណ្ណោះ ដោយធ្វើការសង្កត់ធ្ងន់អំពីតួនាទីរបស់សមាជិកសភាលើមុខងារនីតិកម្ម ដោយរំលេចអំពីសិទ្ធិនៃការផ្តួចផ្តើមធ្វើច្បាប់ គោលការណ៍នៃការអនុម័តច្បាប់ បទប្បញ្ញត្តិហាមឃាត់ ជាពិសេសគោលការណ៍និងទ្រឹស្តីនៃការធ្វើច្បាប់ឱ្យបានល្អដែលត្រូវបានអនុវត្តដោយប្រទេសជាច្រើន។ ជាមួយគ្នានេះ បែបបទការងារ នីតិវិធីរដ្ឋបាល និងបច្ចេកទេសផ្សេងៗ ដែលអនុវត្តដោយមន្ត្រីសភាទាំងពីរ ក៏ត្រូវបានលើកយកមកបង្ហាញផងដែរ។

## គ. វិសាលភាព និងវិធីសាស្ត្រនៃការស្រាវជ្រាវ

អត្ថបទសិក្សានេះ មានវិសាលភាពតែទៅលើការអនុវត្តជាក់ស្តែងនៃមុខងារនីតិកម្មរបស់សភាកម្ពុជាតែប៉ុណ្ណោះ។

ជាទូទៅ សភាអនុវត្តមុខងាររបស់ខ្លួនដោយផ្អែកទៅលើគោលការណ៍ច្បាប់ និងវិធាននានាដែលបានចែង។ នៅក្នុងដំណាក់កាលទី១នៃការសិក្សាលើប្រធានបទនេះ គឺចាប់ផ្តើមសិក្សាទៅលើសញ្ញាណទូទៅ ទ្រឹស្តីជាមូលដ្ឋាននៃបទប្បញ្ញត្តិ និងគោលការណ៍សំខាន់ៗដែលចែងក្នុងរដ្ឋធម្មនុញ្ញ

បទបញ្ញាផ្ទៃក្នុង និងវិធាននានានៃរដ្ឋសភា និងព្រឹទ្ធសភា។ បន្ទាប់ពីទទួលបានព័ត៌មាន និងទិន្នន័យរួចហើយ ក្រុមការងារបានរៀបចំជាមាតិកាដោយឆ្លុះបញ្ចាំងអំពីខ្លឹមសារដែលឆ្លើយតបទៅនឹងប្រធានបទនេះ។ នៅក្នុងផ្នែកទី១ មាន ៣ ចំណុចសំខាន់ៗ (I., II., និង III.) ផ្តោតលើមុខងារចម្បងរបស់សភាទាំងពីរ គោលការណ៍សំខាន់ៗក្នុងដំណើរការនីតិកម្ម និងតួអង្គពាក់ព័ន្ធដែលជាមូលដ្ឋានចំណេះដឹងដើម្បីឈានទៅឈ្វេងយល់កាន់តែស៊ីជម្រៅលើខ្លឹមសារទាំងស្រុងនៃសៀវភៅនេះ។ ក្នុងផ្នែកទី២ មាន ៣ ចំណុចសំខាន់ៗ (IV., V., VI.) ផ្តោតទៅលើរបៀបរបបការងារ និងនីតិវិធីនៃដំណាក់កាលពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នៅក្នុងក្របខណ្ឌរដ្ឋសភា និងព្រឹទ្ធសភា, ដំណើរការបង្វិលទៅបង្វិលមករវាងសភាទាំងពីរ និងការចូលជាធរមាននៃច្បាប់ ។

ដំណាក់កាលទី២ ក្រុមការងារបានប្រមូលទិន្នន័យ និងព័ត៌មានដែលពាក់ព័ន្ធទៅនឹងការអនុវត្តការងារជាក់ស្តែង និងបានចងក្រងជាអត្ថបទព្រាងដើម ។ បន្ទាប់មក យកអត្ថបទព្រាងលើកទី១ មកធ្វើបទបង្ហាញ និងសុំយោបល់ពីមន្ត្រីជំនាញដែលជាថ្នាក់ដឹកនាំជាន់ខ្ពស់នៃសភាទាំងពីរ និងមន្ត្រីជាន់ខ្ពស់នៃក្រុមប្រឹក្សាធម្មនុញ្ញ ហើយបានកែសម្រួល និងដាក់បន្ថែមធាតុចូលដែលប្រមូលបានពីដំណាក់កាលទី២។

ដំណាក់កាលទី៣ ក្រុមការងារបានរៀបចំសិក្ខាសាលា ដើម្បីប្រមូលមតិយោបល់លើឯកសារ «ការអនុវត្តជាក់ស្តែងនៃដំណើរការពិនិត្យ និងអនុម័តច្បាប់នៃសភាកម្ពុជា» ដោយមានការធ្វើបង្ហាញពីអ្នកជំនាញនានាដូចជា សមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី មន្ត្រីជាន់ខ្ពស់នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នាយកប្រតិបត្តិនៃវិទ្យាស្ថានសភាកម្ពុជា ព្រមទាំងសាស្ត្រាចារ្យច្បាប់។ ជាមួយគ្នានេះ ក៏បានផ្តល់វេទិកាដល់អ្នកចូលរួមក្នុងការលើកសំណួរទាក់ទងនឹងប្រធានបទខាងលើមកចោទសួរដែរ។ ជារួម សិក្ខាសាលានេះ បានប្រមូលនូវធាតុចូលសំខាន់ៗបន្ថែមមួយចំនួនដូចខាងក្រោម ៖

- អនុសាសន៍ណែនាំរបស់ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាទាក់ទងនឹងទ្រឹស្តីនៃការធ្វើច្បាប់ល្អដែលជាគោលការណ៍អនុវត្តល្អៗ បន្សុំទៅនឹងស្ថានភាពជាក់ស្តែងដែលអាចឱ្យកម្ពុជាទទួលយក និងអាចអនុវត្តបាន។

- បទពិសោធន៍ជាក់ស្តែងនៃការរៀបចំសេចក្តីស្នើច្បាប់ដែលត្រូវអនុវត្តដោយមន្ត្រីបច្ចេកទេសនៃសភាទាំងពីរ អនុលោមតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៣ ទាក់ទងនឹង ខ្លឹមសារនិងទម្រង់នៃការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ។ (**ចំណុច II, ១.៣**)

- សេវាគាំទ្រនានារបស់សភា ជាពិសេសសេវានីតិវិធី លិខិតស្នាមរដ្ឋបាល និងសេវាស្រាវជ្រាវ បម្រើឱ្យមុខងារនីតិកម្មរបស់អគ្គលេខាធិការដ្ឋានរដ្ឋសភា និងព្រឹទ្ធសភា ដោយបង្ហាញអំពីតួនាទី និងភារកិច្ចរបស់មន្ត្រីសភាក្នុងអង្គភាពពាក់ព័ន្ធសំខាន់ៗ ដែលបានផ្តល់ជូនសមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា។

តាមរយៈមតិយោបល់ ព័ត៌មាន និងទិន្នន័យនានាដែលប្រមូលបានពីដំណាក់កាលទាំង៣ ខាងលើ រិតតែធ្វើឱ្យសៀវភៅនេះមានខ្លឹមសារគ្រប់គ្រាន់ និងគ្រប់ជ្រុងជ្រោយ។

# ប្រវត្តិនៃសភាកម្ពុជា

ប្រទេសកម្ពុជាមានរដ្ឋធម្មនុញ្ញដំបូងនៅឆ្នាំ១៩៤៧។ ក្នុងរយៈពេលជាងប្រាំពីរទស្សវត្សរ៍កន្លងមកនេះ ប្រព័ន្ធនយោបាយនៃព្រះរាជាណាចក្រកម្ពុជា មានការប្រែប្រួលជានិច្ចពីរបបមួយទៅរបបមួយ។ ប្រព័ន្ធទ្វិកសភាបានកើតឡើងដំបូងក្នុងរបបព្រះរាជាណាចក្រកម្ពុជាទី១ ឆ្នាំ១៩៤៧ ដោយបានអូសបន្លាយមកដល់របបសាធារណរដ្ឋខ្មែរ នៅពេលនោះ សភាជាន់ទាបមានឈ្មោះថា **សភាជាតិ** និងសភាជាន់ខ្ពស់ ហៅថា **ព្រឹទ្ធសភា**។ បន្ទាប់មក របបកម្ពុជាប្រជាធិបតេយ្យដែលដឹកនាំដោយ **សាឡុត ស (ប៉ុល ពត)** អ្វីៗ ត្រូវបានលុបបំបាត់ចោលស្ទើរតែទាំងស្រុង ហើយស្ថាប័នតំណាងមានតែសភាតំណាងប្រជាជនកម្ពុជាប៉ុណ្ណោះ។ មកដល់សម័យប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា មានតែសភាមួយថ្នាក់ គឺ **រដ្ឋសភា**។

បន្ទាប់ពីការបោះឆ្នោតក្នុងឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានចាប់ផ្តើមអនុវត្តប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្សឡើងវិញ ហៅថាព្រះរាជាណាចក្រកម្ពុជាទី២ មានសភាមួយថ្នាក់គឺ **រដ្ឋសភា** ដែលមានសមាជិកតំណាងរាស្ត្របានជាប់ឆ្នោតមកពីគណបក្សនយោបាយជាច្រើនផ្សេងគ្នា។ ក្នុងដំណាក់កាលចុងក្រោយនេះ កម្ពុជាបានអនុវត្តប្រព័ន្ធសភាទោលរហូតមកដល់ចុងឆ្នាំ១៩៩៨។

ក្រោយការបោះឆ្នោតសកលឆ្នាំ១៩៩៨ មានវិបត្តិនយោបាយបានកើតឡើង ហើយឈានដល់ការសម្របសម្រួលដើម្បីដោះស្រាយការជាប់គាំងនយោបាយ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃ **សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ** ដែលពេលនោះព្រះអង្គទ្រង់ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ ហើយជាលទ្ធផល ភាគីទាំងអស់បានព្រមព្រៀងគ្នាដង្ហែរតាមព្រះរាជតម្រិះរបស់ព្រះអង្គ ដែលទ្រង់សព្វព្រះរាជហឫទ័យបង្កើតស្ថាប័នព្រឹទ្ធសភាឡើងវិញ។

ការបង្កើតព្រឹទ្ធសភានៅពេលនោះតម្រូវឱ្យធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ហើយសភាជាន់ខ្ពស់ «**ព្រឹទ្ធសភា**» ត្រូវបានចាប់បដិសន្ធិ និងបានបើកសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី១ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ ក្រោយពេលដែលរដ្ឋសភាដំណើរការបានមួយអាណត្តិ (១៩៩៣-

១៩៩៨) ។ យោងតាមមាត្រា៩៩ថ្មី វាក្យខ័ណ្ឌទី២ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កំណត់ថា ព្រឹទ្ធសភា មានសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្ដាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

ព្រឹទ្ធសភានីតិកាលទី១ (១៩៩៩-២០០៥) មានអាណត្តិ៥ឆ្នាំ និងមានសមាជិកទាំងអស់ចំនួន ៦១ រូប ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ។ សមាជិកព្រឹទ្ធសភាត្រូវបានជ្រើសរើសតាមបែបសមាមាត្រពីគណបក្សនយោបាយទាំងបី (គណប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសម រង្ស៊ី) ដែលមានអាសនៈនៅក្នុងរដ្ឋសភា តាមសំណើរបស់ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា។ ព្រឹទ្ធសភានីតិកាលទី១ បានប្រកាសបន្តនីតិកាលរបស់ខ្លួនពីរដង (ម្ដងមួយឆ្នាំ) លើកទី១ ចាប់ពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៤ ដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥ និង លើកទី២ ចាប់ពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥ រហូតដល់ព្រឹទ្ធសភានីតិកាលទី២ ចូលកាន់តំណែងនាថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៦។

អនុលោមតាមរដ្ឋធម្មនុញ្ញ សេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវបានស្នើឡើង ហើយត្រូវបានអនុម័តយល់ព្រមដោយរដ្ឋសភា និងព្រឹទ្ធសភា រួចបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាព ហើយត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៥។ បន្ទាប់ពីពេលនោះមក ដំណើរការរៀបចំបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាបានប្រព្រឹត្តទៅយ៉ាងទៀងទាត់ចាប់ពីនីតិកាលទី២ រហូតមកដល់បច្ចុប្បន្ន។

ដោយឡែក រដ្ឋសភាបានដំណើរការស្ថាប័នរបស់ខ្លួនជាប្រក្រតីចាប់តាំងពីនីតិកាលទី១ រហូតដល់បច្ចុប្បន្ននេះ។ ចាប់ពីនីតិកាលទី១ ដល់នីតិកាលទី៥ គណបក្សនយោបាយដែលត្រូវបានជាប់ឆ្នោតនៅរដ្ឋសភាមានច្រើនគណបក្ស ប៉ុន្តែក្នុងនីតិកាលទី៦ គណបក្សនយោបាយដែលត្រូវបានជាប់ឆ្នោត មានតែគណបក្សមួយក្នុងចំណោមគណបក្ស ២០ ដែលបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

ក្នុងនាមជាស្ថាប័ននីតិប្បញ្ញត្តិកំពូលរបស់ជាតិ រដ្ឋសភា និងព្រឹទ្ធសភា មានបទបញ្ជាផ្ទៃក្នុងរៀងខ្លួនដើម្បីអនុវត្តការងារឱ្យស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។ រាល់សេចក្តីព្រាងច្បាប់ សេចក្តីស្នើ

ច្បាប់ ឬបញ្ហាទាំងពួង ត្រូវបញ្ជូនទៅរដ្ឋសភាពិនិត្យជាលើកដំបូង មុននឹងបញ្ជូនមកព្រឹទ្ធសភាដើម្បីពិនិត្យ និងឱ្យយោបល់។

# I. មុខងារចម្បងរបស់សភាកម្ពុជា

រដ្ឋសភា និងព្រឹទ្ធសភាអនុវត្តមុខងារនីតិកម្ម មុខងារតំណាង និងមុខងារតាមដានការអនុវត្តច្បាប់ដូចគ្នា ប៉ុន្តែសភាទាំងពីរមានរបៀបបំពេញមុខងារខាងលើមិនដូចគ្នានោះទេ។ ខាងក្រោមនេះបង្ហាញអំពីភាពខុសគ្នារវាងមុខងាររបស់រដ្ឋសភា និងព្រឹទ្ធសភា៖

## ១. មុខងារនីតិកម្ម

សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់។[1] រដ្ឋសភា និងព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។[2] លើសពីនេះ តួនាទីក្នុងការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ គឺមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងព្រឹទ្ធសភា និងសេចក្តីសម្រេចស្តីពីតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការនានារដ្ឋសភា និងព្រឹទ្ធសភា។[3]

## ២. មុខងារតំណាង

តំណាងរាស្ត្រត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់ពីប្រជាពលរដ្ឋ រីឯសមាជិកព្រឹទ្ធសភា ត្រូវបានជ្រើសតាំង តាមរយៈការបោះឆ្នោតអសកលដោយសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ និងអ្នកតំណាងរាស្ត្រនៅក្នុងតំណែង។ ក្រៅពីនោះ ក៏មានសមាជិកព្រឹទ្ធសភា ២រូប ត្រូវបានចាត់តាំងដោយព្រះមហា

[1] រដ្ឋធម្មនុញ្ញ មាត្រា៩១ ថ្មី

[2] រដ្ឋធម្មនុញ្ញ មាត្រា៩០ថ្មី (ពីរ) មាត្រា៩៩ថ្មី

[3] សេចក្តីសម្រេចនានារបស់ព្រឹទ្ធសភានីតិកាលទី៤ ខែមិថុនា ឆ្នាំ ២០១៨ និងសេចក្តីសម្រេចនានារបស់រដ្ឋសភាចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០១៤

ក្សត្រ និង ២រូប ទៀត ត្រូវបានជ្រើសតាំងដោយរដ្ឋសភា។[4] ដោយមូលហេតុនេះ ទើបតំណាងរាស្ត្រចុះបំពេញការងារនៅទីស្នាក់ការនៅតាមមណ្ឌលរាជធានី-ខេត្តទាំង២៥ រីឯសមាជិកព្រឹទ្ធសភាចុះបំពេញការងារតាមបណ្តាភូមិភាគទាំង៨ ទូទាំងប្រទេស។ ដូចនេះ មុខងារតំណាងរបស់សភាទាំងពីរមានការអនុវត្តមិនដូចគ្នាទេ សមាជិករដ្ឋសភាគឺជាតំណាងឱ្យប្រជាពលរដ្ឋនៅក្នុងមណ្ឌលដែលខ្លួនស្ថិត នៅ រីឯសមាជិកព្រឹទ្ធសភាគឺជាតំណាងឱ្យភូមិភាគរបស់ខ្លួន។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏សមាជិករដ្ឋសភា និង សមាជិកព្រឹទ្ធសភាជាតំណាងប្រជាជាតិខ្មែរទាំងមូលដូចគ្នាដែរ។[5]

## ៣. មុខងារតាមដានការអនុវត្តច្បាប់

ការអនុវត្តមុខងារតាមដានការអនុវត្តច្បាប់របស់រដ្ឋសភា និងព្រឹទ្ធសភាក៏មានលក្ខណៈខុសគ្នាដែរ។ តំណាងរាស្ត្រមានសិទ្ធិលើកសំណួរទៅរាជរដ្ឋាភិបាល ផ្ទុយទៅវិញសមាជិកព្រឹទ្ធសភាពុំមានសិទ្ធិនេះទេ។ ការដាក់សំណួរទៅរាជរដ្ឋាភិបាល ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា។ ចម្លើយត្រូវផ្តល់ឱ្យតាមរយៈរដ្ឋមន្ត្រីមួយរូប ឬច្រើនរូប អាស្រ័យទៅតាមបញ្ហាដែលបានលើកឡើងក្នុងសំណួរ ស្ថិតក្រោមការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូប ឬច្រើនរូប។ ប្រសិនបើបញ្ហាពាក់ព័ន្ធនឹងនយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវមកឆ្លើយនៅចំពោះមុខរដ្ឋសភាដោយផ្ទាល់។ ចម្លើយរបស់រដ្ឋមន្ត្រី ឬចម្លើយរបស់នាយករដ្ឋមន្ត្រីអាចធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។ ចម្លើយ ត្រូវឆ្លើយតបក្នុងអំឡុងពេលប្រាំពីរថ្ងៃបន្ទាប់ពីទទួលបានសំណួរ។ ក្នុងករណីចម្លើយផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសម្រេចបើកឱ្យមាន ឬមិនឱ្យមានការជជែកដេញដោល។ ចម្លើយរបស់រដ្ឋមន្ត្រី ឬចម្លើយរបស់នាយករដ្ឋមន្ត្រីត្រូវបញ្ចប់ចំពោះសំណួរដែលបានលើក ប្រសិនបើគ្មានការបើកឱ្យការជជែកដេញដោលទេនោះ ចម្លើយរបស់រដ្ឋមន្ត្រី ឬនាយករដ្ឋមន្ត្រីនឹងបញ្ចប់សំណួរតែម្តង។ បើមានការបើកឱ្យជជែកដេញដោលម្ចាស់សំណួរ វាគ្មិនឯទៀត និងរដ្ឋមន្ត្រីពាក់ព័ន្ធ ឬនាយករដ្ឋមន្ត្រី អាចជជែកប្តូរយោបល់ក្នុងរយៈពេលដែលមិនអាចលើសពីមួយពេលប្រជុំឡើយ។ រដ្ឋសភាកំណត់

[4] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ឆ្នាំ២០១៧ មាត្រា៥ មាត្រា៦

[5] រដ្ឋធម្មនុញ្ញ មាត្រា៧៧ និង ច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា មាត្រា២

ទុកពេលមួយថ្ងៃ ក្នុងមួយសប្ដាហ៍ សម្រាប់ការឆ្លើយសំណួរ។ ទោះបីយ៉ាងណាក៏ដោយ សម័យប្រជុំសម្រាប់ការឆ្លើយសំណួរខាងលើនេះ មិនអាចបើកលទ្ធភាពឱ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ។[6] លើសពីនេះ គណៈកម្មការទាំងឡាយរបស់រដ្ឋសភាអាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាកព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន។[7] ផ្ទុយទៅវិញ នីតិវិធីខាងលើមិនអាចអនុវត្តបានសម្រាប់ សមាជិកព្រឹទ្ធសភាបានទេ ព្រោះថា សមាជិកព្រឹទ្ធសភាអាចត្រឹមតែតាមដានការអនុវត្តច្បាប់ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលតែប៉ុណ្ណោះ។ ជាទូទៅ ការអនុវត្តមុខងារតាមដានរបស់ព្រឹទ្ធសភា អាចធ្វើឡើងតាមរយៈគណៈកម្មការនានារបស់ព្រឹទ្ធសភា ដែលមានសិទ្ធិអញ្ជើញតំណាងរាជរដ្ឋាភិបាល សមាជិករដ្ឋសភា ឬម្ចាស់សំណើសុំកែសម្រួល ឬអ្នកស្នើច្បាប់ដែលជាម្ចាស់សេចក្ដីព្រាងច្បាប់ឬសេចក្ដីស្នើច្បាប់ឬបញ្ហាទាំងពួង មកបំភ្លឺនៅចំពោះមុខគណៈកម្មការរបស់ព្រឹទ្ធសភា។ គណៈកម្មការក៏អាចអញ្ជើញតំណាងក្រសួងពាក់ព័ន្ធ ឥស្សរជន អ្នកជំនាញការ ឬតំណាងសង្គមស៊ីវិល ចូលរួមឱ្យយោបល់លើបញ្ហាផ្សេងៗបានដែរ។[8]

ភាពខុសគ្នាមួយទៀតគឺ រដ្ឋសភាមានអំណាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង តាមរយៈការបោះឆ្នោតលើញត្តិបន្ទោសដោយមានសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃចំនួនសមាជិករដ្ឋសភាទាំងមូល។[9] ទោះជាយ៉ាងណាក៏ដោយ ក៏អំណាចនេះមិនត្រូវបានផ្ដល់ជូនព្រឹទ្ធសភាដែរ។

មុខងារចម្បងរបស់រដ្ឋសភា និងព្រឹទ្ធសភាមានបង្ហាញនៅក្នុងតារាងប្រៀបធៀបក្នុងតារាងទី១ ដូចខាងក្រោមនេះ ៖

[6] រដ្ឋធម្មនុញ្ញ មាត្រា៩៦
[7] រដ្ឋធម្មនុញ្ញ មាត្រា៩៧
[8] បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ឆ្នាំ២០១៧ ប្រការ១៨ ចំណុច ច និង ឆ
[9] រដ្ឋធម្មនុញ្ញ មាត្រា៩៨ ថ្មី

*តារាងទី១ ៖ តារាងប្រៀបធៀបមុខងារចម្បងរបស់រដ្ឋសភា និងព្រឹទ្ធសភា*

| **មុខងារ** | **រដ្ឋសភា** | **ព្រឹទ្ធសភា** |
|---|---|---|
| **នីតិកម្ម** | -ផ្តួចផ្តើមសេចក្តីស្នើច្បាប់ ឬសេចក្តីស្នើវិសោធនកម្មច្បាប់ជាធរមាន ប៉ុន្តែមិនសំដៅកាត់បន្ថយចំណូលសាធារណៈ ឬដាក់បន្ទុកមកលើប្រជាពលរដ្ឋ (រដ្ឋធម្មនុញ្ញ មាត្រា៩១ ថ្មី)<br>-ផ្តួចផ្តើមសេចក្តីស្នើវិសោធនកម្មរដ្ឋធម្មនុញ្ញ [រដ្ឋធម្មនុញ្ញ មាត្រា១៥៣ ថ្មី (ពីរ)]<br>-ពិនិត្យនិងអនុម័តសេចក្តីព្រាងច្បាប់ ឬសេចក្តី ស្នើច្បាប់<br>-បើកកិច្ចប្រជុំពេញអង្គនៃរដ្ឋសភាពិភាក្សានិងអនុម័តសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់មួយមាត្រាម្តងៗ ឬមួយជំពូកម្តងៗ | -ផ្តួចផ្តើមសេចក្តីស្នើច្បាប់ ឬសេចក្តីស្នើវិសោធនកម្មច្បាប់ជាធរមាន ប៉ុន្តែមិនសំដៅកាត់បន្ថយចំណូលសាធារណៈ ឬដាក់បន្ទុកមកលើប្រជាពលរដ្ឋ (រដ្ឋធម្មនុញ្ញ មាត្រា៩១ ថ្មី)<br>-គ្មានសិទ្ធិផ្តួចផ្តើមសេចក្តីស្នើវិសោធនកម្មរដ្ឋធម្មនុញ្ញទេ<br>-ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់<br>-បើកកិច្ចប្រជុំពេញអង្គនៃព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់តែលើរបាយការណ៍ (សេចក្តីសន្និដ្ឋានរួម) របស់គណៈកម្មការទទួលបន្ទុកសិក្សាស្រាវជ្រាវសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ |
| **តំណាង** | -តំណាងរាស្ត្រជាតំណាងប្រជាជាតិ | -សមាជិកព្រឹទ្ធសភាគឺតំណាងឱ្យប្រជា |

| | | |
|---|---|---|
| | ខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ ។<br><br>-តំណាងរាស្ត្របោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋទូទាំងប្រទេស | ជាតិខ្មែរទាំងមូល ពុំមែនត្រឹមតែជាតំណាងឱ្យ ភូមិភាគរបស់ខ្លួនប៉ុណ្ណោះទេ (ច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា ឆ្នាំ២០០៨ មាត្រា២)<br>-សមាជិកព្រឹទ្ធសភាបោះឆ្នោតជ្រើសតាំងដោយអង្គបោះឆ្នោត(សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ និងតំណាងរាស្ត្រ) ក្រៅពីនេះ ២ រូបតែងតាំងដោយព្រះមហាក្សត្រ និង ២ រូប ទៀត បោះឆ្នោតជ្រើសតាំងដោយរដ្ឋសភា (ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ឆ្នាំ២០១៧ មាត្រា៥ និង មាត្រា៦) |
| **តាមដានការអនុវត្តច្បាប់** | -ដាក់សំណួរទៅរាជរដ្ឋាភិបាលតាមរយៈប្រធានរដ្ឋសភា (មួយថ្ងៃក្នុងមួយសប្តាហ៍)<br>-អញ្ជើញតំណាងរាជរដ្ឋាភិបាលមកបំភ្លឺបញ្ហា ស្ថិតក្រោមការទទួលខុសត្រូវរបស់ខ្លួន នៅចំពោះ មុខគណៈកម្មការនានារដ្ឋសភា | -គណៈកម្មការនានាធ្វើការតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានាតាមវិស័យដែលជាសមត្ថកិច្ចរបស់ខ្លួន ៖ សវនការ ឬពិគ្រោះយោបល់អំពីវឌ្ឍនភាពការងារជាមួយក្រសួងស្ថាប័ននានា និងរដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី-ខេត្ត) ហើយធ្វើរបាយការណ៍ជូនគណៈ |

| | | |
|---|---|---|
| | -បណ្តេញចេញ ឬ ដកហូតសមាជិករាជរដ្ឋាភិបាលពីតំណែងតាមរយៈការអនុម័តញ្ញត្តិបន្ទោស ( ៥០%+១ ) (រដ្ឋធម្មនុញ្ញ មាត្រា៩៨ ថ្មី) | កម្មាធិការអចិន្ត្រៃយ៍ និងកិច្ចជុំពេញអង្គនៃព្រឹទ្ធសភា។ |

# II. គោលការណ៍សំខាន់ៗក្នុងដំណើរការនីតិកម្ម

## ១. សិទ្ធិនៃការផ្តួចផ្តើមធ្វើច្បាប់ និងគោលការណ៍អនុម័តច្បាប់

សេចក្តីព្រាងច្បាប់ ត្រូវបានផ្តួចផ្តើមឡើងដោយរាជរដ្ឋាភិបាល រីឯសេចក្តីស្នើច្បាប់ត្រូវបានផ្តួចផ្តើមឡើងដោយរដ្ឋសភា ឬព្រឹទ្ធសភា ឬរដ្ឋសភានិងព្រឹទ្ធសភារួមគ្នា ហើយត្រូវបានពិនិត្យ និងអនុម័តដោយរដ្ឋសភា រួចបញ្ជូនទៅព្រឹទ្ធសភាដើម្បីពិនិត្យ និងផ្តល់យោបល់។

### ១.១. សិទ្ធិនៃការផ្តួចផ្តើមធ្វើច្បាប់

#### ១.១.១. សេចក្តីព្រាងច្បាប់

នាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់[10] ដែលអាចជាសេចក្តីព្រាងច្បាប់ថ្មី ឬសេចក្តីព្រាងវិសោធនកម្មនៃច្បាប់ជាធរមាន។ ដំណើរការរៀបចំសេចក្តីព្រាងច្បាប់នៅអង្គនីតិប្រតិបត្តិ អនុវត្តតាមទម្រង់ និងខ្លឹមសារដូចមានកំណត់នៅក្នុងសារាចរណ៍របស់រាជរដ្ឋាភិបាលចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣។[11]

#### ១.១.២. សេចក្តីស្នើច្បាប់

សមាជិករដ្ឋសភា ឬសមាជិកព្រឹទ្ធសភាមួយរូប ឬច្រើនរូប[12] មានសិទ្ធិផ្តួចផ្តើមធ្វើសេចក្តីស្នើច្បាប់ ឬសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ដែលកំពុងនៅជាធរមាន ហើយសេចក្តីស្នើច្បាប់នោះត្រូវសរសេរជាលាយលក្ខណ៍អក្សរ មានចំណងជើង ចែកជាជំពូក ចែកជាមាត្រា និងភ្ជាប់មកជាមួយសេចក្តីថ្លែងហេតុ។[13] រដ្ឋសភា ឬព្រឹទ្ធសភា អាចបង្កើតគណៈកម្មការចំពោះកិច្ច ឬគណៈកម្មការ

---

[10] រដ្ឋធម្មនុញ្ញ មាត្រា៩១ ថ្មី

[11] ទម្រង់នៃសេចក្តីព្រាងច្បាប់នៅក្នុងសារាចរ ឆ្នាំ២០១៣ ទំព័រ៩-១១

[12] សេចក្តីសម្រេច លេខ ១៩៥/០០៣/២០១៥ កបធ.ច ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ របស់ក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយមាត្រា៩១ ថ្មី នៃរដ្ឋធម្មនុញ្ញ ស្របតាមសំណើរបស់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា**

[13] បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ឆ្នាំ២០១៨ ប្រការ២២ និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ឆ្នាំ២០១៧ ប្រការ៣៤

ពិសេសដើម្បីជួយដល់ការរៀបចំសេចក្តីស្នើច្បាប់ ឬសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ដែលកំពុងនៅជាធរមាន។[14]

សមាជិករដ្ឋសភាអាចស្នើសុំធ្វើវិសោធនកម្មលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ក្នុងអំឡុងពេលពិភាក្សាក្នុងគណៈកម្មការ ឬក្នុងប្រជុំពេញអង្គ។ សំណើសុំវិសោធនកម្មនោះត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយជូនទៅគណៈកម្មការនានាក៏បាន ឬជូនទៅរដ្ឋសភាក្នុងពេលប្រជុំពេញអង្គក៏បាន។[15] បន្ទាប់ពីទទួលបានសំណើវិសោធនកម្ម អង្គរដ្ឋសភាអាចសម្រេចថាយល់ព្រម ឬមិនយល់ព្រមទទួលយកសំណើនោះមកពិភាក្សា។[16] អង្គរដ្ឋសភាមិនអនុម័តសំណើវិសោធនកម្មក្នុងថ្ងៃដែលទទួលពាក្យសុំនោះទេ វៀរលែងតែជាការប្រញាប់។[17]

### ១.១.៣. សិទ្ធិក្នុងការផ្តួចផ្តើមធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ

ការផ្តួចផ្តើមគំនិតសេរើឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្ររបស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភាតាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួន (១/៤) នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវធ្វើឡើងដោយច្បាប់រដ្ឋធម្មនុញ្ញមួយដែលអនុម័តដោយរដ្ឋសភា ត្រូវយកតាមមតិភាគច្រើន ២/៣ នៃចំនួនសមាជិករដ្ឋសភាទាំងមូល។[18] ទោះបីយ៉ាងណា យោងតាមរដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រទ្រង់ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាធម្មនុញ្ញចំពោះសំណើទាំងឡាយដែលសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។ [19] ការសើរើនិងវិសោធនកម្មនៃរដ្ឋធម្មនុញ្ញមិនអាចធ្វើទៅបានឡើយកាលបើប៉ះពាល់ដល់គោលការណ៍ឬបទបញ្ញត្តិហាមឃាត់របស់រដ្ឋធម្មនុញ្ញដូចមានបកស្រាយក្នុងចំណុច២ ទំព័រ៣៤ ។

---

[14] បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ឆ្នាំ២០១៨ ប្រការ១១ និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ឆ្នាំ២០១៧ ប្រការ១៩

[15] បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ឆ្នាំ២០១៨ មាត្រា២៦

[16] បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ឆ្នាំ២០១៨ មាត្រា២៧

[17] បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ឆ្នាំ២០១៨ មាត្រា២៨

[18] រដ្ឋធម្មនុញ្ញ មាត្រា១៥៣ ថ្មី (ពីរ)

[19] រដ្ឋធម្មនុញ្ញ មាត្រា១៤៣ ថ្មី

### ១.១.៤. សេចក្តីព្រាងច្បាប់ស្តីពីថវិកា

ថវិកាជាតិ រៀបរាប់អំពីផែនការចំណូលនិងចំណាយរបស់រាជរដ្ឋាភិបាល ហើយអនុញ្ញាតឱ្យរាជរដ្ឋាភិបាលកំណត់ថា តើមានថវិកាគ្រប់គ្រាន់ស្របតាមតម្រូវការចំណាយដែរឬយ៉ាងណា? ថវិកាជាតិផ្តល់សិទ្ធិឱ្យអង្គនីតិប្រតិបត្តិប្រមូលចំណូល និងចំណាយថវិកាក្នុងគោលដៅធ្វើឱ្យសម្រេចគោលបំណងរបស់រាជរដ្ឋាភិបាលដូចជា ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ច។

ថវិកា គឺជាឧបករណ៍សំខាន់បំផុតរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយរបស់ខ្លួន។ ដូចនេះ ច្បាប់ដែលមានលក្ខណៈជាច្បាប់ហិរញ្ញវត្ថុរួមមាន **ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ** និង **ច្បាប់ទូទាត់ថវិកា**។[20]

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ គ្រោងនិងអនុញ្ញាតសម្រាប់ឆ្នាំនីមួយៗនូវប្រភពធនធាន និងបន្ទុកដែលត្រូវចំណាយសរុបរបស់រដ្ឋ ដើម្បីបម្រើឱ្យរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដោយគិតគូរដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្របតាមហិរញ្ញវត្ថុ និងរូបិយវត្ថុជាសារវន្ត ជាពិសេសតាមរយៈការធានាឱ្យបាននូវតុល្យភាពថវិកា។[21]

ជាមូលដ្ឋាន គោលការណ៍នៃការគ្រប់គ្រងរូបិយប័ណ្ណ និងប្រព័ន្ធហិរញ្ញវត្ថុត្រូវកំណត់ដោយច្បាប់។[22] រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានា ផ្នែកហិរញ្ញវត្ថុ និងការបង្កើត ការកែប្រែ ឬការលុបចោលពន្ធដារ។[23]

នៅកម្ពុជា ថវិកាជាតិត្រូវរៀបចំជារៀងរាល់ឆ្នាំសម្រាប់អនុវត្តឆ្នាំបន្ទាប់(ឆ្នាំសារពើពន្ធ)។ ថវិការដ្ឋត្រូវបានរៀបចំដោយរាជរដ្ឋាភិបាល និងត្រូវអនុម័តដោយរដ្ឋសភា និងយល់ព្រមដោយព្រឹទ្ធសភាមុននឹងប្រកាសឱ្យប្រើ។

ការៀបចំច្បាប់ថវិកា ត្រូវចែងច្បាស់ក្នុងក្របខណ្ឌនៃការរៀបចំថវិកា។

---

[20] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ មាត្រា៨ (ឆ្នាំ២០០៨)

[21] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ មាត្រា៩ (ឆ្នាំ២០០៨)

[22] រដ្ឋធម្មនុញ្ញ មាត្រា៥៧

[23] រដ្ឋធម្មនុញ្ញ មាត្រា៩០ ថ្មី(ពីរ) វាក្យខណ្ឌទី២

### ក. ក្របខណ្ឌថវិកា

ផ្អែកតាមប្រតិទិនថវិកា និងដំណើរការរៀបចំថវិកាជាតិ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បែងចែកក្របខណ្ឌនៃការរៀបចំថវិកាជាបីដំណាក់កាលសំខាន់ៗគឺ ទី១ ការរៀបចំយុទ្ធសាស្ត្រថវិកា ទី២ ការព្យាករណ៍ថវិកា និងទី៣ ការអនុម័តថវិកា ។

ខាងក្រោមនេះជាសេចក្តីសង្ខេបនៃដំណើរការរៀបចំថវិកាជាតិ ។

| ដំណើរការរៀបចំច្បាប់ថវិកាជាតិ<br>(មាត្រា ១១ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ) | |
|---|---|
| **មករា - កុម្ភៈ** | - ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច |
| **ពិនិត្យ និងវាយតម្លៃ** | - ការអនុវត្តថវិកាឆ្នាំមុន |
| **មីនា - ឧសភា** | - សារាចរណែនាំ ៖ សប្តាហ៍ទី១ ខែមីនា |
| **ផែនការយុទ្ធសាស្ត្រថវិកា** | - ការសម្របសម្រួល ៖ ១៥ ដល់ ៣១ ខែឧសភា |
| **មិថុនា - សីហា** | - សារាចរណែនាំ ៖ សប្តាហ៍ទី១ ខែមិថុនា |
| **ការប៉ាន់ស្មានថវិកា** | - ការសម្របសម្រួល ៖ ១៥ ដល់ ៣១ កក្កដា |
| | - ការចរចាថវិកា ៖ សីហា ។ |
| **កញ្ញា** | - ការសម្របសម្រួលថវិកា និងការរៀបចំសេចក្តីព្រាងច្បាប់ថវិកា |
| **តុលា - ធ្នូ** | - សប្តាហ៍ទី១ ខែតុលា ៖ បញ្ជូនទៅគណៈរដ្ឋមន្ត្រី |
| **ការអនុម័តច្បាប់ថវិកា** | - សប្តាហ៍ទី១ ខែវិច្ឆិកា ៖ បញ្ជូនទៅរដ្ឋសភា |
| **ត្រូវតែអនុម័ត** | រដ្ឋសភា ៖ ពិភាក្សា និងអនុម័ត |
| **ត្រឹមថ្ងៃ២៥ ខែធ្នូ** | ព្រឹទ្ធសភា ៖ ពិនិត្យ និងឱ្យយោបល់ |

## ខ. ករណីពិសេសនៃថវិកា

យោងតាមមាត្រា៥០ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ចែងថាប្រសិនបើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំមិនត្រូវបានអនុម័តមុនថ្ងៃទី១ ខែមករានៃឆ្នាំការិយបរិច្ឆេទទេនោះ ថវិកាឆ្នាំមុនត្រូវបានបន្តដោយស្របច្បាប់ក្នុងលក្ខខណ្ឌដូចខាងក្រោម ៖

- ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងចំណូលគ្រប់ប្រភេទផ្សេងៗទៀតត្រូវអនុញ្ញាត និងបន្តឱ្យប្រមូលក្នុងលក្ខខណ្ឌ និងតាមបែបបទដែលបានកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុពីមុន និងក្នុងក្របខណ្ឌច្បាប់ និងបទបញ្ញាដែលមានជាធរមាន

- ចំណាយចរន្ត ក្រៅពីបន្ទុកបំណុលសាធារណៈ នៅតែបន្តអនុវត្តតាមក្របខណ្ឌនៃថវិកាឆ្នាំមុនដោយគិតតាម ***វិធីមួយភាគដប់ពីរ (១/១២)*** ជាបណ្តោះអាសន្នក្នុងខែនីមួយៗ រហូតដល់ថវិកាថ្មីត្រូវបានអនុម័ត

- ចំណាយមូលធននៃថវិកា ក្រៅពីរំលស់បំណុលសាធារណៈ នៅតែបន្តអនុវត្តតាមក្របខណ្ឌនៃថវិកាឆ្នាំមុន ក្នុងក្របខណ្ឌឥណទានទូទាត់ដែលនៅទំនេរ ហើយអាចលើសពីនេះ ប្រសិនបើចាំបាច់ ដោយមិនឱ្យការទូទាត់នោះលើសពីកម្រិតឥណទានភ្ជាប់សន្យា ដែលបានអនុម័តក្នុងថវិកាឆ្នាំមុន

- ចំណាយទាំងឡាយដែលជាកាតព្វកិច្ចទាក់ទងនឹងសមាជិកភាពរបស់កម្ពុជាក្នុងស្ថាប័នអន្តរជាតិ និងអន្តររដ្ឋាភិបាល និងកាតព្វកិច្ចទាក់ទងនឹងបន្ទុកបំណុលសាធារណៈ រួមមានការរំលស់ប្រាក់ដើម ការបង់ការប្រាក់ កម្រៃសេវា និង/ឬការបង់ពិន័យដាយថាហេតុត្រូវបានរ៉ាប់រងជាបន្ត មិនឱ្យដាច់តាមកិច្ចព្រមព្រៀងជាធរមាន។

## ១.២. គោលការណ៍នៃការអនុម័ត

ជាគោលការណ៍ រដ្ឋសភាពិនិត្យ និងអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ហើយបញ្ជូនមកព្រឹទ្ធសភាដើម្បីពិនិត្យ និងឱ្យយោបល់។ ការអនុម័តច្បាប់ធម្មតាតម្រូវឱ្យមានសំឡេងភាគ

ច្រើនដាច់ខាត (៥០%+១) រីឯការអនុម័តវិសោធនកម្មរដ្ឋធម្មនុញ្ញតម្រូវឱ្យមានសំឡេងភាគច្រើនពីរភាគបី (២/៣) នៃចំនួនសមាជិកតំណាងរាស្ត្រទាំងមូល។

### ១.២.១. កូរ៉ុម និងសំឡេងអនុម័ត

អនុលោមតាមរដ្ឋធម្មនុញ្ញ មាត្រា៨៨ ថ្មី (ពីរ) និងមាត្រា១១១ ថ្មី (ពីរ) ការប្រជុំរបស់រដ្ឋសភា និងការប្រជុំរបស់ព្រឹទ្ធសភា អាចយកជាការបានលុះត្រាតែ ៖

ក- មានកូរ៉ុមលើសពី ពីរភាគបី (២/៣) នៃចំនួនសមាជិកទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិកទាំងមូល។

ខ- មានកូរ៉ុមលើសពីពាក់កណ្តាល នៃចំនួនសមាជិកទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដាច់ខាត (៥០%+១) នៃចំនួនសមាជិកទាំង មូល។

ចំនួនកូរ៉ុមនិងសំឡេងអនុម័តមានបង្ហាញនៅក្នុងតារាងក្នុងតារាងទី២ ដូចខាងក្រោមនេះ ៖

*តារាងទី២៖ ខ្លឹមសារសង្ខេបអំពីកូរ៉ុមនិងសំឡេងអនុម័ត*

| ល.រ | កម្មវត្ថុនៃការអនុម័ត | ម្ចាស់សំណើ | កូរ៉ុមប្រជុំ | សំឡេងអនុម័ត |
|---|---|---|---|---|
| ១ | ច្បាប់ធម្មតា និងច្បាប់អង្គការ | រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា | លើសពីពាក់កណ្តាល (៥០%+១) នៃចំនួនសមាជិកទាំងមូល | មតិភាគច្រើនដាច់ខាត (៥០%+១) នៃចំនួនសមាជិកទាំងមូល |
| ២ | -បទបញ្ជាផ្ទៃក្នុងរដ្ឋសភា<br>-បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា<br>-ច្បាប់ជាក់លាក់មួយចំនួន ដូចជាថវិកាជាតិ ផែនការរដ្ឋ ការឱ្យគេខ្ចី ការខ្ចី ការធានាហិរញ្ញវត្ថុផ្សេងៗ ការបង្កើត ការកែប្រែ និងការលុបចោលពន្ធ គណនីរដ្ឋបាល ការលើកលែងទោស ការឱ្យសច្ចាប័ន ឬការលុបចោលសន្ធិសញ្ញា | | | |

| | | | | |
|---|---|---|---|---|
| | អន្តរជាតិ ឬអនុសញ្ញាអន្តរជាតិ និងច្បាប់ប្រកាសសង្គ្រាម | | | |
| ៣ | ច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់វិសោធនកម្មរដ្ឋធម្មនុញ្ញ | ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី និងប្រធានរដ្ឋសភាតាមសំណើ ១/៤ នៃសមាជិករដ្ឋសភា | លើសពី ២/៣ នៃចំនួនសមាជិកទាំងមូល | មតិភាគច្រើន ២/៣ នៃចំនួនសមាជិករដ្ឋសភាទាំងមូល |
| ៤ | ការលើកអភ័យឯកសិទ្ធិសភា | សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា | លើសពី ២/៣ នៃចំនួនសមាជិករដ្ឋសភា ឬសមាជិកព្រឹទ្ធសភាទាំងមូល | មតិភាគច្រើន ២/៣ នៃចំនួនសមាជិកទាំងមូល |

### ១.២.២. ការចាត់ទុកជាការប្រញាប់

ចំពោះពាក្យថា " បើជាការប្រញាប់ " ត្រូវពិនិត្យទៅតាម៤ ករណីគឺ ៖

ករណីទី១ : ក្នុងអត្ថបទនៃសេចក្តីព្រាងច្បាប់មានមាត្រាណាមួយចែងថា "ច្បាប់នេះ ត្រូវចាត់ទុកជាការប្រញាប់"។ ការប្រញាប់នេះ គឺសំដៅទៅលើ " ការប្រញាប់ក្នុងការអនុវត្តច្បាប់ " ពីព្រោះជាខ្លឹមសារនៃសេចក្តីដែលមានចែងក្នុងច្បាប់តែម្តង ដើម្បីតម្រូវការអនុវត្តឱ្យស្របនឹងមាត្រា៩៣ថ្មី វាក្យខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ។ ដូច្នេះព្រឹទ្ធសភាមានរយៈពេលធម្មតាសម្រាប់ពិនិត្យ និងឱ្យយោបល់ (មួយខែ)។

ករណីទី២ : មានលិខិតផ្លូវការរបស់រាជរដ្ឋាភិបាល ឬ ម្ចាស់អត្ថបទនៃសេចក្តីព្រាងច្បាប់ សុំឱ្យរដ្ឋសភាពិនិត្យសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់នោះជាការប្រញាប់។ ក្នុងករណីនេះ រដ្ឋសភាត្រូវសម្រេចពីពាក្យសុំនោះ។ ក្រោយពីបានអនុម័តយល់ព្រមលើកដំបូងហើយ រដ្ឋសភាបញ្ជូនមកព្រឹទ្ធសភា ដើម្បីពិនិត្យ និងឱ្យយោបល់ដូចមានចែងក្នុងមាត្រា១១៣ថ្មី វាក្យខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ។ បើគ្មានពាក្យសុំពីរដ្ឋសភាថា ជាការប្រញាប់ទេនោះ ព្រឹទ្ធសភាមានរយៈពេលធម្មតា គឺមួយខែ។

ករណីទី៣ ៖ មានការស្នើសុំពីរដ្ឋសភាឱ្យព្រឹទ្ធសភាពិនិត្យជាការប្រញាប់។ ព្រឹទ្ធសភាមានសិទ្ធិសម្រេចលើពាក្យសុំនេះ ។ បើព្រឹទ្ធសភាសម្រេចថា គួរទុកជាការប្រញាប់ នោះព្រឹទ្ធសភាត្រូវអនុវត្តតាមប្រការ៣៧ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គឺត្រូវចុះអត្ថបទនៃសេចក្តីព្រាងច្បាប់នេះ ទៅក្នុងរបៀបវារៈពិភាក្សាមុនគេ ហើយត្រូវពិនិត្យ និងឱ្យយោបល់ក្នុងរយៈពេលប្រាំថ្ងៃ។ ប៉ុន្តែបើព្រឹទ្ធសភាយល់ថា មិនគួរទុកជាការប្រញាប់ទេនោះ ព្រឹទ្ធសភាមានរយៈពេលធម្មតាគឺមួយខែ។

ករណីទី៤ ៖ រាជរដ្ឋាភិបាល ឬម្ចាស់អត្ថបទនៃសេចក្តីព្រាងច្បាប់ ស្នើសុំឱ្យព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់ជាការប្រញាប់ នោះព្រឹទ្ធសភាត្រូវអនុវត្តនីតិវិធីដូចករណីទី៣ដែរ គឺព្រឹទ្ធសភាមានសិទ្ធិក្នុងការសម្រេចថា គួរយល់ព្រមតាមពាក្យសុំឬទេ? បើយល់ព្រមត្រូវពិនិត្យ និងឱ្យយោបល់ក្នុងរយៈពេលប្រាំថ្ងៃ ហើយបើមិនយល់ព្រម គឺមានរយៈពេលធម្មតាមួយខែដដែល។

## ១.៣. ខ្លឹមសារ និងទម្រង់នៃសេចក្តីស្នើច្បាប់ផ្តួចផ្តើមដោយសមាជិករដ្ឋសភា ឬសមាជិកព្រឹទ្ធសភា

យោងតាមសេចក្តីសម្រេចលេខ ១៥៥/០០៣/២០១៥ កបធ.ច ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ របស់ក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយមាត្រា៩១ ថ្មី នៃរដ្ឋធម្មនុញ្ញ ស្របតាមសំណើរបស់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ដែលមានអត្ថន័យដូចខាងក្រោម ៖

«សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់។

សមាជិករដ្ឋសភាមានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់ ប៉ុន្តែសេចក្តីស្នើច្បាប់នេះ មិនអាចទទួលយកបានឡើយ ប្រសិនបើសេចក្តីស្នើនោះមានគោលដៅកាត់បន្ថយចំណូលសាធារណៈ ឬដាក់បន្ទុកមកលើប្រជាពលរដ្ឋ។»

វាក្យខណ្ឌទី១ នៃមាត្រា៩១ថ្មី កំណត់អំពីសិទ្ធិរបស់សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រីក្នុងការផ្តួចផ្តើមធ្វើច្បាប់។ វាក្យខណ្ឌនេះមានន័យថា ៖

- *សមាជិកព្រឹទ្ធសភាមួយរូប ឬច្រើនរូប* មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ និងមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន។
- *សមាជិករដ្ឋសភាមួយរូប ឬច្រើនរូប* មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ និងមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន។

- ***ទាំងសមាជិកព្រឹទ្ធសភា និងសមាជិករដ្ឋសភា*** មានសិទ្ធិរួមគ្នាផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ ឬមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន។

ការផ្តួចផ្តើមធ្វើច្បាប់ និងការផ្តួចផ្តើមធ្វើសេចក្តីស្នើវិសោធនកម្មច្បាប់ ដែលកំពុងនៅជាធរមាន ពីសំណាក់សមាជិកព្រឹទ្ធសភា ឬពីសមាជិករដ្ឋសភា ឬពីសមាជិកព្រឹទ្ធសភា និងសមាជិករដ្ឋសភារួមគ្នាជាហត្ថលេខី ត្រូវសរសេរជាសេចក្តីស្នើច្បាប់ និងត្រូវបំពេញទម្រង់បែបបទទៅតាមនីតិវិធីនៃការធ្វើច្បាប់។

- នាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមធ្វើសេចក្តីព្រាងច្បាប់ និងផ្តួចផ្តើមធ្វើសេចក្តីព្រាងវិសោធនកម្មច្បាប់ដែលមានជាធរមាន។ នាយករដ្ឋមន្ត្រីត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្របទៅតាមទម្រង់នៃនីតិវិធីធ្វើច្បាប់។

វាក្យខ័ណ្ឌទី២ នៃមាត្រា៩១ថ្មី មានន័យថា ការបញ្ជាក់បន្ថែមចំពោះអត្ថន័យនៃវាក្យខ័ណ្ឌដំបូងដោយមិនអនុញ្ញាតឱ្យសមាជិករដ្ឋសភាស្នើវិសោធនកម្មចំពោះច្បាប់ជាធរមានដែលមានគោលដៅកាត់បន្ថយចំណូលសាធារណៈ ឬដាក់បន្ទុកមកលើប្រជាពលរដ្ឋ។

### ក. ដំណើរការនៃការរៀបចំសេចក្តីស្នើច្បាប់

ជាទូទៅ ការរៀបចំសេចក្តីស្នើច្បាប់មុនពេលអនុម័តដោយគណៈកម្មាធិការអចិន្ត្រៃយ៍សភា សេចក្តីស្នើច្បាប់នោះត្រូវបញ្ជូនទៅ «ក្រុមការងារបច្ចេកទេសនៃអគ្គលេខាធិការដ្ឋានសភា» ដើម្បីធ្វើការងារជាមួយ «អ្នកជំនាញ» ដោយចែកចេញជាពីរដំណាក់កាលដូចខាងក្រោម ៖

#### ក១.សេចក្តីព្រាងដើម (ដំណាក់កាលទី១)

សេចក្តីព្រាងដើមនៅដំណាក់កាលដំបូងត្រូវសរសេរនៅលើក្រដាសស ដោយម្ចាស់សេចក្តីស្នើដែលអាចជា អ្នកជំនាញ សមាជិករដ្ឋសភាមួយរូបឬច្រើនរូប ឬសមាជិកព្រឹទ្ធសភាមួយឬច្រើនរូប។ នៅទំព័រមុខ ឬក្បាលទំព័រត្រូវបានសរសេរ ឬត្រូវបានរៀបរៀងដោយឈ្មោះរបស់អ្នកនិពន្ធ។

ចំពោះសេចក្តីព្រាងដើមនៃសេចក្តីស្នើច្បាប់ កើតចេញមកពីគំនិតដំបូងរបស់អ្នកនិពន្ធដែលគាត់មានវិធីសាស្ត្រផ្សេងគ្នាដើម្បីប្រមូលព័ត៌មានមកពីប្រភពខាងក្រៅ។

មធ្យោបាយមួយទៀតក្នុងការរៀបចំសេចក្តីព្រាងដើមគឺមកពី ក្រុមការងារមួយក្រុមដែលមានទៅដោយបញ្ញវន្ត អ្នកអនុវត្តច្បាប់ ឬមានបទពិសោធន៍ច្រើនលើកិច្ចការច្បាប់។

### ក.២.សេចក្ដីព្រាងដើម (ដំណាក់កាលទី២)

គណៈកម្មការពិសេស ឬគណៈកម្មការចំពោះកិច្ច ក្នុងក្របខ័ណ្ឌសភាដែលមានមុខងារផ្ដាច់មុខក្នុងការរៀបចំសេចក្ដីស្នើច្បាប់ណាមួយ គណៈកម្មការនេះ ត្រូវចាត់តាំងក្រុមអ្នកជំនាញមួយក្រុមដើម្បីជួយការងាររបស់ខ្លួនក្នុងដំណើរការសរសេរអត្ថបទព្រាង។

ក្រុមការងារបច្ចេកទេសខាងលើ អាចជួយគណៈកម្មការចំពោះកិច្ច ដើម្បីរៀបចំនូវកិច្ចពិគ្រោះយោបល់ជាសាធារណៈជាមួយដៃគូពាក់ព័ន្ធនានាដូចជា វិស័យឯកជន និងអាជ្ញាធរសាធារណៈដោយមានកិច្ចពិភាក្សាអំពីទិដ្ឋភាពសេដ្ឋកិច្ច សង្គម វប្បធម៌ និងនយោបាយ ដើម្បីឱ្យក្រុមការងារអាចប្រមូលបាននូវទិន្នន័យ និងព័ត៌មានពីគ្រប់មជ្ឈដ្ឋាន។ បន្ទាប់មក ត្រូវរៀបចំរបាយការណ៍មួយដែលលើកឡើងអំពីមតិយោបល់របស់អ្នកចូលរួម និងបញ្ជាក់អំពីការខ្វែងគំនិតគ្នាជាដើម។

### ក.៣.ការរៀបចំកំណត់ហេតុសង្ខេប ឬរបាយការណ៍

ជាធម្មតា ក្រុមការងារបច្ចេកទេសត្រូវសរសេររបាយការណ៍ ឬកំណត់ហេតុសង្ខេបដោយភ្ជាប់មកជាមួយសេចក្ដីស្នើច្បាប់ ដោយលើកឡើងអំពីគំនិតសំខាន់ៗ ពន្យល់អំពីមូលហេតុ និងសារៈសំខាន់នៃសេចក្ដីស្នើច្បាប់។

### ក.៤.ការរៀបចំកំណត់ពន្យល់ ឬសេចក្ដីថ្លែងហេតុ

កំណត់ពន្យល់ត្រូវភ្ជាប់មកជាមួយសេចក្ដីស្នើច្បាប់ និងលិខិតផ្លូវការមួយដែលត្រូវដាក់បញ្ជូនទៅគណៈកម្មការពិសេសសម្រាប់បំពេញបែបបទផ្សេងៗ។ កំណត់ពន្យល់ ឬសេចក្ដីថ្លែងហេតុ ត្រូវសរសេរដោយមានអត្ថន័យច្បាស់លាស់ ចំៗបញ្ហា ងាយយល់ដោយផ្ដោតទៅលើ ៖

- កម្មវត្ថុ និងគោលបំណងនៃសេចក្ដីស្នើច្បាប់ដោយពន្យល់លម្អិតអំពីខ្លឹមសារសំខាន់ៗ និងផលប្រយោជន៍ដែលបានមកពីច្បាប់នេះ ឬមូលហេតុដែលធ្វើឱ្យមានច្បាប់នេះ
- ហេតុផល និងការវាយតម្លៃលើផលវិបាកដែលមាន
- ខ្លឹមសារនៃសេចក្ដីស្នើច្បាប់ស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ឆ្លុះបញ្ចាំងអំពីកម្មវិធីនយោបាយ និងឆ្លើយតបនឹងបញ្ហាបច្ចុប្បន្នភាពរបស់ប្រទេសជាតិ
- ការសង្ខេបតាមជំពូក ជាពិសេសបទប្បញ្ញត្តិចែងអំពីការដាក់ទោសនៅក្នុងសេចក្ដីស្នើច្បាប់។

ចុងក្រោយ លិខិតផ្លូវការមួយត្រូវចុះហត្ថលេខាដោយប្រធានព្រឹទ្ធសភា (សម្រាប់សេចក្តីស្នើដោយព្រឹទ្ធសភា) នឹងត្រូវបញ្ជូនទៅប្រធានរដ្ឋសភាដើម្បីសុំការអនុម័ត។ លិខិតផ្លូវការនេះ ភ្ជាប់មកជាមួយនូវសេចក្តីថ្លែងហេតុ និងអត្ថបទនៃសេចក្តីស្នើច្បាប់។

## ខ. ទម្រង់នៃសេចក្តីស្នើច្បាប់

### ខ១. ក្របសន្លឹកទំព័រដំបូង

- ត្រូវដាក់ឆ្លងអង្គប្រជុំក្រុមការងារបច្ចេកទេសរបស់ អ. ពស/អ.រស
- នៅចំកណ្តាលសន្លឹកទំព័រត្រូវដាក់ពាក្យ «សេចក្តីស្នើ» ក្រោមពាក្យស្នើ ចំកណ្តាលដាក់ពាក្យ «ច្បាប់» ក្រោមពាក្យច្បាប់ ដាក់ពាក្យស្តីពី «ចំណងជើងនៃសេចក្តីស្នើច្បាប់»
- ប៉ែកខាងក្រោមនៃទំព័រត្រូវដាក់កាលបរិច្ឆេទក្រោយបង្អស់ ដែលក្រុមការងារបច្ចេកទេសបានប្រជុំសម្រេច និងរៀបចំផ្ញើទៅអនុគណៈកម្មការសិក្សារៀបចំសេចក្តីស្នើច្បាប់។ សូមមើលគំរូទី១ ខាងក្រោម៖

គំរូទី១ ៖ ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីស្នើច្បាប់
ដែលត្រូវដាក់ឆ្លងអង្គប្រជុំក្រុមការងារបច្ចេកទេស អ.ពស/អ.រស

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមការងារបច្ចេកទេស

**សេចក្តីស្នើ**

**ច្បាប់**

**ស្តីពី**

[ចំណងជើងនៃសេចក្តីស្នើច្បាប់ជាអក្សរមូល]

**ថ្ងៃ.....ខែ.....ឆ្នាំ.....**

[កាលបរិច្ឆេទចុងក្រោយបង្អស់ដែលក្រុមការងារបច្ចេកទេសបានរៀបចំ]

បន្ទាប់មកត្រូវឆ្លងអង្គប្រជុំអនុគណៈកម្មការសិក្សា និងពិនិត្យ។ ប៉ែកខាងក្រោមនៃទំព័រត្រូវដាក់កាលបរិច្ឆេទក្រោយបង្អស់ដែលអនុគណៈកម្មការបានប្រជុំពិនិត្យ។ សូមមើលគំរូទី២ ខាងក្រោម ៖

គំរូទី២ ៖ ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្ដីស្នើច្បាប់ដែលត្រូវដាក់ឆ្លងអង្គប្រជុំ
អនុគណៈកម្មការសិក្សារៀបចំសេចក្ដីស្នើច្បាប់ដើម្បីផ្ញើទៅគណៈកម្មការពិសេស

| |
|---|
| **ព្រះរាជាណាចក្រកម្ពុជា**<br>**ជាតិ សាសនា ព្រះមហាក្សត្រ**<br>អនុគណៈកម្មការ<br><br>**សេចក្ដីស្នើ**<br>**ច្បាប់**<br>**ស្ដីពី**<br>[ចំណងជើងនៃសេចក្ដីស្នើច្បាប់ជាអក្សរមូល]<br><br>**ថ្ងៃ.....ខែ.....ឆ្នាំ.....**<br><br>[កាលបរិច្ឆេទចុងក្រោយបង្អស់ដែលអនុគណៈកម្មការបានពិនិត្យ] |

បន្ទាប់មកទៀតត្រូវឆ្លងអង្គប្រជុំអនុគណៈកម្មការសិក្សា និងពិនិត្យ។ ប៉ែកខាងក្រោមនៃទំព័រត្រូវដាក់កាលបរិច្ឆេទក្រោយបង្អស់ដែលអនុគណៈកម្មការបានប្រជុំពិនិត្យ។ សូមមើលគំរូទី៣ ខាងក្រោម ៖

គំរូទី៣ ៖ ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីស្នើច្បាប់ដែលត្រូវដាក់ឆ្លងអង្គប្រជុំគណៈកម្មការពិសេសរៀបចំសេចក្តីស្នើច្បាប់ដើម្បីផ្ញើទៅគណៈកម្មាធិការអចិន្ត្រៃយ៍ព.ស/រ.ស

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការពិសេស

**សេចក្តីស្នើ**

**ច្បាប់**

**ស្តីពី**

[ចំណងជើងនៃសេចក្តីស្នើច្បាប់ជាអក្សរមូល]

**ថ្ងៃ.....ខែ.....ឆ្នាំ.....**

[កាលបរិច្ឆេទចុងក្រោយបង្អស់ដែលទទួលបានការឯកភាពពីគណៈកម្មាធិការពិសេស]

ចុងក្រោយបង្អស់ ត្រូវឆ្លងអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដើម្បីពិនិត្យសម្រេច និងបញ្ជូនទៅរដ្ឋសភា ។ ប៉ែកខាងក្រោមនៃទំព័រត្រូវដាក់កាលបរិច្ឆេទក្រោយបង្អស់ ដែលគណៈកម្មាធិការអចិន្ត្រៃយ៍បានពិនិត្យ និងសម្រេច។ សូមមើលគំរូទី៤ ខាងក្រោម ៖

គំរូទី៤ ៖ ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីស្នើច្បាប់ដែលត្រូវដាក់ឆ្លងអង្គប្រជុំ
គណៈកម្មាធិការអេចិន្ត្រៃយ៍ ព.ស/រ.ស

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការអចិន្ត្រៃយ៍

# សេចក្តីស្នើ

# ច្បាប់

# ស្តីពី

[ចំណងជើងនៃសេចក្តីស្នើច្បាប់ជាអក្សរមូល]

**ថ្ងៃ.....ខែ.....ឆ្នាំ.....**

[កាលបរិច្ឆេទចុងក្រោយបង្អស់ដែលទទួលបានការឯកភាពពីគណៈកម្មាធិការអចិន្ត្រៃយ៍]

## ១២. សន្លឹកទំព័របន្តបន្ទាប់

ជាទូទៅ ម្ចាស់សេចក្តីស្នើច្បាប់ត្រូវតាក់តែងសេចក្តី ដោយរៀបចំអត្ថបទជាជំពូក និងជាមាត្រា។ ជំពូកត្រូវដាក់នៅចំកណ្តាលទំព័រ និងមានដាក់ចំណងជើងនៅចំកណ្តាល។ ចំណែកនៅតាមមាត្រានីមួយៗ ជាធម្មតាមិនមានចំណងជើងទេ ប៉ុន្តែក្នុងករណីចាំបាច់ អាចដាក់ចំណងជើងបានចំពោះតែកម្រងច្បាប់ធំៗ ដូចជាក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌជាដើម។

ឧទាហរណ៍ ៖ ជំពូកទី១

ចំពោះមាត្រា ត្រូវចាប់ផ្តើមសរសេរឃ្លាតពីរឹមទំព័រខាងឆ្វេង ដោយដាក់លេខនៅក្រោយពាក្យមាត្រា ហើយមិនប្រើពាក្យ ទី នៅចន្លោះមាត្រានិងលេខឡើយ។

ឧទាហរណ៍ ៖ **មាត្រា១.-** ។

## ១៣.ជំពូក

ជំពូកទី១ ចែង បទប្បញ្ញត្តិទូទៅ

ក្នុងជំពូកនេះត្រូវចែងពីគោលបំណង និងវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិដែល មានអនុភាពប្រើរួមសម្រាប់ច្បាប់ទាំងមូល ហើយអាចមាននិយមន័យផងដែរ។ គោលបំណង និងវិសាលភាពនៃច្បាប់ ត្រូវចែងជាបន្តបន្ទាប់នៅក្នុងមាត្រា១ និងមាត្រា២ ប្រសិនបើមាននិយមន័យនៃបច្ចេកសព្ទ ឬវាក្យសព្ទសំខាន់ៗ និយមន័យនោះត្រូវចែងនៅក្នុងមាត្រា៣ ឬនៅក្នុងសន្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់។

ជំពូកទី២ (ចំណងជើង) និង ជំពូក បន្តបន្ទាប់

ជំពូកទី២ និងជំពូកបន្តបន្ទាប់អាចចែកជាផ្នែក ហើយត្រូវចែងពីខ្លឹមសារពិស្តារទាំងឡាយដែលមានគោលដៅដាក់បញ្ញត្តិដើម្បីឱ្យអនុវត្ត ហើយត្រូវចែងលម្អិតតាមផ្នែកដោយឡែកៗដែលច្បាប់ត្រូវបញ្ញត្ត។

ជំពូកទី... ចែង ទោសប្បញ្ញត្តិ

ក្នុងជំពូកនេះ ត្រូវចែងពីទោស ស្ថានទម្ងន់ទោស ស្ថានសម្រាលទោស និងការផាកពិន័យទាំងឡាយចំពោះអំពើប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិដែលបានដាក់នៅក្នុងច្បាប់។ ការចែងពីទោសប្បញ្ញត្តិ ដែលពាក់ព័ន្ធនឹងមាត្រាណាមួយត្រូវយោងទៅលេខមាត្រានោះឱ្យច្បាស់ចំៗតែម្តង។

ជំពូកទី... ចែង អន្តរប្បញ្ញត្តិ (ប្រសិនបើមាន)

ក្នុងជំពូកនេះអាចចែងបានចំពោះតែករណីដែលកំណត់រយៈពេលមួយជាកំណត់សម្រាប់ផ្តល់នូវលទ្ធភាពឱ្យបំពេញបែបបទអន្តរកាល ដើម្បីសម្រួលការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ថ្មីដែលចូលជាធរមានជំនួសច្បាប់ ឬបទប្បញ្ញត្តិនៃច្បាប់ចាស់ដែលពាក់ព័ន្ធ។ ប្រសិនបើមានបដិប្បញ្ញត្តិ (បទបញ្ញត្តិផ្ទុយ) ត្រូវរៀបចំក្នុងជំពូកនេះដែរ។

ជំពូកទី... ចែង អវសានប្បញ្ញត្តិ

ក្នុងជំពូកនេះមានតែមួយ ឬពីរមាត្រាយ៉ាងច្រើន ដែលក្នុងនោះអាចមានមាត្រាមួយដែលចែងថា «បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍» និងអាចមានមាត្រាមួយទៀតដែលចែងថា «ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់» ចំពោះតែករណីច្បាប់ណាដែលត្រូវ អនុវត្តជាប្រញាប់តែប៉ុណ្ណោះ។

ត្រង់ប៉ែកខាងស្តាំ ១ភាគ៣នៃទំព័រចុងក្រោយបង្អស់នៃអត្ថបទ ត្រូវសរសេរដូចខាងក្រោម ៖

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ..... ខែ .... ឆ្នាំ ......... នាសម័យប្រជុំរដ្ឋសភា
លើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី ... ។
រាជធានីភ្នំពេញថ្ងៃទី ..... ខែ ..... ឆ្នាំ .....
ប្រធានរដ្ឋសភា

**២៤.មាត្រា**

មាត្រាត្រូវដាក់លេខរៀងតាមលំដាប់លំដោយ ដោយចាប់ផ្តើមពីមាត្រា១ នៃសេចក្តីស្នើច្បាប់នោះ។ នៅក្រោយលេខមាត្រា ត្រូវចុចរួចគូសគំនូដូចក្នុងវង់ក្រចកនេះ (មាត្រា១.-) មិនត្រូវប្រើសញ្ញាចំណុចពីរ (:) ទេ។

ការតែងសេចក្តីនៅតាមមាត្រានីមួយៗ ត្រូវផ្តើមល្បះដោយចុះបន្ទាត់មកក្រោមលេខមាត្រា ហើយសរសេរស្មើនឹងដើមលេខនៃមាត្រានោះ។ ពេលសរសេរមិនអស់ចូលដល់បន្ទាត់ទី២ ត្រូវចាប់ផ្តើមសរសេរល្បះបន្តស្មើនឹងដើមពាក្យមាត្រា។

## ២៥.ឧបសម្ព័ន្ធ

- លិខិតផ្លូវការចុះហត្ថលេខាដោយប្រធានព្រឹទ្ធសភាផ្ញើជូនប្រធានរដ្ឋសភា
- លិខិតស្នើសុំរបស់តំណាងសមាជិកព្រឹទ្ធសភាហត្ថលេខី
- បញ្ជីឈ្មោះសមាជិកព្រឹទ្ធសភា និងហត្ថលេខា
- កំណត់ពន្យល់ ឬសេចក្តីថ្លែងហេតុនៃសេចក្តីស្នើច្បាប់
- អត្ថបទព្រាងនៃសេចក្តីស្នើច្បាប់ ។

សូមមើលគំរូទី៥ នៅទំព័រខាងក្រោម ។

សូមមើលគំរូទី៦ នៅទំព័រខាងក្រោម ដែលបង្ហាញអំពីសេចក្តីស្នើច្បាប់ដែលស្នើដោយគណៈកម្មការសភា និងសំណើវិសោធនកម្មច្បាប់ដែលស្នើដោយសមាជិកសភានីមួយៗ។

គំរូទី៥ ៖ ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីស្នើច្បាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

……………………………………………………………………………………………………។

## ជំពូកទី២ និង ជំពូក បន្តបន្ទាប់

(ចំណងជើងជំពូក)

**មាត្រា.-**

……………………………………………………………………………………………………។

## ជំពូកទី...
## ទោសប្បញ្ញត្តិ

**មាត្រា.-**

……………………………………………………………………………………………………។

## ជំពូកទី...
## អន្តរប្បញ្ញត្តិ (ប្រសិនបើមាន)

**មាត្រា.-**

……………………………………………………………………………………………………។

## ជំពូកទី...
## អវសានប្បញ្ញត្តិ

**មាត្រា.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ (ក្នុងករណីដែលច្បាប់ត្រូវអនុវត្តជាប្រញាប់)។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ..... ខែ .... ឆ្នាំ ......... នាសម័យប្រជុំរដ្ឋសភា
លើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី ... ។
រាជធានីភ្នំពេញថ្ងៃទី ..... ខែ ..... ឆ្នាំ .....

**ប្រធានរដ្ឋសភា**

គំរូទី៦ ៖ ទម្រង់នៃសេចក្តីស្នើវិសោធនកម្មរបស់សមាជិកសភា

# សេចក្តីស្នើច្បាប់

**ព្រឹទ្ធសភា/រដ្ឋសភា**

**គណៈកម្មការ...**

(**លេខ**........)

**០១ មករា ២០១៩**

## សំណើវិសោធនកម្ម

## ស្នើដោយ

## ឯកឧត្តម លោកជំទាវ .................................... សមាជិករដ្ឋសភា / សមាជិកព្រឹទ្ធសភា (មណ្ឌល/ភូមិភាគ)

## មាត្រា៣

បន្ទាប់ពីពាក្យ ៖ .... នៃក្រមបរិស្ថាន

ដាក់បញ្ចូលពាក្យ ៖ ..... និងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធដទៃទៀត ។

## មូលហេតុ

សេចក្តីស្នើវិសោធនកម្មអាចជាប់ពាក់ព័ន្ធនឹងច្បាប់ និងលិខិតបទដ្ឋានជាច្រើនទៀត នៅពេលដែលក្រមបរិស្ថាននេះចូលជាធរមាន នឹងអាចបង្កឱ្យមានផលប៉ះពាល់វិជ្ជមាន ឬអវិជ្ជមានដល់ប្រជា ពលរដ្ឋដែលមានទីតាំងនៅក្បែរតំបន់ដែលមានគម្រោងអភិវឌ្ឍន៍គ្រប់គ្រងដោយរាជរដ្ឋាភិបាល។

## ២. បទប្បញ្ញត្តិហាមឃាត់

ជាគោលការណ៍នាយករដ្ឋមន្ត្រី សមាជិករដ្ឋសភា ឬសមាជិកព្រឹទ្ធសភា ១រូប ឬច្រើនរូប មានសិទ្ធិក្នុងការផ្តួចផ្តើមធ្វើច្បាប់ និងវិសោធនកម្មលើច្បាប់ជាធរមាន ក៏ប៉ុន្តែ សិទ្ធិផ្តួចផ្តើម និងសំណើធ្វើច្បាប់ទាំងនោះ មិនត្រូវប៉ះពាល់ដល់ការហាមឃាត់របស់រដ្ឋធម្មនុញ្ញ និងការកាត់បន្ថយចំណូលសាធារណៈ ឬការដាក់បន្ទុកលើប្រជាពលរដ្ឋជាដាច់ខាត។

**ការហាមឃាត់របស់រដ្ឋធម្មនុញ្ញ ៖** ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ ត្រូវចាត់ទុកជាអសារសូន្យ។[24] លើសពីនេះ ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយកាលបើធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និងរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។[25] ម្យ៉ាងទៀត បើប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ការសើរើ ឬការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ក៏មិនត្រូវបានអនុញ្ញាតផងដែរ។[26]

ចំពោះការស្នើធ្វើវិសោធនកម្មច្បាប់របស់តំណាងរាស្ត្រ និង/ឬសមាជិកព្រឹទ្ធសភា ក៏មិនអាចធ្វើទៅបានដែរ កាលបើការធ្វើវិសោធនកម្មនោះសំដៅកាត់បន្ថយចំណូលសាធារណៈ ឬបន្ថែមបន្ទុកមកលើប្រជាពលរដ្ឋ។[27]

[24] រដ្ឋធម្មនុញ្ញ មាត្រា៩២

[25] រដ្ឋធម្មនុញ្ញ មាត្រា១៥៥ ថ្មី (ពីរ)

[26] រដ្ឋធម្មនុញ្ញ មាត្រា១៥៤ ថ្មី (ពីរ)

[27] រដ្ឋធម្មនុញ្ញ មាត្រា៩១ ថ្មី

# ៣. គោលការណ៍ និងទ្រឹស្តីនៃការធ្វើច្បាប់ឱ្យបានល្អ

## ៣. ១. សមាសធាតុនៃការធ្វើច្បាប់ឱ្យបានល្អ

រដ្ឋាភិបាល និងស្ថាប័នផ្សេងៗគ្នានៅលើពិភពលោក មានលក្ខណៈវិនិច្ឆ័យគុណភាពខុសគ្នាចំពោះការធ្វើច្បាប់។ ស្ថាប័នមួយអាចវិនិច្ឆ័យនូវគុណភាពនៃច្បាប់មួយដោយមើលជារួមទៅលើការជះឥទ្ធិពលជាទូទៅ រួមមាន កម្រិតនៃការប្រព្រឹត្តតាមនៅក្នុងសង្គម។ ការប្រព្រឹត្តតាមគឺទទួលជោគជ័យប្រសិនបើមនុស្សនៅក្នុងសង្គមអនុវត្តតាមវិធានទាំងឡាយដែលត្រូវបានអនុម័ត។ ដូច្នេះ ច្បាប់មួយល្អនៅពេលដែលមនុស្សផ្លាស់ប្តូរអាកប្បកិរិយារបស់ខ្លួន និងប្រព្រឹត្តតាមទាំងអស់គ្នា គឺទទួលជោគជ័យ (Hauerstein, 2016)។ យោងតាម Xantaki (2014) គុណភាពនៃបទប្បញ្ញត្តិអាចត្រូវបានធានានៅពេលដែលគោលដៅតូចៗ ទាំងឡាយមួយចំនួនត្រូវតែធ្វើឱ្យបានជោគជ័យ។ រូបភាពខាងក្រោមនេះចង្អុលបង្ហាញអំពីលំដាប់លំដោយឋានានុក្រមដើម្បីសម្រេចបាននូវច្បាប់ល្អ។




**ប្រភព ៖** Helen Xantaki, ការព្រាងច្បាប់ សិល្បៈ និងបច្ចេកវិទ្យានៃវិធានសម្រាប់ធ្វើច្បាប់

### ៣.១.១ ប្រសិទ្ធភាព

លក្ខណៈវិនិច្ឆ័យគុណភាពសំខាន់បំផុតដែលយើងស្វែងរកទូទាំងពិភពលោកគឺ ប្រសិទ្ធភាព។ ប្រសិទ្ធភាពឆ្លុះបញ្ចាំងនូវការលោតសន្ទឹងដែលច្បាប់រៀបចំយន្តការគ្រប់គ្រាន់ដើម្បីសម្រេចកម្មវត្ថុដែលចង់បាន និងដោះស្រាយបញ្ហាចម្បងៗនានា។

### ៣.១.២. ប្រសិទ្ធផល

ប្រសិទ្ធផល គឺជាមធ្យោបាយមួយដើម្បីសម្រេចបាននូវប្រសិទ្ធភាព។ ប្រសិទ្ធផលអាចទទួលបានជោគជ័យតាមរយៈការប្រើប្រាស់ដើមទន់តិចដើម្បីសម្រេចបាននូវជោគជ័យច្រើន។

### ៣.១.៣. សេចក្ដីច្បាស់លាស់ ភាពជាក់លាក់ មិនស្រពេចស្រពិល

ប្រសិទ្ធភាព ក៏អាចទទួលជោគជ័យបានដោយសេចក្ដីច្បាស់លាស់។ ភាពជាក់លាក់គឺជាគុណភាពនៃការមើលឃើញ និងការងាយយល់។ មិនស្រពេចស្រពិល គឺភាពពិតប្រាកដ ឬអត្ថន័យពិត។ លក្ខណៈវិនិច្ឆ័យគុណភាពទាំងនេះផ្ដល់នូវការព្យាករទុកបានចំពោះច្បាប់ ដែលធ្វើឱ្យអ្នកប្រើប្រាស់ច្បាប់រួមទាំងអ្នកអនុវត្តធ្វើឱ្យស៊ីជម្រៅនូវខ្លឹមសារនៃច្បាប់។ ទាំងនេះ គឺជាអ្វីដែលត្រូវការទុកមុន ដ៏មានសារៈសំខាន់សម្រាប់ការប្រព្រឹត្តតាម។

### ៣.១.៤ ការប្រើភាសាងាយយល់ និងការប្រើភាសាអព្យាក្រឹត្យយេនឌ័រ

ការសម្រេចបាននូវការប្រើភាសាងាយយល់ និងការប្រើភាសាអព្យាក្រឹត្យខាងយេនឌ័រក្នុងការរៀបចំសេចក្ដីព្រាងច្បាប់ អាស្រ័យលើគោលការណ៍នានាដែលត្រូវបានកែលម្អធ្វើឱ្យការប្រើភាសាងាយស្រួលគឺដើម្បីធានាថា អ្នកនៅជុំវិញអាចយល់បាននូវអត្ថបទ។ ការប្រើភាសាអព្យាក្រឹត្យខាងយេនឌ័រ គឺជាឧបករណ៍ម្យ៉ាងទៀតសម្រាប់ភាពត្រឹមត្រូវខាងយេនឌ័រ។ ខណៈដែលឧបករណ៍នេះលើកកម្ពស់នូវយថាប្រភេទយេនឌ័រនៅក្នុងការធ្វើពង្រាង។ ការប្រើភាសាងាយយល់ និងការប្រើភាសាអព្យាក្រឹត្យខាងយេនឌ័រគឺជាបញ្ហាមួយទៀតដែលគួរយកមកពិចារណា។

## ៣.២. ការវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA)

រដ្ឋាភិបាលត្រូវការធ្វើការវាយតម្លៃដោយប្រយ័ត្នប្រយែងអំពីបន្ទុក និងផលប្រយោជន៍នៃការដាក់បញ្ចូលបញ្ញត្តិកម្មថ្មី ដើម្បីកាត់បន្ថយផលអវិជ្ជមាននៃបញ្ញត្តិកម្មទាំងនោះ ដូចជាការរារាំងដល់ការប្រកួតប្រជែង ឬការដាក់បន្ទុកចំណាយធ្ងន់ធ្ងរទៅលើធុរកិច្ច ឬអ្នកដែលប្រតិបត្តិតាមបញ្ញត្តិកម្មនោះ ជាដើម។

របាយការណ៍ស្តីពីការធ្វើធុរកិច្ចឆ្នាំ២០១២ ចេញដោយធនាគារពិភពលោក បានចាត់ថ្នាក់ប្រទេសកម្ពុជានៅលេខរៀងទី១៣៨ ក្នុងចំណោមប្រទេសចំនួន១៨៣ ចំពោះភាពងាយស្រួលក្នុងការធ្វើធុរកិច្ច។ ប្រទេសកម្ពុជាមានចំណាត់ថ្នាក់ក្រោមប្រទេសអាស៊ានភាគច្រើន ដូចជា ប្រទេសម៉ាឡេស៊ី ថៃ វៀតណាម និងហ្វីលីពីន ។ បញ្ហានេះតម្រូវឱ្យកម្ពុជាបន្ថយបន្ទុកចំណាយធុរកិច្ច ។ ហេតុដូច្នេះ ការវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត អាចជាមធ្យោបាយមួយក្នុងការធ្វើឱ្យសម្រេចគោលបំណងនេះ។

ការវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត គឺជាទម្លាប់អនុវត្តល្អសម្រាប់ដំណើរការរៀបចំលិខិតបទដ្ឋានគតិយុត្តដែលផ្តល់ផលចំណេញច្រើន ហើយមានប្រទេសអភិវឌ្ឍន៍ជាច្រើនដែលជាសមាជិកនៃអង្គការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសហប្រតិបត្តិការ (OECD) បានទទួលស្គាល់យ៉ាងទូលំទូលាយអស់រយៈពេលជាច្រើនទស្សវត្សមកហើយ។

គោលការណ៍ណែនាំរបស់អាស៊ានស្តីពីទម្លាប់ល្អនៃការរៀបចំបញ្ញត្តិកម្ម អនុម័តដោយ 2/40 SEOM Meeting 2009 នៅទីក្រុងបាងកក និងកិច្ចប្រជុំជាច្រើនរបស់ ASEAN-OECD/APEC/New Zealand ស្តីពី Good Practice and Networking ឆ្នាំ២០១០ នៅទីក្រុងហាណូយ ឆ្នាំ២០១១ នៅទីក្រុងចាកាតា ឆ្នាំ២០១២ នៅទីក្រុងម៉ានីល ឆ្នាំ២០១៣ នៅទីក្រុងបាងកក ឆ្នាំ២០១៤ នៅទីក្រុងប៉េកាំង ឆ្នាំ២០១៥ នៅទីក្រុងគួឡាឡាំពួ ឆ្នាំ២០១៦ នៅទីក្រុងវៀងច័ន្ទ។

កម្ពុជាមិនមានការកំណត់ថេរវេលានៃការប្រើប្រាស់លិខិតបទដ្ឋានគតិយុត្តទេ ដូច្នេះ ទម្លាប់អនុវត្តល្អសម្រាប់ការរៀបចំលិខិតបទដ្ឋានគតិយុត្ត នឹងជួយឱ្យយើងអាចផលិតលិខិតបទដ្ឋានគតិយុត្ត បានកាន់តែប្រសើរ។

អភិបាលកិច្ចល្អគឺជាចំណុចនៃរបៀបវារៈរបស់រាជរដ្ឋាភិបាលដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ។ ដំណើរការ RIA នឹងអាចកាត់បន្ថយការិយាធិបតេយ្យ និងភាពច្រើនហួស ភាពជាន់គ្នានៃលិខិតបទដ្ឋានគតិយុត្ត។

RIA ត្រូវបានផ្តួចផ្តើមឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ស្ថិតនៅក្រោមគម្រោង CREST-Competition, Regulatory Impact Efficiency and SME Technology Project ដើម្បីគាំទ្រក្រសួងពាណិជ្ជកម្ម។ RIA ជាវិធីសាស្ត្រមួយជួយឱ្យសម្រេចតម្រូវការកាត់បន្ថយបន្ទុកចំណាយ កាតព្វកិច្ចរបស់ធុរកិច្ចនៅកម្ពុជា។

ឆ្នាំ២០០៨ ដំណើរការ RIA ត្រូវបានអនុវត្តសាកល្បងនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្ថិតក្រោមកម្មវិធីលើកកម្ពស់គុណភាពលិខិតបទដ្ឋានគតិយុត្ត ក្រោមជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ចាប់ពីឆ្នាំ២០១១ ដល់២០១៥ គម្រោងនេះ ត្រូវបានអនុវត្តដោយក្រុមសង្កេតការណ៍ សេដ្ឋកិច្ច សង្គម និងវប្បធម៌ (ECOSOCC) ដែលមានការចូលរួមអនុវត្តពីក្រសួងចំនួន៧ ដូចជា ក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ។ បន្ទាប់មក ការអនុវត្តកម្មវិធី RIA ថ្នាក់ជាតិ ឆ្នាំ២០១៦-២០១៧ ដែលសម្របសម្រួល និងដឹកនាំដោយក្រុមសង្កេតការណ៍សេដ្ឋកិច្ច និងសង្គម មានការចូលរួមអនុវត្តពីក្រសួងចំនួន៦ ថែមទៀត ក្នុងឆ្នាំ២០១៦ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងក្រសួងថ្មីចំនួន ៦ ទៀត ក្នុង ឆ្នាំ២០១៧។

គម្រោង RIA នៅកម្ពុជាសំដៅពង្រឹងការប្រកួតប្រជែង និងប្រសិទ្ធភាពនៃបញ្ញត្តិកម្ម តាមរយៈការស្ថាបនានូវ គោលការណ៍ប្រតិបត្តិល្អសម្រាប់រៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តនៅតាមក្រសួងស្ថាប័ននានានៃរាជរដ្ឋាភិបាល។ ប្រព័ន្ធ RIA តម្រូវឱ្យក្រសួងនីមួយអនុវត្តតាមគោលការណ៍ប្រតិបត្តិល្អ និងវាយតម្លៃលើគុណសម្បត្តិនៃបទប្បញ្ញត្តិដែលមានផលប៉ះពាល់ដល់បន្ទុកចំណាយកាតព្វកិច្ច និងការប្រកួតប្រជែងរបស់ធុរកិច្ច។

គម្រោងនេះ បានបង្កើតនូវក្រុមការងារវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត (Office of RIA-ORIA ឬ Executing Agency-EA) នៅក្នុងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីផ្តល់ការណែនាំអំពីគោលការណ៍ប្រតិបត្តិល្អ ក្នុងការរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្ត ការបណ្តុះបណ្តាលអំពី RIA និងការគាំទ្រក្នុងការអនុវត្ត RIA ដល់ក្រសួងស្ថាប័នពាក់ព័ន្ធ និងទទួលគ្រប់គ្រងដំណើរការនៃគម្រោងទាំងមូល។

គម្រោងនេះត្រូវបានចាប់ផ្តើមដំណើរការដំបូងជាមួយក្រសួងដែលជាទីភ្នាក់ងារអនុវត្តគម្រោង (Implement Agency-IA) រួមមាន ក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងទេសចរណ៍ ដើម្បីពិសោធអនុវត្តវិធីសាស្ត្រ RIA ក្នុងអំឡុងវគ្គបណ្តុះបណ្តាលនៃគម្រោងសម្រាប់រៀបចំតាក់តែងសំណើ បញ្ញត្តិកម្មដូចបានកំណត់នៅក្នុងផែនការសកម្មភាពដែលភ្នាក់ងារអនុវត្តនីមួយៗបានលើកឡើងក្នុងអំឡុងចាប់ផ្តើមគម្រោងក្នុងឆ្នាំ២០១១។

ECOSOCC និង ADB បានធ្វើការផ្សព្វផ្សាយគម្រោង RIA នៅតាមក្រសួងស្ថាប័ន សាកលវិទ្យាល័យនានា អគ្គលេខាធិការដ្ឋានរដ្ឋសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជាមួយវិស័យឯកជន និងសង្គមស៊ីវិល បានជាច្រើនលើក មានអ្នកចូលរួមចំនួនរាប់ពាន់នាក់ ដែលអ្នកទាំងអស់បានគាំទ្រយ៉ាងខ្លាំងដល់វិធីសាស្ត្រ RIA និងចង់បាន RIA អនុវត្តនៅប្រទេសកម្ពុជា។

តើអ្វីទៅជាការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត?

គោលបំណងនៃ RIA គឺដើម្បីកែលម្អបច្ចេកទេសនៃការធ្វើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងប្រទេសកម្ពុជា ដោយធានាថា ៖

- ជម្រើសនីមួយៗត្រូវបានយកមកពិចារណាដោយធានាបាននូវប្រសិទ្ធភាពរបស់បញ្ញត្តិកម្មដែលនឹងត្រូវបង្កើតឡើង
- បញ្ញត្តិកម្មមិនត្រូវបានធ្វើនៅពេលដែលវាបង្ហាញថា ជាជម្រើសមិនល្អ
- មានការពិគ្រោះយោបល់ជាសាធារណៈក្នុងកម្រិតទទួលយកបាន។

គោលការណ៍ចម្បងទាំងបី នឹងណែនាំអំពីការរៀបចំ RIA ៖

- ការកែលម្អព័ត៌មានសម្រាប់ថ្នាក់ដឹកនាំ ៖ RIA នឹងផ្តល់ព័ត៌មានស្តីពីបន្ទុកចំណាយ និងផលចំណេញនៃសំណើបញ្ញត្តិកម្ម និងជម្រើសដែលសម្រេចនូវគោលបំណងដូចគ្នាជូនថ្នាក់ដឹកនាំដើម្បីធ្វើសេចក្តីសម្រេចប្រកបដោយព័ត៌មានគ្រប់គ្រាន់
- ភាពងាយស្រួល ៖ ភាគច្រើននៃផលចំណេញនានារបស់ RIA អាចទទួលបានតាមរយៈការពិគ្រោះយោបល់ ហេតុផលសមរម្យ ការងាយស្រួលគណនា និងការសាកល្បងលើការសន្មត ជាជាងតាមរយៈការអនុវត្តបច្ចេកទេសស្មុគស្មាញ។ ដូច្នេះ RIA ដែលអនុវត្តនៅកម្ពុជានឹងភាពងាយស្រួលអនុវត្ត
- តម្លាភាព ៖ តម្លាភាពអាចធ្វើឱ្យមានការពិគ្រោះយោបល់បានត្រឹមត្រូវ និងអភិបាលកិច្ចល្អ ហើយសម្រេចបានដោយចំណាយតិច តាមរយៈការបង្ហោះព័ត៌មានលើគេហទំព័រ។ ដើម្បីជួយដល់អាជីវកម្មតូចៗដែលមិនមានលទ្ធភាពប្រើប្រាស់អ៊ិនធឺណិត ភាពងាយស្រួលមើលឯកសារសាធារណៈត្រូវបានរក្សាទុក ដើម្បីឱ្យភាគីពាក់ព័ន្ធអាចមើលឯកសារនោះ បាន។ ការកែលម្អតម្លាភាព នឹងជួយឱ្យសម្រេចគោលបំណងចុងក្រោយរបស់គម្រោង។

ប្រទេសនីមួយៗមានវិធីសាស្ត្រផ្ទាល់របស់គេ ចំពោះគោលការណ៍ RIA ក៏ប៉ុន្តែ សម្រាប់កម្ពុជាបានយកធាតុទាំង ៧ មកអនុវត្តសាកល្បង ៖

### ៣.២.១.បញ្ហា

- កំណត់បញ្ហាដែលតម្រូវឱ្យមានកិច្ចអន្តរាគមពីរាជរដ្ឋាភិបាល
- ពន្យល់ពីលក្ខណៈ ប្រភព និងទំហំនៃបញ្ហា និងរៀបរាប់ពីនរណាខ្លះដែលនឹងទទួលផលប៉ះពាល់
- ផ្តល់ភស្តុតាងជាក់លាក់ និងពន្យល់ថា ហេតុអ្វីបានជាលិខិតបទដ្ឋានដែលមានស្រាប់មិនអាចដោះស្រាយបាន។

### ៣.២.២.គោលបំណង

- កំណត់គោលបំណងនៃកិច្ចអន្តរាគមក្នុងការដោះស្រាយបញ្ហាដែលបានកំណត់
- បញ្ជាក់ពីគោលបំណងដែលជាលទ្ធផលចុងក្រោយប្រសើរជាជាងការបញ្ជាក់ពីមធ្យោបាយដើម្បីសម្រេចបានលទ្ធផល។

### ៣.២.៣.ជម្រើស

- កំណត់ជម្រើសដែលដោះស្រាយបញ្ហាបានតាមគោលបំណង និងគោលដៅ
- បោះបង់ចោលជម្រើសដែលមិនអាចអនុវត្តបាន ឬមិនសមរម្យ និងបន្ទាប់មកទៀតរៀបរាប់ឱ្យបានលម្អិតពីជម្រើសដែលអាចអនុវត្តបាន។

### ៣.២.៤.ការវិភាគផលប៉ះពាល់

- កំណត់ផលប៉ះពាល់សំណើបញ្ញត្តិកម្ម និងបុគ្គល ឬក្រុមដែលទទួលរងផលប៉ះពាល់នោះ
- កំណត់ជាបរិមាណដែលអាចធ្វើទៅកើតនូវទំហំ និងចំនួននៃផលប៉ះពាល់ទាំងនោះហើយកំណត់ជាតម្លៃដើម្បីធ្វើការប្រៀបធៀបគ្នាក្នុងចំណោមជម្រើសទាំងនោះ។

### ៣.២.៥.ការពិគ្រោះយោបល់

- ធ្វើការពិគ្រោះយោបល់ជាមួយភាគីរងផលប៉ះពាល់ក្នុងអំឡុងពេលនៃការរៀបចំធ្វើការវាយតម្លៃផលប៉ះពាល់នៃបញ្ញត្តិកម្ម
- ប្រើប្រាស់ព័ត៌មានដែលទទួលបានពីភាគីពាក់ព័ន្ធដើម្បីលើកម្ពស់គុណភាពនៃការវិភាគ។

### ៣.២.៦.សេចក្តីសន្និដ្ឋាន

កំណត់ជម្រើសដែលឃើញថាសមស្របជាងគេ និងផ្តល់ហេតុផលលើការជ្រើសរើសពោល គឺជម្រើសនោះនឹងធ្វើឱ្យសម្រេចគោលបំណង និងគោលដៅនៃកិច្ចអន្តរាគមនិងផ្តល់ផលវិជ្ជមានច្រើនបំផុតដល់សេដ្ឋកិច្ច និងសង្គម។

### ៣.២.៧.ការអនុវត្ត និងតាមដានត្រួតពិនិត្យ

ពន្យល់ពីវិធីដែលជម្រើសថា សមស្របនោះនឹងត្រូវអនុវត្ត និងវាយតម្លៃ។

ទាក់ទងនឹងគោលការណ៍ និងរបាយការណ៍ RIA ប្រទេសកម្ពុជាមានវិធីសាស្ត្រអនុវត្តផ្ទាល់ខ្លួនជាពីរទម្រង់គឺ ៖

- របាយការណ៍ RIA បឋម ឬរបាយការណ៍វាយតម្លៃបឋម (PAS) ៖ រាល់សំណើបញ្ញត្តិកម្មដែលអាចមានផលប៉ះពាល់ដល់ធុរកិច្ចតម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃបឋម(PAS) ហើយគោលបំណងនៃការរៀបចំ PAS គឺដើម្បីផ្តល់ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តដោយឆាប់រហ័ស និងកំណត់ថាតើផលប៉ះពាល់ដល់ធុរកិច្ច ឬការប្រកួតប្រជែងច្រើន ឬតិចតួច។ មានគំរូ PAS ដែលត្រូវបានរៀបចំឡើងសម្រាប់ក្រសួងពាក់ព័ន្ធអនុវត្តតាម
- របាយការណ៍ RIA ពេញលេញ ឬរបាយការណ៍វាយតម្លៃពេញលេញ (RIS) ៖ RIS តម្រូវចំពោះសំណើបញ្ញត្តិកម្មប្រសិនបើ PAS បង្ហាញថា មានផលប៉ះពាល់ច្រើន។ ទាំង RAS និងទាំង RIS ប្រើប្រាស់ធាតុទាំង ៧ របស់ RIA ក្នុងការវិភាគ ។

## III. តួអង្គសំខាន់ៗក្នុងដំណើរការនីតិកម្មកម្ពុជា

ដំណើរការនីតិកម្មរបស់កម្ពុជាមានការពាក់ព័ន្ធផ្ទាល់ជាមួយស្ថាប័នសំខាន់ៗជាច្រើនស្របតាមដំណាក់កាលដូចខាងក្រោម ៖

### ១. រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលដឹកនាំដោយនាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់តាមរយៈក្រសួងស្ថាប័ននានាដែលជាសេនាធិការរៀបចំសេចក្តីព្រាងច្បាប់។ ប្រមុខរាជរដ្ឋាភិបាលបញ្ជូនប្រតិភូដែលជាតំណាងរបស់ខ្លួនធ្វើការជាមួយរដ្ឋសភា និងព្រឹទ្ធសភាដើម្បីបកស្រាយ ពន្យល់ និងការពារខ្លឹមសារក្នុងសេចក្តីព្រាងច្បាប់ដែលកំពុងត្រូវបានពិនិត្យទាំងនៅក្នុងគណៈកម្មការនានា និងក្នុងកិច្ចប្រជុំពេញអង្គរដ្ឋសភា និងព្រឹទ្ធសភា។ នាយករដ្ឋមន្ត្រីបញ្ជូនអត្ថបទច្បាប់ដែលរដ្ឋសភានិងព្រឹទ្ធសភាបានអនុម័តរួច ទូលថ្វាយព្រះមហាក្សត្រដើម្បីស្នើសុំព្រះហស្តលេខាប្រកាសឱ្យប្រើច្បាប់។ រាជរដ្ឋាភិបាលមានភារកិច្ចធ្វើការផ្សព្វផ្សាយ និងអនុវត្តច្បាប់នោះ។ នាយករដ្ឋមន្ត្រីមានសិទ្ធិក្នុងការស្នើទៅក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យធម្មនុញ្ញភាពនៃច្បាប់ មុននិងក្រោយច្បាប់ដែលរដ្ឋសភានិងព្រឹទ្ធសភាបានអនុម័ត ច្បាប់នោះប្រកាសឱ្យប្រើជាធរមានផងដែរ។[28]

### ២. រដ្ឋសភា និងព្រឹទ្ធសភា

សមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា មានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់ និងធ្វើវិសោធនកម្មច្បាប់ដែលកំពុងស្ថិតនៅធរមាន។ លើសពីនេះ ពួកគាត់ចូលរួមយ៉ាងសកម្មក្នុងការពិនិត្យ ឱ្យយោបល់ ការពិភាក្សា ការអនុម័ត និងការស្នើសុំធ្វើវិសោធនកម្មលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលកំពុងពិនិត្យនិងពិភាក្សាក្នុងគណៈកម្មការនានា និងនៅក្នុងកិច្ចប្រជុំពេញអង្គរដ្ឋសភា និងព្រឹទ្ធសភារៀងៗខ្លួន។ ចំពោះច្បាប់រៀបចំអង្គការ ក្រោយពីត្រូវបានអនុម័តដោយរដ្ឋសភា និងត្រូវបានពិនិត្យនិងឱ្យយោបល់ដោយព្រឹទ្ធសភារួច រដ្ឋសភាត្រូវបញ្ជូនច្បាប់នោះទៅក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យធម្មនុញ្ញភាពមុន

---
[28] រដ្ឋធម្មនុញ្ញ មាត្រា ១៤០ថ្មី និង ១៤១ថ្មី

នឹងប្រកាសឱ្យប្រើ។[29] ដោយឡែក មុននិងក្រោយពីច្បាប់ត្រូវបានប្រកាសឱ្យប្រើ ប្រធានរដ្ឋសភា តំណាងរាស្ត្រចំនួនមួយភាគដប់ (១/១០) ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន (១/៤) អាចស្នើទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់នោះផងដែរ។[30]

### ២.១. គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងព្រឹទ្ធសភា

គណៈកម្មាធិការអចិន្ត្រៃយ៍ គឺជាអង្គការជាន់ខ្ពស់ស្ថិតក្នុងរចនាសម្ព័ន្ធនយោបាយរបស់រដ្ឋសភា និងព្រឹទ្ធសភា ដែលមានអំណាចគ្រប់គ្រង ដឹកនាំ ចាត់ចែង និងធានានូវការបំពេញតួនាទី ភារកិច្ច និងការងាររបស់រដ្ឋសភា និងព្រឹទ្ធសភាដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងព្រឹទ្ធសភាមានសមាសភាពដូចគ្នារួមមាន ប្រធាន អនុប្រធានទាំងពីរ និងប្រធានគណៈកម្មការនានា។[31]

ក្នុងកិច្ចប្រជុំលើកទី១ របស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា និងព្រឹទ្ធសភា គឺដើម្បីពិនិត្យលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ហើយបញ្ជូនទៅគណៈកម្មការ មួយ ឬច្រើនដើម្បីពិនិត្យ និងសិក្សា។ បន្ទាប់មក គណៈកម្មាធិការអចិន្ត្រៃយ៍នៃសភានីមួយៗរៀបចំកិច្ចប្រជុំលើកទី២ ដើម្បីស្តាប់របាយការណ៍ដែលជាលទ្ធផល នៃការសិក្សាស្រាវជ្រាវរបស់គណៈកម្មការទទួលបន្ទុក ហើយសម្រេចដាក់ ឬមិនដាក់បញ្ចូលសេចក្តីព្រាងច្បាប់ ឬសេចក្តីព្រាងច្បាប់នោះ ទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំពេញអង្គនៃស្ថាប័នរៀងៗខ្លួន។

### ២.២. គណៈកម្មការនានារបស់រដ្ឋសភា និងព្រឹទ្ធសភា

គណៈកម្មការនីមួយៗនៃរដ្ឋសភាមានសមាជិកយ៉ាងតិចប្រាំពីររូប [32] រីឯគណៈកម្មការនីមួយៗនៃព្រឹទ្ធសភា មានសមាជិកយ៉ាងតិចប្រាំរូប[33]។ សមាជិករដ្ឋសភាមួយរូបអាចជាសមាជិកពីរគណៈ

[29] រដ្ឋធម្មនុញ្ញ មាត្រា ១៤០ថ្មី

[30] រដ្ឋធម្មនុញ្ញ មាត្រា ១៤០ថ្មី និង ១៤១ថ្មី

[31] បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ប្រការ ៧ ថ្មី (ពីរ) និង បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ប្រការ ១៣

[32] បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ឆ្នាំ២០១៨ ប្រការ១០ថ្មី (បី) វាក្យខណ្ឌទី៦

[33] បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ឆ្នាំ២០១៧ ប្រការ១៦

កម្មការបាន[34] ចំណែកឯសមាជិកព្រឹទ្ធសភាមួយរូបអាចឈរជាបេក្ខជនសមាជិកគណៈកម្មការពីរបាន[35]។

វិស័យទទួលខុសត្រូវរបស់គណៈកម្មការជំនាញនៃសភាទាំងពីរ ត្រូវបានរៀបចំទៅតាមវិស័យពាក់ព័ន្ធគ្នាដែលស្របនឹងការទទួលខុសត្រូវជាក់ស្តែងរបស់ក្រសួងស្ថាប័ននានានៃរាជរដ្ឋាភិបាល។

គណៈកម្មការមានភារកិច្ចសិក្សាស្រាវជ្រាវលម្អិតលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលត្រូវបានបញ្ជូនមកដោយគណៈកម្មាធិការអចិន្ត្រៃយ៍ និងត្រូវរាយការណ៍ត្រឡប់ទៅវិញមុននឹងដាក់ពិភាក្សានិងអនុម័តដោយកិច្ចប្រជុំពេញអង្គនៃស្ថាប័នរបស់ខ្លួន។

### ២.៣. កិច្ចប្រជុំពេញអង្គរដ្ឋសភា និងព្រឹទ្ធសភា

កិច្ចប្រជុំពេញអង្គរដ្ឋសភា និងព្រឹទ្ធសភា គឺជាដំណើរការនៃកិច្ចប្រជុំរៀងៗខ្លួនរបស់សមាជិករដ្ឋសភា ឬសមាជិកព្រឹទ្ធសភាទាំងអស់ដើម្បីពិភាក្សា ឱ្យយោបល់ និងអនុម័តសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងស្របតាមរបៀបវារៈដែលបានកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍។ ក្នុងដំណាក់កាលពិភាក្សា និងអនុម័ត មានតួអង្គពាក់ព័ន្ធសំខាន់ៗជាច្រើនចូលរួមក្នុងកិច្ចប្រជុំពេញអង្គដូចជា តំណាងរាជរដ្ឋាភិបាល និងសមាជិកសភាដែលជាម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ គណៈកម្មការទទួលបន្ទុក និង/ឬគណៈកម្មការសហការ និងក្រុមនយោបាយ (Political group)។

## ៣. ក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលត្រូវបានអនុម័តដោយរដ្ឋសភា និងពិនិត្យឱ្យយោបល់ដោយព្រឹទ្ធសភា។[36] ក្រុមប្រឹក្សាធម្មនុញ្ញទទួលពិគ្រោះយោបល់ជាមួយព្រះមហាក្សត្រចំពោះសេចក្តីស្នើទាំងឡាយដែលសុំធ្វើវិសោធនកម្មលើ

[34] បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ឆ្នាំ២០១៨ ប្រការ១០ថ្មី (បី) វាក្យខណ្ឌទី៧

[35] បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ឆ្នាំ២០១៧ ប្រការ៩ថ្មី

[36] រដ្ឋធម្មនុញ្ញ មាត្រា១៣៦ ថ្មី

រដ្ឋធម្មនុញ្ញ។ [37] ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់ មុននិងក្រោយពេលច្បាប់ចូលជាធរមាន តាមសំណើរបស់តួអង្គដែលមានសិទ្ធិប្តឹងអំពីធម្មនុញ្ញភាពរបស់ច្បាប់ ដូចមានកំណត់ក្នុងមាត្រា ១៤០ថ្មី និង ១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ។ ច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ត្រូវបញ្ជូនឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពមុននឹងប្រកាសឱ្យប្រើ។ [38] ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធ្វើមោឃភាពច្បាប់ណាមួយ ឬសំណើណាមួយដែលត្រូវបានអនុម័តដោយរដ្ឋសភា ផ្ទុយនឹងគោលការណ៍ និងការហាមឃាត់របស់រដ្ឋធម្មនុញ្ញ ដូចមានក្នុងចំណុច(II.២)ខាងលើ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញគឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ានិងមានអំណាចលើគ្រប់ស្ថាប័នរដ្ឋ។[39]

## ៤. ព្រះមហាក្សត្រ

ទាក់ទងនឹងការងារនីតិកម្ម ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខា និងផ្តល់សច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ បន្ទាប់ពីត្រូវបានពិនិត្យ និងអនុម័តដោយរដ្ឋសភានិងព្រឹទ្ធសភា។[40] ព្រះមហាក្សត្រឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ និងច្បាប់ដែលត្រូវបានអនុម័តដោយរដ្ឋសភានិងពិនិត្យឱ្យយោបល់ដោយព្រឹទ្ធសភា។[41] ព្រះមហាក្សត្រអាចបញ្ជូនច្បាប់ដែលបានអនុម័តទៅក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យមុននិងក្រោយពេលដែលច្បាប់ប្រកាសឱ្យប្រើ។[42]

[37] រដ្ឋធម្មនុញ្ញ មាត្រា១៤៣ ថ្មី
[38] រដ្ឋធម្មនុញ្ញ មាត្រា១៤០ ថ្មី
[39] រដ្ឋធម្មនុញ្ញ មាត្រា១៤២ ថ្មី
[40] រដ្ឋធម្មនុញ្ញ មាត្រា២៦ ថ្មី
[41] រដ្ឋធម្មនុញ្ញ មាត្រា២៨ ថ្មី
[42] រដ្ឋធម្មនុញ្ញ មាត្រា១៤០ ថ្មី និង មាត្រា ១៤១ ថ្មី

# IV. ដំណាក់កាលនៃការពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់

រាជរដ្ឋាភិបាល សមាជិករដ្ឋសភា ក្រុមសមាជិករដ្ឋសភា ឬក្រុមសមាជិកព្រឹទ្ធសភា ត្រូវបញ្ជូនអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ និងឯកសារពាក់ព័ន្ធដូចជា សេចក្តីថ្លែងហេតុ តាមរយៈលិខិតផ្លូវការរបស់ម្ចាស់សំណើដើម្បីសុំការអនុម័តពីរដ្ឋសភា។

## ១. នីតិវិធីនៃការពិនិត្យ និងអនុម័តនៅរដ្ឋសភា

❖ **ជំហានទី១ ៖ ការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា (លើកទី១)**

**☛ មុនពេលប្រជុំ**

- នៅពេលម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់បញ្ជូនមករដ្ឋសភា ចាំបាច់ត្រូវចូលតាមច្រកនាយកដ្ឋានរដ្ឋបាលដើម្បីចុះលេខលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ហើយបញ្ជូនទៅអគ្គលេខាធិការរដ្ឋសភា។ បន្ទាប់មក អគ្គលេខាធិការចាត់ចែងបញ្ជូនបន្តទៅនាយកដ្ឋានពាក់ព័ន្ធនានា ដើម្បីបន្តនីតិវិធី
- នាយកដ្ឋាននីតិវិធីទទួលបន្ទុករៀបចំកំណត់បង្ហាញស្តីពីសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់សម្រាប់ផ្តល់យោបល់ ឬយោបល់ផ្នែកច្បាប់ទៅប្រធានរដ្ឋសភាតាមរយៈអគ្គនាយកដ្ឋាននីតិកម្ម និងស្រាវជ្រាវ និងអគ្គលេខាធិការរដ្ឋសភា ដើម្បីស្នើយោបល់ឬគោលការណ៍ដាក់បញ្ចូលក្នុងរបៀបវារៈកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍។ (មើលឧបសម្ព័ន្ធ១៖កំណត់បង្ហាញពេលទទួលបានសេចក្តីព្រាងច្បាប់ពីរាជរដ្ឋាភិបាល)
- បន្ទាប់ពីបានឃើញយោបល់ពាក់ព័ន្ធនានា ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ (ប្រធានរដ្ឋសភា) សម្រេចថា តើដាក់ ឬមិនដាក់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះទៅក្នុងរបៀបវារៈកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ឱ្យពិនិត្យពិចារណា

- ដំណាក់កាលនេះ នាយកដ្ឋាននីតិវិធីត្រូវសម្របសម្រួលជាមួយគណៈកម្មាធិការអចិន្ត្រៃយ៍ និងរៀបចំលិខិតអញ្ជើញ ឯកសារពាក់ព័ន្ធ របៀបវារៈ និងកំណត់កាលបរិច្ឆេទសម្រាប់កិច្ចប្រជុំគណៈ កម្មាធិការអចិន្ត្រៃយ៍ដើម្បីពិនិត្យនិងបញ្ជូនសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ ឱ្យគណៈកម្មការសិក្សាស្រាវជ្រាវ
- ចុងក្រោយ ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ កោះអញ្ជើញសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ទាំងអស់តាមរយៈលិខិតអញ្ជើញផ្លូវការមួយ ដែលនៅក្នុងស្រោមសំបុត្រអញ្ជើញនោះមានលិខិតអញ្ជើញ និងរបៀបវារៈប្រជុំ ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងៗ ដូចជាអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ សេចក្តីថ្លែងហេតុនៃអត្ថបទច្បាប់ និងលិខិតរបស់ម្ចាស់អត្ថបទច្បាប់ដែលស្នើសុំឱ្យរដ្ឋសភាអនុម័តច្បាប់។ (មើលឧបសម្ព័ន្ធ២៖ លិខិតអញ្ជើញប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា)

## ☛ អំឡុងពេលប្រជុំ

- មុនដំបូង ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ស្នើឱ្យពិនិត្យកូរ៉ុមនៃអង្គប្រជុំដែលជាគោលការណ៍តម្រូវឱ្យមាន លើសពី ៥០%+១ នៃចំនួនសមាជិកទាំងមូល
- ប្រធានអង្គប្រជុំអានរបៀបវារៈប្រជុំ ហើយស្នើឱ្យសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ទាំងអស់អនុម័តដោយលើកដៃ
- បន្ទាប់មក ប្រធានអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចាប់ផ្តើមពិនិត្យរបៀបវារៈម្តងមួយៗ។ សេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ដែលស្នើសុំជាការប្រញាប់ស្ថិតក្នុងរបៀបវារៈជាអាទិភាពមុនគេ
- ការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ (លើកទី១)នេះ ពិនិត្យនិងពិចារណាជារួមតែនៅលើទម្រង់ច្បាប់ គតិច្បាប់ និងវិស័យទទួលខុសត្រូវ ដើម្បីបញ្ជូនសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់នោះទៅគណៈកម្មការបន្ទុក និង/ឬគណៈកម្មការសហការដែលមានសមត្ថកិច្ចឱ្យធ្វើការសិក្សាស៊ីជម្រៅ

- កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យនិងអនុម័តបញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ទៅគណៈកម្មការទទួលបន្ទុក និង/ឬសហការជាមួយគណៈកម្មការដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃចំនួនសមាជិកទាំងមូល ដើម្បីសិក្សាស្រាវជ្រាវ និងរាយការណ៍ត្រឡប់មកវិញអំពីលទ្ធផលនៃការសិក្សាទៅជម្រាបក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍(លើកទី២)។ ដោយឡែក ចំពោះសេចក្តីព្រាងច្បាប់ថវិកា ឬសេចក្តីព្រាងច្បាប់ទូទាត់ថវិកា គណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវតែបញ្ជូនទៅគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មដើម្បីសិក្សាស្រាវជ្រាវ។

**➨ ក្រោយពេលប្រជុំ**

ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះហត្ថលេខាលើលិខិតផ្លូវការមួយដែលរៀបចំដោយនាយកដ្ឋាននីតិវិធី ដើម្បីបញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះទៅគណៈកម្មការទទួលបន្ទុកនិងគណៈកម្មការសហការបើមាន ហើយថតចម្លងអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជូនតំណាងរាស្ត្រទាំងអស់ដោយដាក់ក្នុងប្រអប់សំបុត្ររបស់ពួកគាត់ដែលស្ថិតក្រោមការគ្រប់គ្រង និងចាត់ចែងរបស់នាយកដ្ឋានរដ្ឋបាល។ (មើលឧបសម្ព័ន្ធ៣៖ លិខិតបញ្ជូនច្បាប់ឱ្យគណៈកម្មការសិក្សា)

### ❖ ជំហានទី២ ៖ ការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នៅក្នុងគណៈកម្មការទទួលបន្ទុក

ជាទូទៅ ដើម្បីសិក្សាស្រាវជ្រាវសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ មានកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ កិច្ចប្រជុំជាមួយគណៈកម្មការសហការ (បើមាន) និងកិច្ចប្រជុំជាមួយតំណាងរាជរដ្ឋាភិបាលដោយមានការចូលរួមពីតំណាងគណៈកម្មការនានារបស់រដ្ឋសភាដែរ។ *គណៈកម្មការទទួលបន្ទុក* កោះប្រជុំផ្ទៃក្នុងគណៈកម្មការដើម្បីបែងចែកភារកិច្ចក្នុងការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទៅឱ្យសមាជិកគណៈកម្មការ។ ដំណាលគ្នានោះ កិច្ចប្រជុំគណៈកម្មការសហការត្រូវបានធ្វើឡើងដែរគឺដើម្បីប្រមូលមតិយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។ បន្ទាប់មក មានកិច្ចប្រជុំរួមគ្នារវាងគណៈកម្មការទទួលបន្ទុក និង/ឬគណៈកម្មការសហការ និងតំណាងគណៈកម្មការនានា ជាមួយ

តំណាងរាជរដ្ឋាភិបាល ដើម្បីលើកជាសំណួរផ្សេងៗ និងស្តាប់ការបំភ្លឺរាល់បញ្ហាឬចំណុចទាំងឡាយដែលមិនច្បាស់លាស់នៅក្នុងសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។

☛ **មុនពេលប្រជុំ**

- បន្ទាប់ពីទទួលបានលិខិតផ្លូវការពីគណៈកម្មាធិការអចិន្ត្រៃយ៍បញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ឱ្យគណៈកម្មការទទួលបន្ទុកសិក្សា និងដោយមានជំនួយពីជំនួយការគណៈកម្មការ *ប្រធានគណៈកម្មការទទួលបន្ទុក* ធ្វើលិខិតកោះអញ្ជើញសមាជិកគណៈកម្មការទទួលបន្ទុក និង/ឬគណៈកម្មសហការទាំងអស់ ទីប្រឹក្សាច្បាប់អមរដ្ឋសភា ទីប្រឹក្សាច្បាប់ប្រចាំគណៈកម្មការ ដើម្បីចូលរួមប្រជុំផ្ទៃក្នុង ដើម្បីបែងចែកភារកិច្ចសិក្សាស្រាវជ្រាវស៊ីជម្រៅសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់
- **មន្ត្រីជំនួយការគណៈកម្មការ** ត្រូវត្រៀមរៀបចំអត្ថបទចម្លង (Hard-copy) និងស្នើសុំអត្ថបទ ដើមក្នុងកុំព្យូទ័រ (Soft-copy) នៃអត្ថបទច្បាប់ពីម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់សម្រាប់ការពិនិត្យនិងពិភាក្សាក្នុងកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ។ លើសពីនេះ មន្ត្រីជំនួយការគណៈកម្មការត្រូវធ្វើការងាររដ្ឋបាលផ្សេងទៀតដូចជា ការរៀបចំធ្វើកំណត់ហេតុរបាយការណ៍អង្គប្រជុំ និងការស្រាវជ្រាវរាល់ឯកសារពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជូនសមាជិកគណៈកម្មការ ជាពិសេស ស្រង់នូវចំណុចសំខាន់ៗរបស់សមាជិកគណៈកម្មការដែលបានស្នើសុំធ្វើការកែសម្រួល និងសំណួរផ្សេងៗសម្រាប់កិច្ចប្រជុំជាមួយម្ចាស់សេចក្តីព្រាង ឬសេចក្តីស្នើច្បាប់។

☛ **អំឡុងពេលប្រជុំ**

- ប្រធានគណៈកម្មការទទួលបន្ទុកពិនិត្យកូរ៉ុមប្រជុំ បើមានកូរ៉ុមលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មការទាំងមូល អង្គប្រជុំអាចចាប់ផ្តើមដំណើរការ បើពុំដូចនោះទេ ប្រធានអង្គប្រជុំនឹងលើកពេលកិច្ចប្រជុំ

- ប្រធានគណៈកម្មការទទួលបន្ទុកអានរបៀបវារៈនៃកិច្ចប្រជុំ និងលើកពីលទ្ធផលសម្រេចនៃកិច្ចប្រជុំផ្ទៃក្នុងរបស់គណៈកម្មការ ស្តីពីការសិក្សាស្រាវជ្រាវលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់
- សមាជិកគណៈកម្មការទទួលបន្ទុក ឬតំណាងគណៈកម្មការសហការ មានសិទ្ធិលើកឡើងនូវចំណុចណាមួយក្នុងជំពូក ឬក្នុងមាត្រាណាមួយមកស្នើសុំធ្វើការកែសម្រួល ឬលុបចោល ដោយមានភ្ជាប់ជាមួយនូវហេតុផលច្បាស់លាស់ និងលើកឡើងសំណួរដើម្បីឱ្យម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ធ្វើការបំភ្លឺ
- **ទីប្រឹក្សាច្បាប់អមគណៈកម្មការ** ក៏មានភារកិច្ចផ្តល់យោបល់ និងអនុសាសន៍ក្នុងពេលប្រជុំផងដែរ ប៉ុន្តែ មិនមានសិទ្ធិសម្រេច ឬអនុម័តនៅក្នុងកិច្ចប្រជុំគណៈកម្មការបានឡើយ[43]
- គណៈកម្មការទទួលបន្ទុកស្តាប់ទស្សនៈរួមរបស់ម្ចាស់សេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ក្នុងដំណើរការ ការវិវត្តនៃស្ថានការណ៍ និងភាពចាំបាច់ដែលនាំឱ្យមានការតាក់តែងសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់
- បើមានការចាំបាច់ គណៈកម្មការទទួលបន្ទុកអាចរៀបចំសិក្ខាសាលា ឬវេទិកាសាធារណៈជាមួយសាធារណជន អង្គការអន្តរជាតិ និងសង្គមស៊ីវិលដើម្បីប្រមូលមតិយោបល់ និងធាតុចូលនានាបញ្ចូលក្នុងសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលកំពុងសិក្សាស្រាវជ្រាវ
- គណៈកម្មការទទួលបន្ទុក អាចស្នើអ្នកជំនាញនៅក្នុងរដ្ឋសភា ឬមកពីក្រៅ ដើម្បីវិភាគលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលកំពុងសិក្សាស្រាវជ្រាវផងដែរ
- សមាជិករដ្ឋសភាមួយរូប ឬគណៈកម្មការទទួលបន្ទុកអាចធ្វើសំណើទៅក្រុមប្រឹក្សាអ្នកច្បាប់ នាយកដ្ឋានស្រាវជ្រាវច្បាប់ នាយកដ្ឋានស្រាវជ្រាវកិច្ចការជាតិ និងនាយកដ្ឋាន

[43] ប្រការ ១២ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា

ស្រាវជ្រាវកិច្ចការអន្តរជាតិនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ដើម្បីប្រមូលគំនិតយោបល់ និងព័ត៌មានទាំងឡាយពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់

- សមាជិកគណៈកម្មការទទួលបន្ទុក និងតំណាងគណៈកម្មការនានាចូលរួមប្រជុំពិភាក្សាលើបញ្ហាផ្សេងៗជាមួយម្ចាស់អត្ថបទច្បាប់។ ប្រសិនបើមានការឯកភាពគ្នារវាងគណៈកម្មការ និងម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ អាចមានការកែសម្រួលខ្លឹមសារមួយចំនួនក្នុងសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ក្នុងអំឡុងកិច្ចប្រជុំរបស់គណៈកម្មការ
- ក្នុងអំឡុងពេលសិក្សាស្រាវជ្រាវនេះ ប្រសិនបើមានវិសោធនកម្ម [44] សំខាន់ចាំបាច់លើសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ស្នើឡើងដោយគណៈកម្មការទទួលបន្ទុក ពេលនោះម្ចាស់អត្ថបទច្បាប់ត្រូវកែសម្រួល និងធ្វើជាសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់លើកទី២ រួចផ្ញើមករដ្ឋសភាតាមដំណើរនីតិវិធីនីតិកម្មជាថ្មីម្តងទៀត។ ប៉ុន្តែ បើមានការកែសម្រួលតិចតួចក្នុងអត្ថបទច្បាប់ អង្គប្រជុំគណៈកម្មការទទួលបន្ទុក ឬកិច្ចប្រជុំរវាងគណៈកម្មការទទួលបន្ទុក និងម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ អាចឯកភាពគ្នាកែសម្រួលតែម្តងដោយមិនបាច់មានគម្រោងលើកទី២ ទេ
- ក្រោយការពិភាក្សាកែសម្រួលផ្សេងៗក្នុងអត្ថបទច្បាប់ កិច្ចប្រជុំរបស់គណៈកម្មការទទួលបន្ទុក ឬជាមួយសមាជិកគណៈកម្មការសហការ ឬជាមួយម្ចាស់សេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ អនុម័តយល់ព្រមរួមគ្នាថា ឯកភាពឬមិនឯកភាពដោយសំឡេងភាគច្រើន (៥0%+១)

[44] ជាក់ស្តែង «វិសោធនកម្ម» ចាំបាច់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ អាចសំដៅដល់ ការកែប្រែ ឬការលុបចោលអត្ថន័យ ឬការបន្ថែមមាត្រាឬជំពូក។ ទោះជាយ៉ាងនេះក៏ដោយ សេចក្តីព្រាងលើកទី២ ត្រូវបានគេកែសម្រួលផ្អែកទៅលើកិច្ចពិភាក្សាក្នុងអង្គប្រជុំរវាងគណៈកម្មការទទួលបន្ទុក និងម្ចាស់សេចក្តីព្រាង។ ពីព្រោះថា ប្រសិនបើមានសេចក្តីព្រាងលើកទី២ក្នុងដំណាក់កាលនេះ គេត្រូវរៀបចំដំណើរនីតិវិធីគ្រប់ជំហានឡើងវិញក្នុងដំណើរការពិនិត្យច្បាប់ក្នុងរដ្ឋសភា ដែលជានិច្ចកាលវាត្រូវការពេលវេលាច្រើន។ ដូច្នេះ ប្រសិនបើមានកំហុសតិចតួចនៅក្នុងសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលកំពុងពិនិត្យ ឧទាហរណ៍ ការប្រើពាក្យពេចន៍ អក្ខរាវិរុទ្ធ និងការវាយអត្ថបទ។ល។ គេអាចព្រមព្រៀងគ្នាកែតម្រូវកំហុសទាំងនោះនៅក្នុងកម្រិតគណៈកម្មការបាន។

- ជាចុងក្រោយ គណៈកម្មការទទួលបន្ទុកស្នើសុំអង្គប្រជុំសម្រេចដាក់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ក្នុងរបៀបវារៈកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍លើកទី២។

**☛ ក្រោយពេលប្រជុំ**

- បន្ទាប់ពីការសិក្សាស្រាវជ្រាវសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ចប់ មន្ត្រីជំនួយការអមគណៈកម្មការទទួលបន្ទុកជាអ្នកធ្វើកំណត់ហេតុ និងរបាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាស្រាវជ្រាវនោះ
- មន្ត្រីជំនួយការត្រូវរៀបចំលិខិតផ្លូវការជូនប្រធានគណៈកម្មការទទួលបន្ទុកចុះហត្ថលេខាដើម្បីស្នើសុំដាក់បញ្ចូលក្នុងរបៀបវារៈនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ (លើកទី២) ដោយភ្ជាប់ជាមួយនូវរបាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាស្រាវជ្រាវសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។ លិខិតផ្លូវការនោះផ្ញើជូនប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។ (មើលឧបសម្ព័ន្ធ៤៖ លិខិតស្នើសុំដាក់បញ្ចូលក្នុងរបៀបវារៈប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គរដ្ឋសភា)

## ❖ ជំហានទី៣ ៖ ការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា(លើកទី២)

**☛ មុនពេលប្រជុំ**

- មន្ត្រីនាយកដ្ឋាននីតិវិធី ជាសេនាធិការក្នុងការរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងកិច្ចប្រជុំពេញអង្គ។ ដូច្នេះ មន្ត្រីនាយកដ្ឋាននីតិវិធីមានភារកិច្ចរៀបចំលិខិតអញ្ជើញសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ចូលរួមប្រជុំលើកទី២ ដើម្បីស្តាប់របាយការណ៍សិក្សាស្រាវជ្រាវរបស់គណៈកម្មការទទួលបន្ទុក។ នៅក្នុងលិខិតអញ្ជើញនោះមានភ្ជាប់ជាមួយរបៀបវារៈប្រជុំ និងឯកសារមួយចំនួនពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់។

## ☛ អំឡុងពេលប្រជុំ

- ដំបូង ប្រធានគណៈកម្មការអចិន្ត្រៃយ៍ពិនិត្យកូរ៉ុមប្រជុំ ។ សមាជិកត្រូវមានវត្តមានលើសពី ៥០%+១ សម្រាប់ដំណើរការប្រជុំអាចប្រព្រឹត្តទៅបាន
- បន្ទាប់ពីអានរបៀបវារៈ ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ស្នើសមាជិកទាំងអស់អនុម័តរបៀបវារៈដោយលើកដៃ
- បន្ទាប់មក អង្គប្រជុំចាប់ផ្តើមពិនិត្យរបៀបវារៈម្តងមួយៗតាមលំដាប់អាទិភាព
- លុះដល់របៀបវារៈរបស់ខ្លួន ប្រធានគណៈកម្មការទទួលបន្ទុកឡើងធ្វើសេចក្តីរាយការណ៍ជូនអង្គប្រជុំអំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់របស់ខ្លួន
- ចុងក្រោយ អង្គប្រជុំសម្រេចថាតើត្រូវដាក់បញ្ចូល ឬមិនដាក់បញ្ចូលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះក្នុងរបៀបវារៈប្រជុំពេញអង្គនៃរដ្ឋសភា[45] ប្រសិនបើមានសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ច្រើនដែលត្រូវដាក់បញ្ចូលក្នុងរបៀបវារៈនៃកិច្ចប្រជុំពេញអង្គរដ្ឋសភា អង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ត្រូវពិចារណា និងរៀបចំរបៀបវារៈពេញអង្គរដ្ឋសភាតាមលំដាប់អាទិភាពនៃកាស្នើសុំប្រញាប់ និងបន្ទាន់របស់ម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់
- ក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍លើកទី២នេះ អង្គប្រជុំក៏ត្រូវពិនិត្យនិងអនុម័តកាលបរិច្ឆេទ និងសមាសភាពលេខាធិការនៃកិច្ចប្រជុំពេញអង្គរដ្ឋសភាចំនួន ៣រូប ផងដែរដើម្បីជួយការងារប្រជុំពេញអង្គរដ្ឋសភានាពេលខាងមុខ។

[45] បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ឆ្នាំ២០១៨ ប្រការ២១ថ្មី

- **ក្រោយពេលប្រជុំ**

  - បន្ទាប់ពីប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍លើកទី២ សេចក្តីប្រកាសព័ត៌មានមួយត្រូវបានធ្វើឡើងដោយអគ្គលេខាធិការដ្ឋានរដ្ឋសភា ដើម្បីជូនដំណឹងដល់សាធារណជនអំពីលទ្ធផលនៃអង្គប្រជុំនេះ។ សេចក្តីប្រកាសព័ត៌មានបង្ហាញអំពីកាលបរិច្ឆេទ និងរបៀបវារៈសម្រាប់កិច្ចប្រជុំពេញអង្គនៃរដ្ឋសភាខាងមុខ
  - នាយកដ្ឋាននីតិវិធីត្រៀមរៀបចំលិខិតអញ្ជើញនិងរបៀបវារៈដើម្បីអញ្ជើញតំណាងរាស្ត្រទាំងអស់ចូលរួមប្រជុំពេញអង្គឬជាកិច្ចប្រជុំវិសាមញ្ញនៃរដ្ឋសភានាពេលខាងមុខ។

### ❖ ជំហានទី៤ ៖ ការពិភាក្សា និងអនុម័តក្នុងកិច្ចប្រជុំពេញអង្គរដ្ឋសភា

- **មុនពេលប្រជុំ**

  - ប្រធានរដ្ឋសភា កោះអញ្ជើញតំណាងរាស្ត្រទាំងអស់មកចូលរួមប្រជុំពេញអង្គ តាមរយៈលិខិតអញ្ជើញផ្លូវការមួយ។ (មើលឧបសម្ព័ន្ធ៥៖ លិខិតកោះប្រជុំពេញអង្គរដ្ឋសភា)
  - អគ្គលេខាធិការរដ្ឋសភារៀបចំលិខិតផ្លូវការអញ្ជើញតំណាងរាជរដ្ឋាភិបាល ឬម្ចាស់អត្ថបទច្បាប់ ដើម្បីមកការពារនៅក្នុងកិច្ចប្រជុំពេញអង្គរដ្ឋសភា។ (មើលឧបសម្ព័ន្ធ៦៖ លិខិតអញ្ជើញតំណាងរាជរដ្ឋាភិបាលការពារច្បាប់)
  - មន្ត្រីនាយកដ្ឋាននីតិវិធីត្រៀមឯកសារ ឧបករណ៍ សេវារៀបចំឯកសារ និងជំនួយស្មារតីសម្រាប់ប្រធានរដ្ឋសភា ឬប្រធានស្តីទីដើម្បីដឹកនាំដំណើរការកិច្ចប្រជុំពេញអង្គរដ្ឋសភា។

- **អំឡុងពេលប្រជុំ**

  - ក្រោយពីទទួលលិខិតអញ្ជើញពីប្រធានរដ្ឋសភា សមាជិករដ្ឋសភាទាំងអស់ចូលរួមប្រជុំពេញអង្គនៃរដ្ឋសភាក្រោមអធិបតីភាពប្រធាន និងអនុប្រធានទាំងពីរនៃរដ្ឋសភាដើម្បីពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាសាធារណៈ

- កូរ៉ុមនៃកិច្ចប្រជុំពេញអង្គរដ្ឋសភា ប្រែប្រួលដោយផ្អែកតាមវិធាននៃការអនុម័ត។ បើការអនុម័តតម្រូវឱ្យមានសំឡេងភាគច្រើនពីរភាគបី (២/៣) នៃចំនួនសមាជិកសភាទាំងមូល ចំនួនកូរ៉ុមអាចដំណើរការទៅបានលុះត្រាតែ មានចំនួនសមាជិករដ្ឋសភាមកចូលរួមប្រជុំលើសពី ពីរភាគបី (២/៣)។ ដោយឡែក បើការអនុម័តតម្រូវឱ្យមានសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃចំនួនសមាជិករដ្ឋសភាទាំងមូល លុះត្រាតែមានសមាជិករដ្ឋសភាមកចូលរួមប្រជុំលើសពីពាក់កណ្តាល (៥០%+១)នៃសមាជិកទាំងមូល
- បន្ទាប់ពីពិនិត្យកូរ៉ុមប្រជុំ និងក្រោយពីអានរបៀបវារៈនៃកិច្ចប្រជុំពេញអង្គ ប្រធានរដ្ឋសភា ឬប្រធានរដ្ឋសភាស្តីទី ស្នើឱ្យសមាជិករដ្ឋសភាទាំងអស់អនុម័តយល់ព្រមលើរបៀបវារៈនៃកិច្ចប្រជុំពេញអង្គ
- បន្ទាប់មក អង្គប្រជុំចាប់ផ្តើមពិភាក្សានិងអនុម័តសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាបន្តបន្ទាប់ស្របតាមរបៀបវារៈដែលទើបបានអនុម័ត។

ដើម្បីពិភាក្សា និងអនុម័តរបៀបវារៈនីមួយៗតាមលំដាប់ មុនដំបូងប្រធានរដ្ឋសភាត្រូវអានរបៀបវារៈនោះ ហើយស្នើអង្គប្រជុំអនុម័តយករបៀបវារៈមួយនោះដើម្បីពិភាក្សានិងអនុម័ត។ បន្ទាប់មកទៀត ក្រោយពីបានពិភាក្សាមួយមាត្រាម្តងៗ ឬមួយជំពូកម្តងៗចប់ ប្រធានរដ្ឋសភាស្នើសុំឲ្យអង្គប្រជុំអនុម័តម្តងទៀត។ ជាចុងក្រោយ បន្ទាប់ពីកិច្ចប្រជុំពេញអង្គរដ្ឋសភាពិនិត្យនិងពិភាក្សាសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះចប់ទាំងស្រុង ប្រធានអង្គប្រជុំស្នើសុំឱ្យកិច្ចប្រជុំពេញអង្គរដ្ឋសភាអនុម័តច្បាប់នោះយកជាផ្លូវការតាមមតិភាគច្រើនដាច់ខាត (៥០%+១) ឬតាមមតិភាគច្រើនពីរភាគបី (២/៣) អាស្រ័យលើភាពចាំបាច់នៃច្បាប់ ឬបញ្ហានានាដែលតម្រូវ។

- នៅពេលដល់របៀបវារៈរបស់ខ្លួន ប្រធានគណៈកម្មការទទួលបន្ទុកអានរបាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាស្រាវជ្រាវលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់របស់ខ្លួនជូនអង្គរដ្ឋសភាជ្រាប និងស្នើឱ្យកិច្ចប្រជុំពេញអង្គរដ្ឋសភាពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ ឬ

សេចក្តីស្នើច្បាប់មួយមាត្រាម្តងៗ ឬមួយជំពូកម្តងៗ។[46] ក្នុងករណីពិភាក្សានិងអនុម័តនេះ ប្រធានរដ្ឋសភាអាចពន្លឿនកិច្ចពិភាក្សានិងអនុម័តបាន ដោយធ្វើការពិនិត្យនិងពិភាក្សាតែទៅលើមាត្រា ឬជំពូកណាដែលបានស្នើធ្វើវិសោធនកម្មតែប៉ុណ្ណោះ

- បន្ទាប់មក តំណាងរាស្ត្រតាមក្រុម (ជាធម្មតាក្រុមនេះរៀបតាមគណបក្សនយោបាយដែលមានអាសនៈនៅរដ្ឋសភា) មានសិទ្ធិក្នុងការបញ្ចេញមតិយោបល់ទូទៅលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។ ជាគោលការណ៍ ក្រុមនីមួយៗមានពេល២០នាទីដើម្បីមានយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។[47] សមាជិករដ្ឋសភាម្នាក់ៗមានពេល៥នាទីដើម្បីឆ្លើយតប ហើយអាចបន្ថែម១០នាទីទៀត ប្រសិនបើប្រធានអង្គប្រជុំយល់ថាចាំបាច់។ ម៉ោងបន្ថែមនេះអាចអនុញ្ញាត ឱ្យពីរដងនៅលើប្រធានបទដដែល ប្រសិនមានម៉ោងនៅសល់។ តំណាងរាស្ត្រដទៃទៀត ដែលនៅក្នុងក្រុមជាមួយគ្នាអាចផ្តល់ យោបល់បន្ថែមនៅលើប្រធានបទដូចគ្នា ប្រសិនបើចាំបាច[48]
- តំណាងរាស្ត្រណាមានបំណងបញ្ចេញមតិយោបល់លើមាត្រា ឬជំពូកណាមួយ ត្រូវបំពេញទម្រង់ស្នើសុំមានមតិដោយមានហត្ថលេខាឯកភាពពីប្រធានក្រុមរបស់ខ្លួន ហើយដាក់ជូនលេខាធិការអង្គប្រជុំរៀបចំតាមលំដាប់មុនក្រោយ រួចប្រគល់ជូនប្រធានរដ្ឋសភាសម្រេចអនុញ្ញាតឱ្យមានមតិជាបន្តបន្ទាប់។[49] (មើលឧបសម្ព័ន្ធ៧៖ លិខិតសុំបញ្ចេញយោបល់ក្នុងសម័យប្រជុំពេញអង្គរដ្ឋសភា)
- ចុងក្រោយនៃការពិនិត្យនិងពិភាក្សាសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ចប់ ប្រធានរដ្ឋសភាស្នើសុំសមាជិករដ្ឋសភាទាំងមូលអនុម័តដោយលើកដៃ។ ដោយឡែក ការអនុម័តលើ

---

[46] បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ឆ្នាំ២០១៨ ប្រការ២៩ថ្មី

[47] បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ឆ្នាំ២០១៨ ប្រការ៥៩ថ្មី

[48] បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ឆ្នាំ២០១៨ ប្រការ៥៨ថ្មី និងប្រការ៥៩ថ្មី

[49] បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ឆ្នាំ២០១៨ ប្រការ៥៥ថ្មី

សំណើវិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវធ្វើឡើងដោយការបោះឆ្នោតសម្ងាត់។ [50] បន្ទាប់មក លេខាធិការនៃកិច្ចប្រជុំពេញអង្គរាប់សំឡេងឬសន្លឹកឆ្នោត ហើយប្រធានរដ្ឋសភាប្រកាសលទ្ធផលនៃសំឡេងអនុម័តរបស់សមាជិករដ្ឋសភា។[51]

## ➨ ក្រោយពេលប្រជុំ

- មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភាត្រូវរៀបចំថតចម្លងសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័ត ហើយមានចុះហត្ថលេខាដោយប្រធានរដ្ឋសភាយកមករក្សាទុកមួយច្បាប់ សម្រាប់ទុកជូនម្ចាស់អត្ថបទច្បាប់មួយច្បាប់ និងអត្ថបទច្បាប់ដើមសម្រាប់ផ្ញើទៅព្រឹទ្ធសភា
- បន្ទាប់មក មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភាត្រូវរៀបចំឯកសារពាក់ព័ន្ធ និងរបាយការណ៍លទ្ធផលនៃការអនុម័តសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដើម្បីផ្ញើជូនព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់បន្តទៀត។ ឯកសារដែលផ្ញើទៅព្រឹទ្ធសភានោះរួមមានដូចខាងក្រោម ៖
    - លិខិតស្នើសុំអនុម័តធ្វើឡើងដោយម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់
    - សេចក្តីថ្លែងហេតុរបស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់
    - របាយការណ៍ដែលបង្ហាញអំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់របស់គណៈកម្មការទទួលបន្ទុក
    - អត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីព្រាងច្បាប់ដែលរដ្ឋសភាបានអនុម័ត
    - លទ្ធផលនៃសំឡេងអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់
    - លិខិតផ្លូវការចុះហត្ថលេខាដោយប្រធានរដ្ឋសភា ទុកសម្រាប់ផ្ញើជូនប្រធានព្រឹទ្ធសភាដើម្បីស្នើសុំឱ្យព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើ

[50] បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ឆ្នាំ២០១៨ ប្រការ៤០ថ្មី
[51] បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ឆ្នាំ២០១៨ ប្រការ៦៥ថ្មី

ច្បាប់។ ក្នុងករណីបន្ទាន់ លិខិតស្នើសុំនោះត្រូវបញ្ជាក់ថា «ស្នើសុំឱ្យព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់ដោយចាត់ទុកជាការប្រញាប់»។

ចុងក្រោយ មន្ត្រីនាយកដ្ឋានរដ្ឋបាលនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា បញ្ជូនឯកសារខាងលើទៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាដើម្បីចាត់ការបន្តនីតិវិធី។

## គំនូសបំព្រួញទី១ ៖ ការពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នៅរដ្ឋសភា



## ២. នីតិវិធីនៃការពិនិត្យ និងឱ្យយោបល់នៅព្រឹទ្ធសភា

តាមនីតិវិធីកំណត់ នៅពេលដែលរដ្ឋសភាបានពិនិត្យ និងអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកដំបូងរួចហើយ រដ្ឋសភាត្រូវធ្វើលិខិតផ្លូវការបញ្ជូនមកប្រធានព្រឹទ្ធសភាដើម្បីស្នើសុំឱ្យព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់។[52]

លិខិតផ្លូវការនេះ មានភ្ជាប់មកជាមួយឯកសារពាក់ព័ន្ធមួយចំនួន ដូចជា សេចក្តីថ្លែងហេតុរបស់ម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ អត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័ត និងរបាយការណ៍សិក្សាស្រាវជ្រាវរបស់គណៈកម្មការទទួលបន្ទុកនៃរដ្ឋសភា ។

ជាធម្មតា សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបញ្ជូនមកព្រឹទ្ធសភា ត្រូវឆ្លងកាត់អគ្គលេខាធិការដ្ឋានជាមុនសិន ។ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានភារកិច្ចទទួលរាប់រងរាល់កិច្ចការរដ្ឋបាល សន្តិសុខ និងសេវាទាំងឡាយរបស់ព្រឹទ្ធសភា ព្រមទាំងទំនាក់ទំនងផ្សេងៗ ក្រៅព្រឹទ្ធសភា ក្រោមការដឹកនាំ និងត្រួតពិនិត្យរបស់ប្រធានព្រឹទ្ធសភា ។

- **ជំហានទី១ ៖ ការពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់** (**គណៈកម្មាធិការអចិន្ត្រៃយ៍លើកទី១**)

**☛មុនពេលប្រជុំ**

ក្រោយពេលទទួលបានឯកសារដូចបានរៀបរាប់ខាងលើ អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី ដោយមាននាយកដ្ឋាននីតិវិធីជាសេនាធិការផ្ទាល់ ត្រូវរៀបចំ និងចាត់ចែងឯកសារចាំបាច់មួយចំនួនដូចខាងក្រោម ៖

- ធ្វើកំណត់បង្ហាញ ស្នើសុំយោបល់ថ្នាក់ដឹកនាំព្រឹទ្ធសភា អំពីការគ្រោងកម្មវិធីប្រជុំ (**អចិន្ត្រៃយ៍លើកទី១ លើកទី២ និងប្រជុំព្រឹទ្ធសភា** ) ក្រោយពេលដែលអង្គប្រជុំរដ្ឋសភា

[52] រដ្ឋធម្មនុញ្ញ មាត្រា១១៣ថ្មី

ត្រូវបានបញ្ចប់ ។(មើលឧបសម្ព័ន្ធ៨៖ លិខិតស្នើសុំយោបល់ពីថ្នាក់ដឹកនាំព្រឹទ្ធសភាលើការកំណត់កាលបរិច្ឆេទប្រជុំនានារបស់ព្រឹទ្ធសភា)

- ធ្វើកំណត់បង្ហាញសុំយោបល់ថ្នាក់ដឹកនាំព្រឹទ្ធសភា លើលិខិតផ្លូវការរបស់ប្រធានរដ្ឋសភា ដែលបញ្ជូនមកព្រឹទ្ធសភា ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដោយបញ្ជាក់អំពីកម្មវត្ថុនៃលិខិត ព្រមទាំងយោបល់របស់អគ្គនាយក និងយោបល់របស់អគ្គលេខាធិការព្រឹទ្ធសភា ដើម្បី ៖
    - រៀបជារបៀបវារៈដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យ និងសម្រេចបញ្ជូនទៅគណៈកម្មការពិនិត្យសិក្សា តាមវិស័យជាសមត្ថកិច្ច
    - ចែកជូនគ្រប់សមាជិកព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សាបន្ទាប់ពីបានការសម្រេចពីគណៈកម្មាធិការអចិន្ត្រៃយ៍(លើកទី១)
    - ត្រៀមរៀបជារបៀបវារៈប្រជុំពេញអង្គព្រឹទ្ធសភា នៅពេលខាងមុខ ។

កំណត់បង្ហាញខាងលើនេះ ត្រូវចុះហត្ថលេខាដោយអគ្គនាយក និងអគ្គលេខាធិការ ដើម្បីស្នើសុំការពិនិត្យ និងសម្រេចពីប្រធានព្រឹទ្ធសភា។ (មើលឧបសម្ព័ន្ធ៩ ៖ កំណត់បង្ហាញលើលិខិតផ្លូវការរបស់រដ្ឋសភាបញ្ជូនមកព្រឹទ្ធសភា)

បន្ទាប់ពីទទួលបានការឯកភាពពីថ្នាក់ដឹកនាំព្រឹទ្ធសភាលើកំណត់បង្ហាញ ស្នើសុំយោបល់អំពីការគ្រោងកម្មវិធីប្រជុំ **អចិន្ត្រៃយ៍លើកទី១ លើកទី២ និងប្រជុំព្រឹទ្ធសភា** រួចមក នាយកដ្ឋាននីតិវិធីត្រូវបន្តការងារមួយចំនួនទៀត ដូចខាងក្រោម ៖

- ធ្វើលិខិតអញ្ជើញប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍លើកទី១ (មើលឧបសម្ព័ន្ធ១០៖ លិខិតអញ្ជើញប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាលើកទី១)
- ធ្វើជំនួយស្មារតីដឹកនាំអង្គប្រជុំ សម្រាប់ប្រធានអង្គប្រជុំ ។

### ➨ អំឡុងពេលប្រជុំ

- **ការពិនិត្យចំនួនវត្តមាន និងកូរ៉ុម**

យោងប្រកា២១ វាក្យខណ្ឌទី២ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា កូរ៉ុមសម្រាប់កិច្ចប្រជុំណាមួយនៃគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការនានា ឬគណៈកម្មការពិសេសព្រឹទ្ធសភា ត្រូវមានលើសពីពាក់កណ្ដាល នៃចំនួនសមាជិកទាំងមូល ។

រាល់ការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការនានា និងគណៈកម្មការពិសេសត្រូវអនុម័តដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកទាំងមូល។

ក្នុងករណីដែលមិនមានកូរ៉ុមគ្រប់ចំនួន កិច្ចប្រជុំនីមួយៗមិនអាចដំណើរការបានឡើយ ហើយប្រធានអង្គប្រជុំប្រកាសលើកពេលប្រជុំទៅពេលក្រោយ។

អគ្គលេខាធិការព្រឹទ្ធសភា និងអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី រួមគ្នាជួយដល់ប្រធានអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងការពិនិត្យចំនួនវត្តមាន និងកូរ៉ុម។

- **ការប្រកាសរបៀបវារៈ និងការអនុម័តរបៀបវារៈ**

យោងមាត្រា១៤ថ្មី ចំណុច (គ) និងមាត្រា៣៧ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍ ជាអ្នករៀបចំរបៀបវារៈនៃពេលសម័យប្រជុំនីមួយៗ។ ការរៀបចំរបៀបវារៈ គឺត្រូវរៀបជាលំដាប់មុនក្រោយដូចតទៅ ៖

- បញ្ហាទាំងឡាយ ដែលមានសំណើសុំចាត់ទុកជាការប្រញាប់
- បញ្ហាទាំងឡាយ ដែលរដ្ឋសភាបញ្ជូនមកព្រឹទ្ធសភា
- បញ្ហាទាំងឡាយ ដែលរាជរដ្ឋាភិបាលបញ្ជូនមកព្រឹទ្ធសភា
- បញ្ហាទាំងឡាយ ដែលគណៈកម្មការបញ្ជូនមកព្រឹទ្ធសភា
- បញ្ហាទាំងឡាយ ដែលសមាជិកព្រឹទ្ធសភាបញ្ជូនមកព្រឹទ្ធសភា ។

បើក្នុងប្រភេទនីមួយៗមានបញ្ហាមានច្រើននោះ របៀបវារៈនៃបញ្ហាទាំងនោះត្រូវរៀបតាមលំដាប់នៃកាលបរិច្ឆេទដែលឯកសារចូលមកដល់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា លើកលែងតែមានការសម្រេចផ្សេងពីនេះ។

ជាទូទៅ ប្រធានគណៈកម្មការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអ្នកអានរបៀបវារៈសម្រាប់ការប្រជុំនីមួយៗ និងនៅពេលបញ្ចប់នៃការប្រជុំ ប្រធានអង្គប្រជុំត្រូវអានរបៀបវារៈសម្រាប់ពេលប្រជុំបន្ត។

- ការអនុម័ត បញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទៅគណៈកម្មការពិនិត្យសិក្សាតាមវិស័យជាសមត្ថកិច្ច
- ការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍លើកទី១ ផ្តោតសំខាន់ទៅលើ ៖

១. ទម្រង់ និងខ្លឹមសារសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដោយសម្រេចថា យល់ព្រម ឬមិនយល់ព្រម ។

២. សម្រេចបញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទៅគណៈកម្មការណាមួយ ឬច្រើន ដែលពាក់ព័ន្ធដើម្បីពិនិត្យសិក្សា ។

### ☛ ក្រោយពេលប្រជុំ

- លិខិតផ្លូវការ ចុះហត្ថលេខាដោយប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ ភ្ជាប់មកជាមួយអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ និងឯកសារពាក់ព័ន្ធមួយចំនួន រួចបញ្ជូនទៅគណៈកម្មការទទួលបន្ទុកដើម្បីពិនិត្យសិក្សា។(មើលឧបសម្ព័ន្ធ១១៖ លិខិតបញ្ជូនសេចក្តីព្រាងច្បាប់ទៅគណៈកម្មការទទួលបន្ទុកដើម្បីសិក្សា)
- មន្ត្រីនាយកដ្ឋាននីតិវិធី ធ្វើកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍(កំណត់ហេតុសង្ខេប និងពិស្តារ)។

❖ **ជំហានទី២៖ ដំណើរការពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដោយគណៈកម្មការទទួលបន្ទុក (តាមវិស័យជាសមត្ថកិច្ច)**

☛ **មុនពេលប្រជុំ**

ជាគោលការណ៍ ប្រធានគណៈកម្មការទទួលបន្ទុក គឺជាអ្នករាយការណ៍។ ថ្វីបើតួនាទីរបស់ប្រធានគណៈកម្មការជាអ្នករាយការណ៍ មិនមានចែងច្បាស់នៅក្នុងបទបញ្ជាផ្ទៃក្នុង ប៉ុន្តែប្រការ១៨ (ក) ប្រការ៣២ វាក្យខណ្ឌទី២ និងប្រការ៣៣ អាចយកមកប្រើសម្រាប់ធ្វើការបកស្រាយ។ ប្រធានគណៈកម្មការធ្វើការងារយ៉ាងជិតស្និទ្ធជាមួយមន្ត្រីលេខាធិការដ្ឋាន ដើម្បីរៀបចំផែនការសម្រាប់គណៈកម្មការក្នុងការសិក្សា និងពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។

▪ **ការរៀបចំលិខិតសុំយោបល់**

សមាជិកព្រឹទ្ធសភាគ្រប់រូបត្រូវផ្តល់យោបល់ថាតើ យល់ស្រប កែប្រែ ឬបដិសេធចោលទាំងស្រុងលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលគាត់បានទទួល។ ការឆ្លើយតបរបស់សមាជិកព្រឹទ្ធ-សភាមួយរូបៗ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយបង្ហាញនូវមូលហេតុក្នុងការកែប្រែ ឬការបដិសេធចោល។[53]

សមាជិកព្រឹទ្ធសភាធ្វើការសិក្សាស៊ីជម្រៅលើខ្លឹមសារទាំងមូលនៃអត្ថបទច្បាប់ ដោយផ្តោតលើបញ្ហានានាដែលទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការក្នុងក្របខណ្ឌភូមិភាគរបស់ខ្លួន។ ចំពោះច្បាប់ធម្មតា សមាជិកព្រឹទ្ធសភាត្រូវបញ្ជូនអនុសាសន៍អំពីអត្ថបទច្បាប់ក្នុងរយៈពេល៣ថ្ងៃ មុនការពិនិត្យសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់នៅគណៈកម្មការទទួលបន្ទុក។ ការពិនិត្យក្នុងគណៈកម្មការ ត្រូវអនុម័តនៅចំពោះមុខតំណាងរាជរដ្ឋាភិបាល។ រយៈពេលសម្រាប់ផ្តល់យោបល់គឺមិនឱ្យលើសពី ១ថ្ងៃមុនថ្ងៃប្រជុំ។[54]

---

[53] បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាព្រឹទ្ធសភា ឆ្នាំ២០១៧ ប្រការ៣២ វាក្យខណ្ឌទី២

[54] បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាព្រឹទ្ធសភា ឆ្នាំ២០១៧ ប្រការ៣២ វាក្យខណ្ឌទី៣

- **ការប្រមូលព័ត៌មានពីប្រភពផ្សេងៗ**

ទាំងមន្ត្រីលេខាធិការដ្ឋានអមគណៈកម្មការ និងសមាជិកព្រឹទ្ធសភាត្រូវដឹងច្បាស់អំពីដំណើរការរៀបចំសេចក្តីព្រាងច្បាប់ចាប់តាំងពីដើមដំបូងក្នុងកម្រិតក្រសួងសាមី រហូតដល់ការបញ្ជូនទៅដល់រដ្ឋសភា ដើម្បីពិភាក្សានិងអនុម័ត។ ដូចនេះ មន្ត្រីលេខាធិការដ្ឋានត្រូវប្រមូលព័ត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ មកពីប្រភពផ្សេងៗឱ្យបានទូលំទូលាយ។ ព័ត៌មានទាំងនោះអាចដកស្រង់ពីកាសែត ទស្សនាវដ្តី គេហទំព័រ និងញត្តិរបស់ក្រុមផលប្រយោជន៍ណាមួយ។ ព័ត៌មានដែលប្រមូលបានអាចជួយដល់សមាជិក ក៏ដូចជាប្រធានគណៈកម្មការសម្រាប់ជាមូលដ្ឋានក្នុងការសម្រេចចិត្តទាំងផ្នែកបច្ចេកទេស និងទស្សនៈនយោបាយលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។ ក្រៅពីព័ត៌មានពីប្រភពខាងលើនេះ នៅមានមធ្យោបាយសំខាន់មួយទៀតក្នុងការប្រមូលព័ត៌មានគឺការរៀបចំកិច្ចពិគ្រោះយោបល់ជាសាធារណៈ និងការធ្វើសវនការជាសាធារណៈជាដើម។

- **កិច្ចពិគ្រោះយោបល់ជាសាធារណៈ និងសវនាការជាសាធារណៈ**

កិច្ចពិគ្រោះយោបល់ជាសាធារណៈត្រូវបានគេចាត់ទុកថា ជាវិធីសាស្ត្រដ៏ល្អក្នុងការប្រមូលធាតុចូលមកពីសាធារណជនគ្រប់កម្រិត។ ប្រសិនបើចាំបាច់ ប្រធានគណៈកម្មការអាចសម្រេចដើម្បី រៀបចំវេទិកាមួយ ដោយអញ្ជើញតំណាងសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋមកចូលរួម ហើយពួកគេអាចលើកឡើងនូវកង្វល់មួយចំនួនទាក់ទងនឹងសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នៅក្នុងវេទិកានេះ។ ប្រធានគណៈកម្មការដើរតួសំខាន់ក្នុងការសម្របសម្រួលក្នុងសិក្ខាសាលានេះ ហើយមន្ត្រីលេខាធិការដ្ឋានកត់ត្រាព័ត៌មានសំខាន់ៗ និងសំណួរមួយចំនួនសម្រាប់សាកសួរបន្តទៅតំណាងរាជរដ្ឋាភិបាលឱ្យបំភ្លឺ។

ដូចគ្នានេះដែរ សវនការជាសាធារណៈភាគច្រើនបំផុតត្រូវបានធ្វើឡើងនៅក្នុងកម្រិតចង្អៀតរវាងសមាជិកគណៈកម្មការ និងអ្នកជំនាញតែប៉ុណ្ណោះ។ ក្នុងកិច្ចប្រជុំផ្ទៃក្នុង ប្រធានគណៈកម្មការអាចអញ្ជើញអ្នកជំនាញពាក់ព័ន្ធផ្សេងៗគ្នា ដើម្បីផ្តល់ព័ត៌មានលម្អិត និងបំភ្លឺអំពីបញ្ហាទាំងឡាយដែលមាននៅក្នុងសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។

ប្រការ១៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាមានខ្លឹមសារគ្រប់គ្រាន់ ដើម្បីប្រគល់សិទ្ធិឱ្យប្រធានគណៈកម្មការរៀបចំវេទិកាខាងលើនេះ ក្នុងក្របខណ្ឌនៃការចូលរួមផ្នែកនយោបាយ មកពីបណ្ដាសាធារណជនគ្រប់កម្រិតទាំងអស់ក្នុងសង្គម។

- **ការរៀបចំរបាយការណ៍ព្រាង**

ប្រធានគណៈកម្មការទទួលបន្ទុក និងមន្ត្រីលេខាធិការដ្ឋានធ្វើការរួមគ្នាដើម្បីរៀបចំនូវរបាយការណ៍ព្រាងមួយសម្រាប់គណៈកម្មការ។ ព័ត៌មានដ៏ទូលំទូលាយដែលបានប្រមូលមកពីប្រភពដ៏គួរឱ្យទុកចិត្ត គឺជាមូលដ្ឋានដ៏រឹងមាំ សម្រាប់គណៈកម្មការធ្វើការសម្រេចចិត្តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ និងការបង្ហាញជំហរនយោបាយនៅក្នុងរបាយការណ៍។

## ☛ អំឡុងពេលប្រជុំ

- **កិច្ចពិភាក្សាក្នុងគណៈកម្មការ**

សមាជិកព្រឹទ្ធសភា តំណាងឱ្យគណៈកម្មការនានា អាចចូលរួមប្រជុំពិភាក្សាលើបញ្ហាផ្សេងៗជាមួយគណៈកម្មការទទួលបន្ទុក និងតំណាងរាជរដ្ឋាភិបាលដែលមកការពារសេចក្តីព្រាងច្បាប់។ ក្នុងកិច្ចប្រជុំគណៈកម្មការ អាចមានការកែប្រែខ្លះៗក្នុងសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។ សំណើវិសោធនកម្មមួយចំនួន អាចត្រូវបានលើកឡើងក្នុងវេទិកានេះ ហើយបើគណៈកម្មការ និងម្ចាស់សេចក្តីព្រាងច្បាប់ ឬម្ចាស់សេចក្តីស្នើច្បាប់មានគំនិតស្របគ្នា គេអាចកែសម្រួលខ្លឹមសារខ្លះៗនៃបទប្បញ្ញត្តិព្រមទាំងទម្រង់អត្ថបទច្បាប់ដែលកំពុងពិនិត្យរួមគ្នា។

របាយការណ៍ព្រាងនឹងត្រូវបានធ្វើការកែសម្រួលឡើងវិញ បន្ទាប់ពីកិច្ចប្រជុំគណៈកម្មការ និងត្រូវរៀបចំឱ្យរួចរាល់សម្រាប់ប្រធានគណៈកម្មការរាយការណ៍ នៅក្នុងកិច្ចប្រជុំគណៈកម្មការអចិន្ត្រៃយ៍លើកទី២។

- **ក្រោយពេលប្រជុំ**
  - បន្ទាប់ពីការសិក្សាស្រាវជ្រាវសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ចប់ មន្ត្រីជំនួយការគណៈកម្មការទទួលបន្ទុក មានភារកិច្ចធ្វើកំណត់ហេតុ និងរបាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាស្រាវជ្រាវ
  - ក្រោយពេលដែលប្រធានគណៈកម្មការទទួលបន្ទុក បានពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ឬសំណើសុំកែសម្រួលចប់សព្វគ្រប់ ប្រធានគណៈកម្មការទទួលបន្ទុក ត្រូវធ្វើលិខិតស្នើសុំមកប្រធានព្រឹទ្ធសភា ដើម្បីរាយការណ៍អំពីលទ្ធផលនៃការពិនិត្យសិក្សា ស្រាវជ្រាវលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដោយស្នើសុំដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃសម័យប្រជុំពេញអង្គព្រឹទ្ធសភា។ (មើលឧបសម្ព័ន្ធ១២៖ លិខិតរបស់គណៈកម្មការទទួលបន្ទុកស្នើសុំបញ្ចូលក្នុងរបៀបវារៈនៃកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា)

❖ **ជំហានទី៣ ៖ ដំណើរការពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទទួលបន្ទុក សុំដាក់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទៅក្នុងរបៀបវារៈ នៃអង្គប្រជុំព្រឹទ្ធសភា(គណៈកម្មាធិការអចិន្ត្រៃយ៍លើកទី២**)

- **មុនពេលប្រជុំ**

នាយកដ្ឋាននីតិវិធី ត្រូវបន្តការងារមួយចំនួនទៀត ដូចខាងក្រោម ៖

- ធ្វើលិខិតអញ្ជើញប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍លើកទី២ (មើលឧបសម្ព័ន្ធ១៣៖ លិខិតអញ្ជើញប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍លើកទី២ )
- ថតចម្លងរបាយការណ៍របស់គណៈកម្មការទទួលបន្ទុក ដើម្បីចែកជូនសមាជិក សមាជិកាគណៈកម្មាធិការអចិន្ត្រៃយ៍
- ធ្វើជំនួយស្មារតីដឹកនាំអង្គប្រជុំ សម្រាប់ប្រធានអង្គប្រជុំ ។

## ☛ អំឡុងពេលប្រជុំ

- **ការពិនិត្យក្រុម**

ការពិនិត្យក្រុមត្រូវធ្វើឡើងដូចគ្នានឹងកិច្ចប្រជុំលើកទី១។ បន្ទាប់មក ប្រធានគណៈកម្មការទទួលបន្ទុក រាយការណ៍អំពីលទ្ធផលនៃការពិនិត្យសិក្សារបស់ខ្លួន ជូនអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។ ចុងក្រោយ អង្គប្រជុំត្រូវអនុម័តថា តើគួរដាក់ ឬមិនដាក់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ ទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា។

របៀបវារៈមានជាលំដាប់មុនក្រោយ ប្រសិនបើប្រភេទនីមួយៗមានបញ្ហាច្រើននោះ របៀបវារៈនៃបញ្ហាទាំងនោះ ត្រូវរៀបតាមលំដាប់កាលបរិច្ឆេទនៃការចូលមកដល់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា លើកលែងតែមានការសម្រេចផ្សេងពីនេះ។

នៅចុងបញ្ចប់នៃការប្រជុំ ប្រធានអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍(លើកទី២) ត្រូវអានរបៀបវារៈសម្រាប់ពេលប្រជុំបន្ត។

## ☛ ក្រោយពេលប្រជុំ

- ធ្វើសេចក្តីប្រកាសព័ត៌មាន សម្រាប់ជូនដំណឹងដល់សាធារណជន អំពីលទ្ធផលនៃកិច្ចប្រជុំ។ សេចក្តីប្រកាសព័ត៌មាន ក៏បានបង្ហាញអំពីរបៀបវារៈដែលត្រូវពិភាក្សា ក្នុងកិច្ចប្រជុំព្រឹទ្ធសភានាពេលខាងមុខផងដែរ។ (មើលឧបសម្ព័ន្ធ១៤ ៖ សេចក្តីប្រកាសព័ត៌មានអំពីលទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍លើកទី២)
- ធ្វើកំណត់ហេតុនៃកិច្ចប្រជុំ (កំណត់ហេតុសង្ខេប និងពិស្តារ)។

## ❖ ជំហានទី៤ ៖ ដំណើរការពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ក្នុងអង្គប្រជុំព្រឹទ្ធសភា

### ☛ មុនពេលប្រជុំ

#### ▪ ផ្ញើលិខិតអញ្ជើញ

ក្រោយពីកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍លើកទី២ បានបញ្ចប់ នាយកដ្ឋាននីតិវិធីមានការងារចំនួនទៀត ដូចខាងក្រោម ៖

- ផ្ញើលិខិតអញ្ជើញសមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា (មើលឧបសម្ព័ន្ធ១៥ ៖លិខិតអញ្ជើញប្រជុំពេញអង្គព្រឹទ្ធសភា)
- ផ្ញើលិខិតអញ្ជើញតំណាងរាជរដ្ឋាភិបាលមកការពារសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ក្នុងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា (មើលឧបសម្ព័ន្ធ១៦ ៖ លិខិតអញ្ជើញតំណាងរាជរដ្ឋាភិបាលមកបំភ្លឺលើសេចក្តីព្រាងច្បាប់)
- ផ្ញើលិខិតអញ្ជើញរដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ឬតំណាងក្រសួង មកចូលរួមតាមដានស្តាប់ក្នុងកិច្ចប្រជុំពេញអង្គនៃព្រឹទ្ធសភា
- ផ្ញើជំនួយស្មារតីដឹកនាំអង្គប្រជុំ សម្រាប់ប្រធានអង្គប្រជុំព្រឹទ្ធសភា
- ថតចម្លងរបាយការណ៍របស់គណៈកម្មការទទួលបន្ទុក ដើម្បីចែកជូនគ្រប់សមាជិក សមាជិកាព្រឹទ្ធសភា ។

ម្ចាស់សេចក្តីព្រាងច្បាប់ ឬម្ចាស់សេចក្តីស្នើច្បាប់ ត្រូវបានអញ្ជើញចូលរួម ក្នុងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា ដើម្បីឆ្លើយបំភ្លឺលើបញ្ហានានា ដែលពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។

## ☛ អំឡុងពេលប្រជុំ

មានមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួនបួនក្រុម សម្រាប់ផ្តល់សេវាការងារក្នុងសាលប្រជុំពេញអង្គ មាន ៖

ក្រុមទី១ មន្ត្រីនាយកដ្ឋានពិធីការ ៖ ទទួលបន្ទុកអញ្ជើញសមាជិក សមាជិកាព្រឹទ្ធសភា តំណាងរាជរដ្ឋាភិបាល និងភ្ញៀវជាតិ ឬ ភ្ញៀវអន្តរជាតិ ទៅអាសនៈ។

ក្រុមទី២ មន្ត្រីនាយកដ្ឋានរដ្ឋបាល ៖ ទទួលបន្ទុកស្រង់វត្តមាន និងអវត្តមានរបស់សមាជិក សមាជិកាព្រឹទ្ធសភា ។

ក្រុមទី៣ មន្ត្រីនាយកដ្ឋានព័ត៌មាន ៖ ទទួលបន្ទុកថតវីដេអូ ផ្សព្វផ្សាយព័ត៌មាន និងប្រកាសលទ្ធផលនៃកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា។

ក្រុមទី៤ មន្ត្រីនាយកដ្ឋាននីតិវិធី ៖ ទទួលបន្ទុកផ្តល់ឯកសារពាក់ព័ន្ធនានាដែលទាក់ទងនឹងរបៀបវារៈប្រជុំ ជួយលេខាធិការអង្គប្រជុំ ក្នុងការរាប់ចំនួនវត្តមាន និងកូរ៉ុម រាប់ចំនួនសំឡេងអនុម័ត និងធ្វើកំណត់ហេតុ ។

អគ្គលេខាធិការ មានវត្តមានជានិច្ចនៅក្នុងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា ដើម្បីដឹកនាំមន្ត្រី ក្នុងការបម្រើសេវាជូនអង្គព្រឹទ្ធសភា។ ក្រៅពីមន្ត្រីទាំងបួនក្រុម ដូចបានរៀបរាប់ខាងលើ នៅមានលេខាធិការអង្គប្រជុំដែលជាសមាជិកព្រឹទ្ធសភា ជួយប្រធានព្រឹទ្ធសភាក្នុងសម័យប្រជុំព្រឹទ្ធសភានីមួយៗ ក្នុងការពិនិត្យចំនួនវត្តមាន និងកូរ៉ុម នៅពេលចាប់ផ្តើមកិច្ចប្រជុំ និងនៅពេលអនុម័ត និងចាត់ចែងការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការចុះហត្ថលេខាលើកំណត់ហេតុប្រជុំ។

ជាទម្លាប់ នៅពេលដល់ម៉ោងប្រជុំពេញអង្គ ស្នូរកណ្តឹងបន្លឺឡើង ប្រធានព្រឹទ្ធសភា ឬប្រធានអង្គប្រជុំ អមដំណើរដោយអនុប្រធានទី១ និងអនុប្រធានទី២ ព្រមទាំងអគ្គលេខាធិការព្រឹទ្ធសភាអញ្ជើញចូលក្នុងសាលប្រជុំ។

- **ការពិនិត្យកូរ៉ុម**

ជាទូទៅ កិច្ចប្រជុំពេញអង្គព្រឹទ្ធសភា អាចយកជាការបានលុះត្រាតែមានកូរ៉ុមប្រជុំលើសពីពាក់កណ្តាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកសំឡេងភាគច្រើនដាច់ខាត ឬសំឡេងភាគច្រើនដោយប្រៀបនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។ ជាគោលការណ៍ កូរ៉ុមត្រូវមានគ្រប់ចំនួនក្នុងពេលចាប់ផ្តើមប្រជុំ និងក្នុងពេលអនុម័ត។ ប្រសិនបើមិនមានកូរ៉ុមគ្រប់ចំនួនក្នុងរយៈពេល ៣០នាទី ចាប់តាំងពីពេលចាប់ផ្តើម ប្រធានអង្គប្រជុំអាចលើកពេលប្រជុំ។ កិច្ចប្រជុំពេញអង្គ ដែលគ្មានប្រធានដឹកនាំ មិនអាចដំណើរការបានឡើយ។

ជាក់ស្តែង ប្រធានអង្គប្រជុំ ស្នើឱ្យលេខាធិការអង្គប្រជុំត្រួតពិនិត្យវត្តមាន និងកូរ៉ុម រួចរាយការណ៍ជូនអង្គប្រជុំព្រឹទ្ធសភា ។

- **ការប្រកាស និងអនុម័តរបៀបវារៈ**

ប្រសិនបើមានចំនួនសមាជិក សមាជិកាព្រឹទ្ធសភាគ្រប់ចំនួន ដែលអាចដំណើរការអង្គប្រជុំបាន ប្រធានអង្គប្រជុំស្នើឱ្យសមាជិកព្រឹទ្ធសភាទាំងអស់ អនុម័តរបៀបវារៈដោយនិយាយថា ***«ប្រសិនបើឯកឧត្តម លោកជំទាវ យល់ព្រម សូមមេត្តាលើកដៃ...»*** ។ ភ្លាមនោះ លេខាធិការអង្គប្រជុំ រាប់ចំនួនសំឡេងអនុម័ត និងរាយការណ៍ជូនអង្គព្រឹទ្ធសភា។

- **ការបង្ហាញរបាយការណ៍របស់គណៈកម្មការទទួលបន្ទុក**

ក្រោយពីទទួលបានការអនុម័តយល់ព្រមពីអង្គប្រជុំលើរបៀបវារៈ ដែលត្រូវលើកយកមកពិនិត្យ និងឱ្យយោបល់ ប្រធានអង្គប្រជុំស្នើប្រធានគណៈកម្មការទទួបន្ទុក រាយការណ៍អំពីលទ្ធផលនៃការពិនិត្យសិក្សា។

ការពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ក្នុងកិច្ចប្រជុំពេញអង្គ ត្រូវចាប់ផ្តើមឡើងដោយការបង្ហាញរបាយការណ៍របស់គណៈកម្មការទទួលបន្ទុក។ របាយការណ៍របស់គណៈកម្មការទទួលបន្ទុក បង្ហាញអំពីលទ្ធផលនៃការសិក្សាស៊ីជម្រៅរបស់ខ្លួន លើសេចក្តីព្រាងច្បាប់ ឬ

សេចក្តីស្នើច្បាប់ ដោយបានដាក់បញ្ចូលនូវខ្លឹមសារសំខាន់ៗទៅក្នុងសេចក្តីសន្និដ្ឋានរួម ដែលជាផ្នែកបញ្ចប់នៃរបាយការណ៍។

- **ការជជែកពិភាក្សា**

សមាជិកព្រឹទ្ធសភាម្នាក់ៗ មានសិទ្ធិសុំបញ្ចេញយោបល់របស់ខ្លួននៅក្នុងអង្គប្រជុំបាន។ ដើម្បីអាចមានយោបល់បាន សមាជិកព្រឹទ្ធសភាម្នាក់ៗ ត្រូវសុំការអនុញ្ញាតពីប្រធានក្រុមសមាជិកព្រឹទ្ធសភាជាមុនសិន រួចជូនទៅលេខាធិការអង្គប្រជុំ ដើម្បីលេខាធិការអង្គប្រជុំបញ្ជូនទៅប្រធានអង្គប្រជុំ។ ជាក់ស្តែង ចំពោះការស្នើសុំបញ្ចេញមតិយោបល់របស់សមាជិកព្រឹទ្ធសភា ត្រូវបំពេញនៅលើទម្រង់ដែលមានស្រាប់។ (មើលឧបសម្ព័ន្ធ១៧ ៖ពាក្យស្នើសុំមានមតិយោបល់ក្នុងអង្គប្រជុំព្រឹទ្ធសភា)

លេខាធិការអង្គប្រជុំ ត្រូវកត់ឈ្មោះសមាជិកព្រឹទ្ធសភាក្នុងក្រុមនីមួយៗ ដែលសុំបញ្ចេញយោបល់តាមលំដាប់មុនក្រោយ ហើយបញ្ជូនទៅប្រធានព្រឹទ្ធសភា (ប្រធានអង្គប្រជុំ)។

អាសនានុក្រមរបស់សមាជិកព្រឹទ្ធសភា ត្រូវរៀបតាមក្រុមសមាជិកព្រឹទ្ធសភានីមួយៗ។ ក្រុមនីមួយៗ ត្រូវមានសមាជិកយ៉ាងតិច១០រូប។ សមាជិកព្រឹទ្ធសភា១រូប អាចចូលជាសមាជិកក្រុមបានតែមួយប៉ុណ្ណោះ។ ក្រុមនីមួយៗ ត្រូវមានប្រធាន១រូប និងអនុប្រធាន១រូប។

សមាជិកព្រឹទ្ធសភាចាត់តាំងដោយព្រះមហាក្សត្រ ជ្រើសតាំងដោយរដ្ឋសភា និងគណបក្សនយោបាយដែលមានអាសនៈតិចជាងដប់ អាចជ្រើសរើសចូលជាមួយក្រុមណាមួយ តាមការពេញចិត្តរបស់ខ្លួន។ បញ្ជីរាយនាមរបស់ក្រុមសមាជិកព្រឹទ្ធសភា ត្រូវផ្ញើជូនប្រធានព្រឹទ្ធសភា។

ក្រុមសមាជិកព្រឹទ្ធសភានីមួយៗត្រូវបំពេញតួនាទីរៀងៗខ្លួន ដើម្បីប្រមូលផ្តុំរាល់បញ្ញាញាណនយោបាយក្នុងការបញ្ចេញមតិយោបល់នៅក្នុងកិច្ចប្រជុំពេញអង្គនៃព្រឹទ្ធសភា។ ពហុនិយមខាងនយោបាយនៃក្រុមសមាជិកព្រឹទ្ធសភាទាំងអស់ត្រូវអនុវត្តដោយសេចក្តីថ្លៃថ្នូរ មានគុណធម៌ និងសុជីវធម៌ ក្នុងក្របខណ្ឌនៃក្រមសីលធម៌សមាជិកព្រឹទ្ធសភា ដោយមិនរំលោភបំពាន និងគ្មានការរើសអើងស្របតាមលក្ខន្តិកៈរបស់សមាជិកព្រឹទ្ធសភាដែលតំណាងឱ្យភូមិភាគ និងប្រជាជាតិខ្មែរទាំងមូល។

ក្រុមសមាជិកព្រឹទ្ធសភា មានភារកិច្ចរួមគ្នាក្នុងការពិភាក្សា និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដោយរៀបចំតំណាងក្រុមមួយរូបថ្លែងយោបល់ក្នុងនាមក្រុម នៅក្នុងកិច្ចប្រជុំព្រឹទ្ធសភា ដោយប្រកាន់ជំហររួមរបស់ក្រុម។

ជាគោលការណ៍ រយៈពេលបញ្ចេញយោបល់សម្រាប់ក្រុមសមាជិកព្រឹទ្ធសភានីមួយៗ ត្រូវបានកំណត់។ សមាជិកព្រឹទ្ធសភាតំណាងក្រុមនីមួយៗដែលបានសុំចុះឈ្មោះដើម្បីបញ្ចេញយោបល់ អាចនិយាយបាន២០នាទីយ៉ាងយូរ និងអាចឆ្លើយវិញបានត្រឹមតែ៥នាទីប៉ុណ្ណោះ។ បើប្រធានព្រឹទ្ធសភាយល់ថា ជាការចាំបាច់ ឬមានប្រយោជន៍ក្នុងការពិភាក្សា ប្រធានអាចអនុញ្ញាតបន្ថែមរយៈពេល១០នាទីទៀត ហើយការបន្ថែមខាងលើនេះអាចបន្តពីរដងបានក្នុងប្រធានបទតែមួយ។ សមាជិកក្នុងក្រុមតែមួយ មានសិទ្ធិសុំបញ្ចេញមតិបន្ថែមក្នុងប្រធានបទដដែលបាន គឺគិតក្នុងរយៈពេលដែលនៅសល់ពីការកំណត់ខាងលើ។ តំណាងក្រុមសមាជិកព្រឹទ្ធសភា ដែលត្រូវបានអនុញ្ញាតឱ្យបញ្ចេញយោបល់ ត្រូវមានយោបល់តែអំពីរឿងដែលកំពុងពិភាក្សា។ បើបញ្ចេញយោបល់ចាកប្រធាន ប្រធានអង្គប្រជុំត្រូវរំលឹកឱ្យចូលមកក្នុងប្រធានបទវិញ។ ក្នុងករណីដែលវាគ្មិនរូបនោះ នៅតែចចេសបញ្ចេញយោបល់ក្រៅប្រធានបទ ប្រធានអង្គប្រជុំមានសិទ្ធិបញ្ឈប់មិនឱ្យនិយាយបន្តទៀតបាន។

<u>បញ្ជាក់</u> ៖ បទប្បញ្ញត្តិអំពីការសុំចុះឈ្មោះបញ្ចេញយោបល់ និងការកំណត់រយៈពេលបញ្ចេញយោបល់ខាងលើ គឺប្រើសម្រាប់តែសមាជិកព្រឹទ្ធសភាតែប៉ុណ្ណោះ មិនយកមកប្រើចំពោះតំណាងរាជរដ្ឋាភិបាល សមាជិករដ្ឋសភា ឬម្ចាស់សេចក្តីស្នើច្បាប់ អ្នកជំនាញការពារសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងនោះទេ។

### ➥ ក្រោយពេលប្រជុំ

- អគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ ធ្វើសេចក្តីប្រកាសព័ត៌មានអំពីលទ្ធ-ផលនៃសម័យប្រជុំពេញអង្គព្រឹទ្ធសភា ដើម្បីផ្សព្វផ្សាយជូនសាធារណជន។ (មើលឧបសម្ព័ន្ធ១៨៖ សេចក្តីប្រកាសព័ត៌មានអំពីលទ្ធផលនៃកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា)
- អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី ធ្វើលិខិតផ្លូវការ មានចុះហត្ថលេខាដោយប្រធានអង្គប្រជុំព្រឹទ្ធសភា បញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទៅរដ្ឋសភា។ (មើល

ឧបសម្ព័ន្ធ១៩៖ លិខិតជូនដំណឹងទៅប្រធានរដ្ឋសភាអំពីការពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ )

- ធ្វើកំណត់កំណត់ហេតុនៃកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា (កំណត់ហេតុសង្ខេប និងពិស្តារ)។

គំនូសបំព្រួញទី២ ៖ ការពិនិត្យ និងឱ្យយោបល់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នៅព្រឹទ្ធសភា



# ៣. សេវាគាំទ្ររបស់រដ្ឋសភា និងព្រឹទ្ធសភា

## ៣.១. អគ្គលេខាធិការដ្ឋានរដ្ឋសភា

អគ្គលេខាធិការដ្ឋានរដ្ឋសភា ត្រូវបានរៀបចំឡើងដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ មានតួនាទីជាសេនាធិការផ្ទាល់របស់រដ្ឋសភា ផ្តល់សេវាទ្រទ្រង់លើការងារទូទៅ ដើម្បីធានាឱ្យបាននូវនិរន្តរភាពនៃកិច្ចការនានារបស់រដ្ឋសភា ស្របតាមរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងច្បាប់ពាក់ព័ន្ធជាធរមាន[55]។

អគ្គលេខាធិការដ្ឋានរដ្ឋសភាបានធ្វើការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់ខ្លួនឱ្យស្របនឹងស្ថានភាព និងទំហំការងារចាំបាច់ដើម្បីបង្កើនប្រសិទ្ធភាពការងារជូនសមាជិកា សមាជិករដ្ឋសភា ក៏ដូចជាគណៈកម្មការជំនាញនានា។ អគ្គលេខាធិការដ្ឋានរដ្ឋសភា មានអង្គភាពចំណុះមួយចំនួនដូចជា អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋាននីតិកម្មនិងស្រាវជ្រាវ អគ្គនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ពិធីការ និងព័ត៌មាន អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ អគ្គាធិការដ្ឋាន អង្គភាពលទ្ធកម្ម នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានសន្តិសុខ និងការិយាល័យលេខាធិការ។ តាមរចនាសម្ព័ន្ធនេះ គេសង្កេតឃើញមានសេវាគាំទ្រពីរផ្នែកធំៗគឺសេវាគាំទ្រខាងមធ្យោបាយនិងផ្គត់ផ្គង់ និងសេវាគាំទ្រខាងនីតិវិធី និងស្រាវជ្រាវ។

ដើម្បីធានាបានលើការផ្តល់សេវាគាំទ្រមុខងារនីតិកម្មរបស់រដ្ឋសភា អគ្គនាយកដ្ឋានទាំងអស់នឹងអង្គភាពដទៃទៀតបានបំពេញការងារដោយឡែកៗពីគ្នាស្របតាមមុខងារ និងភារកិច្ចរបស់ខ្លួន ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី២ នៃសេចក្តីសម្រេចលេខ៦៧ របស់រដ្ឋសភា ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីបេសកកម្មរបស់អគ្គលេខាធិការដ្ឋានរដ្ឋសភា។

ដូចបានលើកមកបរិយាយនៅក្នុង ចំណុច (IV, ១) ជាក់ស្តែង មន្ត្រីរាជការអង្គភាពមួយចំនួនដែលមានភារកិច្ចពាក់ព័ន្ធចាំបាច់ក្នុងការផ្តល់សេវាផ្សេងៗនៅក្នុងកិច្ចប្រជុំនានារបស់រដ្ឋសភា ទាំងសេវាបច្ចេកទេស នីតិវិធី និងឯកសារ គឺបានបង្ហាញចាប់ពីជំហានទី១ដល់ជំហានទី៤។

ខាងក្រោមនេះ គឺជាការបង្ហាញដោយខ្លីៗអំពីតួនាទី និងភារកិច្ចរបស់នាយកដ្ឋានពាក់ព័ន្ធនានាដែលជួយលើកិច្ចការនីតិកម្មរបស់រដ្ឋសភា ជាអាទិ៍ ៖

---

[55] សេចក្តីសម្រេចលេខ ០៦៧ រស ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦

**នាយកដ្ឋាននីតិវិធី** មានតួនាទី និងភារកិច្ចទទួលខុសត្រូវលើការផ្តល់សេវានីតិកម្ម នីតិវិធី ឯកសារគតិយុត្ត និងរៀបចំកំណត់ហេតុសម្រាប់កិច្ចប្រជុំរបស់រដ្ឋសភា និងសមាជរដ្ឋសភា និងព្រឹទ្ធសភា។

**នាយកដ្ឋានស្រាវជ្រាវច្បាប់** មានតួនាទី និងភារកិច្ចស្រាវជ្រាវ ចងក្រង គ្រប់គ្រង និងថែរក្សាឯកសារសំខាន់ៗទាំងឡាយរបស់រដ្ឋសភា និងផ្តល់សេវាឯកសារផ្សេងៗជូនគណៈកម្មការនានា តំណាងរាស្ត្រ និង អគ្គលេខាធិការដ្ឋាននៃរដ្ឋសភា។

**នាយកដ្ឋានស្រាវជ្រាវកិច្ចការជាតិ** មានតួនាទី និងភារកិច្ចក្នុងការសិក្សា ស្រាវជ្រាវ វិភាគ និងផ្តល់ព័ត៌មានទាក់ទងនឹងវិស័យជាតិ និងកសាងឯកសារស្រាវជ្រាវតាមឯកទេសជំនាញ និងឯកសារជំនួយស្មារតីសម្រាប់បម្រើសេចក្តីត្រូវការរបស់រដ្ឋសភា និងអគ្គេលខាធិការដ្ឋាន។

**នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ** មានតួនាទី និងភារកិច្ចផ្តល់ការសិក្សាស្រាវជ្រាវ វិភាគ ផ្តល់យោបល់ និងព័ត៌មានលើការងាររបស់រដ្ឋសភា រួមមាន កិច្ចការអន្តរសភា កិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី និងការទូតរបស់សភា សម្រាប់បម្រើសេចក្តីត្រូវការរបស់រដ្ឋសភា និងអគ្គលេខាធិការដ្ឋាន។

### ៣.២. អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាត្រូវបានកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា[56]។ អគ្គលេខាធិការដ្ឋាន ទទួលរ៉ាប់រងរាល់កិច្ចការរដ្ឋបាល សន្តិសុខ និងសេវាទាំងឡាយរបស់ព្រឹទ្ធសភា ព្រមទាំងទំនាក់ទំនងផ្សេងៗក្រៅព្រឹទ្ធសភា ក្រោមការដឹកនាំ និងត្រួតពិនិត្យរបស់ប្រធានព្រឹទ្ធសភា។

អគ្គលេខាធិការដ្ឋាន មានភារកិច្ចរៀបចំគម្រោងថវិកាប្រចាំឆ្នាំ បែបបទចំណាយថវិកា និងទទួលខុសត្រូវធ្វើរបាយការណ៍ចំណាយថវិការបស់ព្រឹទ្ធសភា ដែលឆ្លងកាត់ការពិនិត្យដោយគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម (គណៈកម្មការទី២) ដោយមានការចូលរួមពីតំណាងមកពីគណៈកម្មការនានា មុននឹងដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាពិនិត្យសម្រេច។

ចាប់ពីចុងនីតកាលទី២ នៃព្រឹទ្ធសភា អគ្គលេខាធិការដ្ឋាន មានរចនាសម្ព័ន្ធចែកជាបីអគ្គនាយកដ្ឋាន និងមានអគ្គាធិការដ្ឋានមួយ។ មកដល់ខែឧសភា ឆ្នាំ២០២០ តាមសេចក្តីសម្រេចលេខ : ០២៧/

[56] បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ប្រការ២៧ ដល់ ប្រការ៣១

០៥២០/ពស/សរ.ខលអ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវបានកែសម្រួលឡើងវិញ ដើម្បីឆ្លើយតបនឹងស្ថានភាព និងទំហំការងារចាំបាច់របស់ព្រឹទ្ធសភា។ តាមរចនាសម្ព័ន្ធថ្មីនេះ អគ្គលេខាធិការដ្ឋាន មានអគ្គនាយកដ្ឋានចំនួនប្រាំ និងមានអគ្គាធិការដ្ឋានមួយ ។ អគ្គនាយកដ្ឋានទាំងប្រាំ មានដូចជា អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី អគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ អគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ និងអគ្គនាយកដ្ឋានស្រាវជ្រាវ[57]។

អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី មានតួនាទីផ្ដល់សេវាបច្ចេកទេស នីតិវិធី កំណត់ហេតុប្រជុំ សេវាឯកសារគតិយុត្ត ទិន្នន័យច្បាប់ និងសេវាទ្រទ្រង់សកម្មភាពរបស់គណៈកម្មការ និងក្រុមនានារបស់ព្រឹទ្ធសភា។ អគ្គនាយកដ្ឋានមានភារកិច្ចសំខាន់ៗ ដូចខាងក្រោម ៖

- រៀបចំប្រតិទិនការងារ របៀបវារៈ នីតិវិធី ដំណើរការកិច្ចប្រជុំ និងធ្វើកំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភា

- តាក់តែងឯកសារគតិយុត្ត និងលិខិតផ្សេងៗពាក់ព័ន្ធនឹងកិច្ចដំណើរការ និងលទ្ធផលកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ សម័យប្រជុំព្រឹទ្ធសភា គណៈកម្មការ និងក្រុមនានារបស់ព្រឹទ្ធសភា ព្រមទាំងលិខិតឆ្លើយឆ្លងរបស់ថ្នាក់ដឹកនាព្រឹទ្ធសភាក្នុងក្របខ័ណ្ឌការងារនៃវិស័យជំនាញ

- ផ្គត់ផ្គង់ឯកសារគតិយុត្ត និងទិន្នន័យច្បាប់

- ជាសេនាធិការរបស់អគ្គលេខាធិការ និងលេខាធិការសម័យប្រជុំក្នុងពេលប្រជុំនីមួយៗ

- ធ្វើកំណត់ហេតុ ឬរបាយការណ៍ស្ដីពីលទ្ធផលនៃកិច្ចប្រជុំ ជំនួបពិភាក្សាការងារ ការរៀបចំវេទិកា សិក្ខាសាលា កិច្ចពិគ្រោះយោបល់ និងបេសកកម្មរបស់គណៈកម្មការ និងក្រុមនានារបស់ព្រឹទ្ធសភា

- ផ្ដល់សេវារដ្ឋបាល បច្ចេកទេសគតិយុត្ត និងព័ត៌មានជូនគណៈកម្មការ និងក្រុមនានារបស់ព្រឹទ្ធសភា

[57] សេចក្ដីសម្រេចលេខ ០២៧/០៥២០/ពស/សរ.ខលអ

- ធ្វើរបាយការណ៍ពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងរបស់គណៈកម្មការទាំង១០

- សិក្សាវិភាគ និងរៀបចំតារាងសង្ខេបស្តីពីវឌ្ឍនភាពការងាររបស់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលតាមវិស័យ និងធ្វើរបាយការណ៍តាមវិស័យរបស់គណៈកម្មការនានា

- រៀបចំជំនួបពិភាក្សាការងាររបស់គណៈកម្មការ និងក្រុមនានាជាមួយក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល រៀបចំវេទិកា សិក្ខាសាលា កិច្ចពិគ្រោះយោបល់ និងពិធីសំណេះសំណាលផ្សេងៗនៅតាមភូមិភាគ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ល។

ក្នុងការផ្តល់សេវាលើមុខងារនីតិកម្ម នាយកដ្ឋាននីតិវិធី គឺជាអង្គភាពស្នូលដែល មានតួនាទីផ្តល់សេវានីតិវិធីនៃដំណើរការប្រជុំ ឯកសារគតិយុត្ត ធ្វើកំណត់ហេតុប្រជុំ និងឯកសារផ្សេងៗពាក់ព័ន្ធនឹងការសម្រេចនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភា។ នាយកដ្ឋានមានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- រៀបចំប្រតិទិនការងារប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភា

- រៀបចំបែបបទ នីតិវិធី និងផ្គត់ផ្គង់ឯកសារផ្សេងៗពាក់ព័ន្ធនឹងរបៀបវារៈប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភា

- កសាងឯកសារគតិយុត្ត និងឯកសារផ្សេងៗពាក់ព័ន្ធនឹងដំណើរការ និងការសម្រេចនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភា

- ធ្វើកំណត់ហេតុសង្ខេប និងកំណត់ហេតុពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភា

- ចងក្រងកំណត់ហេតុ លិខិតបទដ្ឋានគតិយុត្ត និងឯកសារផ្សេងៗពាក់ព័ន្ធនឹងការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភា។ល។

អគ្គនាយកដ្ឋានស្រាវជ្រាវ មានតួនាទីផ្តល់សេវាសិក្សាស្រាវជ្រាវ និងព័ត៌មានផ្នែកច្បាប់ កិច្ចការទូទៅតាមវិស័យ ថវិកា និងកិច្ចការសភា ដើម្បីគាំទ្រដល់ការប្រតិបត្តិមុខងារស្នូលទាំង៣ របស់ព្រឹទ្ធសភា។

ដើម្បីបំពេញតួនាទីខាងលើនេះ អគ្គនាយកដ្ឋានមានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- ផ្តល់សេវាសិក្សាស្រាវជ្រាវ វិភាគ ផ្តល់យោបល់ និងរៀបចំជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ និងបញ្ហាទាំងពួង
- ផ្តល់សេវាសិក្សាស្រាវជ្រាវ វិភាគ និងផ្តល់យោបល់ផ្នែកច្បាប់ សេដ្ឋកិច្ច សង្គម កិច្ចការសភា និងថវិកា
- ចងក្រងឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ និង
- ទំនាក់ទំនង និងសហប្រតិបត្តិការទាំងក្នុង និងក្រៅស្ថាប័នដើម្បីបម្រើឱ្យការងារស្រាវជ្រាវ។

ក្នុងនោះមានអង្គភាព ៣ សំខាន់ៗដែលមានភារកិច្ចក្នុងការស្រាវជ្រាវ និងរៀបចំឯកសារជំនួយស្មារតីនៃសេចក្តីព្រាងច្បាប់ជូនសមាជិកព្រឹទ្ធសភា ក៏ដូចជាគណៈកម្មការជំនាញនានា ជាអាទិ៍ នាយកដ្ឋានស្រាវជ្រាវច្បាប់ នាយកដ្ឋានស្រាវជ្រាវទូទៅ និងនាយកដ្ឋានស្រាវជ្រាវថវិកា។

ដូចបានលើកមកបរិយាយនៅក្នុង ចំណុច (IV, ២) ជាក់ស្តែង មន្ត្រីរាជការអង្គភាពមួយចំនួនដែលមានភារកិច្ចពាក់ព័ន្ធចាំបាច់ក្នុងការផ្តល់សេវាផ្សេងៗជូនសមាជិកា សមាជិកព្រឹទ្ធសភាបំពេញមុខងារនីតិកម្ម រួមមាន នីតិវិធី បច្ចេកទេសគតិយុត្ត ឯកសារ និងសេវាស្រាវជ្រាវ គឺបានបង្ហាញចាប់ពីជំហានទី១ ដល់ជំហានទី៤។

## V. ដំណើរការបង្វិលទៅបង្វិលមក

ព្រឹទ្ធសភាពិនិត្យហើយឱ្យយោបល់ ក្នុងរយៈពេលមួយខែយ៉ាងយូរលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមជាលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួង ដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ។ បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ។

បើព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម ឬពុំបានឱ្យយោបល់សោះ ក្នុងរយៈពេលដែលមានកំណត់ទុកហើយនោះ ច្បាប់ដែលរដ្ឋសភាបានអនុម័តហើយនោះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ។

បើព្រឹទ្ធសភា សុំឱ្យកែសម្រួលលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទីពីរ។ រដ្ឋសភាត្រូវពិនិត្យ និងសម្រេចតែត្រង់បទប្បញ្ញត្តិ ឬចំណុចណាដែលព្រឹទ្ធសភាសុំឱ្យកែសម្រួល ដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ។

ការបង្វិលទៅវិញទៅមករវាងព្រឹទ្ធសភា និងរដ្ឋសភា ត្រូវធ្វើតែក្នុងរយៈពេលមួយខែ។ រយៈពេលនេះ ត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសម្រេចពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃ បើជាការប្រញាប់។

បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យាពេល ដែលបានកំណត់ទុកសម្រាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភា និងព្រឹទ្ធសភា ត្រូវបន្ថែមឱ្យស្មើគ្នាដែរ។

បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាចនឹងយកមក ពិចារណាជាលើកទីពីរបានមុនរយៈពេលមួយខែទេ។ រយៈពេលនេះ ត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ បើពិនិត្យពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃ បើជាការប្រញាប់។

ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកទីពីរនេះ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណាដែលបានសម្រេចដូចខាងលើនេះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ។

## VI. **ការចូលជាធរមាននៃច្បាប់**

នៅពេលដែលរដ្ឋសភា ទទួលបានយោបល់យល់ព្រមលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ពីព្រឹទ្ធសភា ត្រូវបញ្ជូនទៅរាជរដ្ឋាភិបាល ដើម្បីបន្តនីតិវិធីបង្គំទូលថ្វាយព្រះមហាក្សត្រ ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់។

មាត្រា២៨ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ ចែងថា «**ព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និងព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខា លើព្រះរាជក្រឹត្យ តាមសេចក្ដីស្នើសុំពីគណៈរដ្ឋមន្ត្រី** » ។

មាត្រា៩៣ថ្មី នៃរដ្ឋធម្មនុញ្ញ ចែងថា «ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញ ក្នុងរយៈពេលដប់ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ ។ ប៉ុន្តែបើច្បាប់នេះបានចែងថា ជាការប្រញាប់ ច្បាប់នេះត្រូវចូលជរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ » ។

ច្បាប់ដែលព្រះមហាក្សត្រ ទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេស ឱ្យទាន់តាមពេលវេលាកំណត់ខាងលើ ។

គំនូសបំព្រួញទី៣ ៖ នីតិវិធីពិនិត្យ និងអនុម័តច្បាប់របស់សភាកម្ពុជា




<u>សំគាល់</u> ៖

(១)ដំណើរការការងារក្នុងរសភា និងព្រឹទ្ធសភា។

(២)ការបង្វិលទៅបង្វិលមករវាងរដ្ឋសភា និងព្រឹទ្ធសភា។

# សេចក្តីសន្និដ្ឋាន

ឧបករណ៍សំខាន់បំផុតរបស់រដ្ឋសភា និងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាក្នុងការអនុវត្តមុខងារនីតិកម្ម គឺរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុង។ ទន្ទឹមនឹងនេះ សភាទាំងពីរក៏មានវិធានផ្ទៃក្នុងដោយឡែករៀងៗខ្លួនដែលអាចធានាបាននូវការរៀបចំនូវរដ្ឋបាលសភានីមួយៗ ទាំងរចនាសម្ព័ន្ធនយោបាយ និងរចនាសម្ព័ន្ធរដ្ឋបាលឱ្យប្រព្រឹត្តទៅដោយរលូន។

សមាជិកសភា ជាអ្នកពិនិត្យមើលជម្រើសនានាលើប្បញ្ញត្តកម្មដែលសមស្រប មុននឹងធ្វើសេចក្តីសម្រេចចិត្តផ្នែកនយោបាយ រីឯមន្ត្រីសភាជាអ្នកផ្តល់សេវាបច្ចេកទេស នីតិវិធី និងការគាំទ្រខាងមធ្យោបាយនានា ដល់ពួកគាត់ក្នុងការបំពេញមុខងារឱ្យសម្រេចបានជោគជ័យ។ ក្រៅពីឧបករណ៍ខាងលើ ស្ថាប័ននីតិប្បញ្ញត្តិទាំងពីរមានគោលការណ៍ក្រមសីលធម៌ដោយឡែករៀងខ្លួន ដែលជានិយាមជួយតម្រង់ទិសសមាជិកព្រឹទ្ធសភា និងអ្នកតំណាងរាស្ត្រឱ្យបំពេញមុខងារប្រកបដោយប្រសិទ្ធភាព។

ដូចគ្នានេះដែរ មន្ត្រីសភាដែលមានតួនាទីផ្តល់សេវាគាំទ្រនានា ទាំងបច្ចេកទេស នីតិវិធី និងរដ្ឋបាល ត្រូវតែប្រព្រឹត្តដោយមិនលំអៀង អព្យាក្រឹត្យភាព និងបំពេញការងារប្រកបដោយវិជ្ជាជីវៈដើម្បីផ្តល់សេវាដល់សមាជិកសភា និងសមាជិកព្រឹទ្ធសភា។ ច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិក៏មានបទប្បញ្ញត្តិចែងអំពីគោលការណ៍ខាងលើ រួមទាំងគោលការណ៍ក្រមសីលធម៌របស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានសភាទាំងពីរ គឺជាបទដ្ឋានយ៉ាងសំខាន់ ដែលជួយឱ្យមន្ត្រីសភាបំពេញការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

ឆ្លងតាមការអនុវត្តជាក់ស្តែង យើងសង្កេតឃើញថា បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាក្តី និងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភាក្តី មានលក្ខណៈគ្រប់គ្រាន់និងទន់ភ្លន់ ដែលអាចសម្រួលដល់ការអនុវត្តនូវវិធាននីតិវិធីស្របតាមស្ថានភាពជាក់ស្តែងនៃកិច្ចការសភា។ បែបបទការងារមួយចំនួន ដូចជា នីតិវិធីកិច្ចការរដ្ឋបាល បច្ចេកទេស និងការទូតសភា ជាដើម ពុំបានសរសេរ ឬពុំបានចងក្រងជាវិធានសម្រាប់

មន្ត្រីសភាអនុវត្តឡើយ ហើយភាពខ្វះចន្លោះនេះ ទុកលទ្ធភាពដល់មន្ត្រីសភាធ្វើការបត់បែនទៅតាមស្ថានភាពការងារជាក់ស្តែង។

ម្យ៉ាងទៀត វិធានផ្ទៃក្នុងនៃការអនុវត្តជំហានទាំងបួនរបស់រដ្ឋសភា និងព្រឹទ្ធសភាក្នុងការបំពេញមុខងារនីតិកម្មគឺមានលក្ខណៈប្រហាក់ប្រហែលគ្នា ប៉ុន្តែ របៀបរបបនៃការផ្តល់សេវាគាំទ្រខាងនីតិវិធី និងការផ្តល់សេវាបច្ចេកទេសស្រាវជ្រាវ គឺមានលក្ខណៈខុសគ្នាតិចតួច។

បន្ទាប់ពីបានបំពេញតួនាទីក្នុងការធ្វើច្បាប់ សមាជិកសភាមិនទាន់បញ្ចប់ភារកិច្ចរបស់ខ្លួនទេ គាត់ត្រូវចូលរួមជួយធ្វើការផ្សព្វផ្សាយច្បាប់ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ ដើម្បីឱ្យប្រជាពលរដ្ឋតាមមណ្ឌលរៀងៗខ្លួនបានយល់ជ្រួតជ្រាប និងចូលរួមអនុវត្តប្រកបដោយប្រសិទ្ធភាព។

បន្ទាប់មក សភាត្រូវធ្វើការពិនិត្យតាមដានរាជរដ្ឋាភិបាលក្នុងការអនុវត្តច្បាប់ លិខិតបង្គាន គតិយុត្ត និងគោលនយោបាយនានា ដែលអំណាចពិនិត្យតាមដាននេះ អាចធ្វើឡើងតាមយន្តការគណៈកម្មការជំនាញ នានារបស់សភា។ ដូច្នេះ សភាមានតួនាទីចាប់ឱ្យរាជរដ្ឋាភិបាលទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួនក្នុងការអនុវត្តច្បាប់ និងគោលនយោបាយនានាដែលបានអនុម័ត ជាពិសេសការសន្យានានារបស់រាជរដ្ឋាភិបាលនៅរៀងរាល់ដើមនីតិកាលនីមួយៗ។

ព្រឹទ្ធសភា និងរដ្ឋសភាមានអំណាចនីតិប្បញ្ញត្តិដូចគ្នា ប៉ុន្តែមានអត្តសញ្ញាណ និងសមត្ថកិច្ចផ្សេងគ្នា អាស្រ័យដោយប្រភព ភាពជាតំណាង និងអំណាច។ រដ្ឋសភាមានអំណាចបោះឆ្នោតជ្រើសតាំងរាជរដ្ឋាភិបាល មានសិទ្ធិធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ មានសិទ្ធិត្រួតពិនិត្យរាជរដ្ឋាភិបាល និងមានអំណាចសម្រេចជាចុងក្រោយ។ រីឯព្រឹទ្ធសភា មិនមានអំណាចដូចរដ្ឋសភាឡើយ ប៉ុន្តែព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល។

លើសពីនេះ អនុលោមតាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា បានផ្តល់ឱ្យសភាទាំងពីរ មានអំណាចស្មើគ្នាក្នុងការសម្រេចលើបញ្ហាសំខាន់ៗ របស់ប្រទេសជាតិ។

ក្នុងទ្រឹស្តីនយោបាយ និងសភានិយម ការអនុវត្តប្រព័ន្ធទ្វិសភារបស់សកម្ពុជាក្នុងសម័យទំនើប ទោះបីជាមានសមត្ថកិច្ចដូចគ្នាខ្លះ និងខុសគ្នាខ្លះក្តី ប៉ុន្តែស្ថាប័នទាំងពីរបានដើរតួនាទីយ៉ាងសំខាន់ និងជាដៃគូមិនអាចខ្វះបានក្នុងការពិនិត្យអនុម័ត និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលជាតម្រូវការរបស់ជាតិ ។

# ឯកសារពិគ្រោះ


## ១.ឯកសារភាសាខ្មែរ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បទបញ្ជាផ្ទៃក្នុងរដ្ឋសភា
- បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ខែសីហា ឆ្នាំ២០២០
- សេចក្តីសម្រេចនានារបស់ព្រឹទ្ធសភា នីតិកាលទី៤ ខែមិថុនា ឆ្នាំ២០១៨
- សារាចរណែនាំស្តីពី នីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ផ្សេងទៀត អនុម័តដោយគណៈរដ្ឋមន្ត្រី ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣

## ២. ឯកសារភាសាបរទេស

- Guide de légistique, 3ème edition mise à jour 2017, Secrétariat general du Gouvernement
- The National Assembly IN THE FRENCH INSTITUTIONS, November 2014, Service des Affaires Internationales et de Défense
- CCLSP-Parliamenetary Centre Compendium: Parliamentary Practices and Legal Documents, March 2010

# សមាសភាពក្រុមការងាររៀបចំចងក្រងសៀវភៅ

| | | |
|---|---|---|
| ១. | លោក **យិន យូរ៉ាន់** | អគ្គនាយករង នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី (អ.ព.ស) |
| ២. | លោក **គុន គន្ធូ** | ប្រធាននាយកដ្ឋានស្រាវជ្រាវច្បាប់ (អ.ព.ស) |
| ៣. | លោក **ស៊ី វីរី** | ប្រធានការិយាល័យស្រាវជ្រាវកិច្ចការអង្គការអន្តរជាតិ (អ.រ.ស) |
| ៤. | លោក **មួ និត្យធារ៉ា** | អតីតប្រធានការិយាល័យស្រាវជ្រាវកិច្ចការទំនាក់ទំនងអន្តរជាតិ (អ.រ.ស) និងបច្ចុប្បន្នជាអគ្គាធិការរងនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ៥. | លោកស្រី **វ៉ាន់ ណារី** | ប្រធានការិយាល័យស្រាវជ្រាវកិច្ចការទំនាក់ទំនងអន្តរជាតិ(អ.រ.ស) |
| ៦. | លោក **សាយ សុក្រារុណា** | អនុប្រធានការិយាល័យជំនួយការគណៈកម្មការ (អ.រ.ស) |
| ៧. | លោក **ប៉ក់ ម៉ិនឆេន** | អនុប្រធានការិយាល័យស្រាវជ្រាវកិច្ចការអង្គការអន្តរជាតិ(អ.រ.ស) |
| ៨. | លោក **សុទ្ធ សាងមុណ្យ** | អតីតអ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាលនៃវិទ្យាស្ថានសភាកម្ពុជា (PIC) និងបច្ចុប្បន្នជាមេធាវី និងជាសាស្ត្រាចារ្យច្បាប់ |

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំជាមន្ត្រីសភាដែលជាសិក្ខាកាមនៃវគ្គបណ្តុះបណ្តាលស្តីពី «**បច្ចេកទេសនៃការតាក់តែងច្បាប់**» ដែលបានប្រព្រឹត្តទៅអស់រយៈពេលពីរឆ្នាំ (២០១៦-២០១៨) ក្រោមការឧបត្ថម្ភ និងគាំទ្រដោយវិទ្យាស្ថានសភាកម្ពុជា (PIC) សហការជាមួយអគ្គលេខាធិការដ្ឋានរដ្ឋសភា និងព្រឹទ្ធសភា សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

- **ឯកឧត្តម អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ឡេង ប៉េងឡុង** អគ្គលេខាធិការរដ្ឋសភា និង**លោក គឹមយាត ដារ៉ារិទ្ធ** នាយកប្រតិបត្តិនៃវិទ្យាស្ថានសភាកម្ពុជា (PIC) ដែលជានិច្ចកាល តែងតែយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីសភាទាំងពីរ លើកិច្ចការស្រាវជ្រាវ មុខវិជ្ជាសំខាន់ៗមួយចំនួនទាក់ទងនឹងច្បាប់ សេដ្ឋកិច្ច និងសង្គម ក៏ដូចជាផ្នែកព័ត៌មានបច្ចេកវិទ្យា និងទំនាក់ទំនង ដើម្បីជាប្រយោជន៍ដល់ការផ្តល់សេវាជូនសមាជិកសភាបំពេញការងារឱ្យមានប្រសិទ្ធភាព។ វគ្គសិក្សានេះ ក៏បានផ្តល់ឱកាសឱ្យយើងខ្ញុំបានរៀនសូត្រក្រេបយកចំណេះដឹងខាងកិច្ចការសភាទាំងទ្រឹស្តីសភាបរទេស និងការដកពិសោធន៍លើកិច្ចការសភាដោយផ្ទាល់នៅរដ្ឋសភា និងព្រឹទ្ធសភាបារាំង កាលពីឆ្នាំ២០១៨ ។

- វាគ្មិនមានរាយនាមដូចខាងក្រោមដែលបានចូលរួមនៅក្នុងសិក្ខាសាលាស្តីពី «**ការប្រមូលយោបល់លើឯកសារស្តីពីការអនុវត្តជាក់ស្តែងនៃដំណើរការពិនិត្យ និងអនុម័តច្បាប់នៅសភាកម្ពុជា**» និងបានធ្វើបទបង្ហាញលើប្រធានបទផ្សេងៗគ្នា ៖

  - **ឯកឧត្តម អ៊ឹម ស៊ីថុល** អគ្គលេខាធិការនៃក្រុមប្រឹក្សាអ្នកច្បាប់អមទីស្តីការគណៈរដ្ឋមន្ត្រី ឧទ្ទេសនាមលើប្រធានបទ «ដំណើរការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាល ៖ ទម្រង់ និងខ្លឹមសារនៃសេចក្តីព្រាងច្បាប់»

- **ឯកឧត្តម ប៊ុន ឌុន្ធា** អគ្គនាយក នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី (អ.ពស) ឧទ្ទេសនាមលើប្រធានបទ «ដំណើរការពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់នៅព្រឹទ្ធសភា»
- **ឯកឧត្តម កែ កេតនិន** អគ្គនាយក នៃអគ្គនាយកដ្ឋាននីតិកម្ម និងស្រាវជ្រាវ (អ.រស) ឧទ្ទេសនាមលើប្រធានបទ «ដំណើរការពិនិត្យ និងអនុម័តច្បាប់នៅរដ្ឋសភា»
- **ឯកឧត្តម ឡាយ ប៊ុនម៉េង** អគ្គនាយករង នៃអគ្គនាយកដ្ឋាននីតិកម្ម និងស្រាវជ្រាវ (អ.រស) ឧទ្ទេសនាមលើប្រធានបទ «ការផ្តួចផ្តើមធ្វើសេចក្តីស្នើច្បាប់ ឬសេចក្តីស្នើវិសោធនកម្មច្បាប់ ៖ បទពិសោធន៍នៅរដ្ឋសភា»

- **លោក សុទ្ធ សាងបុណ្យ** ជាមេធាវី ជាសាស្ត្រាចារ្យច្បាប់ និងជាអ្នកសម្របសម្រួលវគ្គសិក្សា ដែលបានជួយរៀបចំទម្រង់ និងខ្លឹមសារឯកសារនេះ

- ព្រមទាំងឯកឧត្តម លោកជំទាវ លោកសាស្ត្រាចារ្យ អស់លោក លោកស្រី និងអ្នកនាងកញ្ញាដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមសិក្ខាសាលា និងផ្តល់យោបល់លើឯកសារដ៏មានសារៈសំខាន់នេះ។

- **លោក មិុះ ឿន** អនុប្រធាននាយកដ្ឋានស្រាវជ្រាវច្បាប់ និង**លោក ខែម សារៈ** មន្ត្រីស្រាវជ្រាវនៃនាយកដ្ឋានស្រាវជ្រាវច្បាប់ ដែលបានចូលរួមផ្តល់យោបល់កែសម្រួលបញ្ចប់ឯកសារនេះ។

# ឧបសម្ព័ន្ធ១ ៖

# កំណត់បង្ហាញពេលទទួលបានសេចក្តីព្រាងច្បាប់ពីរាជរដ្ឋាភិបាល

| នាយកដ្ឋាន នីតិវិធី | |
|---|---|
| ចូល | លេខៈ ១២៦ |
| | ថ្ងៃទី ២៧/០៨ ម៉ោង ១០:៣០ |
| | បញ្ជូនទៅៈ................ |

# **កំណត់បង្ហាញ**

**នាយកដ្ឋាននីតិវិធីសូមគោរពរាយការណ៍ជូនៈ** ឯកឧត្តមអគ្គលេខាធិការរដ្ឋសភា

**ឯកសារទទួលបានពីៈ** លិខិតរបស់រាជរដ្ឋាភិបាលលេខ ៦០០ លស.កបច ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៧

**សូមគោរពជូនៈ** សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា

**កម្មវត្ថុ ៈ** សំណើសុំពិនិត្យ និងអនុម័តនូវសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ។

✪ឯកសារជូនភ្ជាប់មាន ៈ

-លិខិតរបស់រាជរដ្ឋាភិបាល លេខ ៦០០ លស.កបច ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៧ **ជូនរដ្ឋសភាពិនិត្យ និងអនុម័តជាការប្រញាប់ ដោយក្តីអនុគ្រោះ ។**

-សេចក្តីថ្លែងហេតុលេខ ១៣ សជណ.កបច ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៧

-សេចក្តីព្រាងច្បាប់ដែលមាន ពីរមាត្រា

✪សេចក្តីព្រាងច្បាប់នេះ ត្រឹមត្រូវតាមនីតិវិធី និងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា

**យោបល់នាយកដ្ឋាន ៈ** សូមគោរពជម្រាបជូនសម្តេចអគ្គមហាពញាចក្រីប្រធានរដ្ឋសភា ដើម្បីសុំមតិសម្រេចៈ

**-រៀបចំរបៀបវារៈ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាពិនិត្យ និងសម្រេច**

**-ចែកជូនតំណាងរាស្ត្រទាំងអស់ដើម្បីធ្វើការសិក្សាស្រាវជ្រាវ បន្ទាប់ពីបានការសម្រេចពីគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា**

**-ត្រៀមរៀបចំរបៀបវារៈសម័យប្រជុំរដ្ឋសភានាពេលខាងមុខ**

| **ចំណារសម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា** | **ចំណារឯកឧត្តមអគ្គលេខាធិការរដ្ឋសភា** | **ចំណារឯកឧត្តមអគ្គនាយកនីតិកម្មនិងស្រាវជ្រាវ** |
|---|---|---|
| 31.08.2017 | | |

ភ្នំពេញ,ថ្ងៃ ... ទី៣០ ខែ សីហា ឆ្នាំ២០១៧

**ប្រធាននាយកដ្ឋាន**

**ហួត ពៅ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦០០ សជ.ករ

| **រដ្ឋសភា** | |
|---|---|
| **ចូល** | លេខ ... |
| | ថ្ងៃទី ... ឆ្នាំ ... ម៉ោង ... |
| | បញ្ជូនទៅ ... |

## សូមគោរពជូន

## សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា

**កម្មវត្ថុ:** សំណើសុំពិនិត្យ និងអនុម័តនូវសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមផ្ញើជូន**សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា** នូវសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលទទួលបានការសម្រេចយល់ព្រមពីគណៈរដ្ឋមន្ត្រីរួចហើយ ក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ដើម្បីបំពេញបែបបទ និងនីតិវិធី ដូចមានអត្ថន័យក្នុងសេចក្តីថ្លែងហេតុ ភ្ជាប់មកជាមួយនេះ។

អាស្រ័យហេតុនេះ សូម**សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា** មេត្តាដាក់សេចក្តីព្រាងច្បាប់នេះ ជូនរដ្ឋសភាពិនិត្យ និងអនុម័ត ជាការប្រញាប់ ដោយក្តីអនុគ្រោះ។

សូមសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ១៧ អសណ.កបក

## សេចក្ដីថ្លែងហេតុ
## អំពី
## សេចក្ដីព្រាងច្បាប់
## ស្ដីពីវិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ ស្ដីពីជលផល ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦

ក្រោយឆ្នាំ១៩៧៩ ប្រទេសជាតិត្រូវបានរំដោះចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត វិស័យនេសាទត្រូវបានស្ដារឡើងវិញដោយបង្កើតនាយកដ្ឋានជលផលមួយស្ថិតក្រោមក្រសួងពាណិជ្ជកម្ម រហូតដល់ឆ្នាំ១៩៨០ ទើបផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរហូតមកដល់បច្ចុប្បន្ន។ ជាបន្ទាន់ផងដែរក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តជាបន្តបន្ទាប់សម្រាប់គ្រប់គ្រងវិស័យជលផល រហូតដល់ឆ្នាំ១៩៨១ នាយកដ្ឋានជលផល បានចាប់ផ្ដើមសិក្សាស្រាវជ្រាវរៀបចំកសាងច្បាប់ជលផលជាថ្មីសម្រាប់គ្រប់គ្រងវិស័យជលផលនៅកម្ពុជា ដោយមានការជួយជ្រោមជ្រែងយ៉ាងសស្រាក់សស្រាំពីរៀមច្បងជាច្រើននាក់ ដែលជាមន្ត្រីជំនាញនេសាទពីសង្គមចាស់សល់ពីការកាប់សម្លាប់ក្រោមរបបប្រល័យពូជសាសន៍ ប៉ុល ពត បានចូលរួមរៀបចំប្រកបដោយស្មារតីខិតខំតស៊ូព្យាយាម និងអត់ធ្មត់ខ្ពស់សម្រេចបានក្រឹត្យច្បាប់ស្ដីពីការគ្រប់គ្រងវិស័យជលផល។ ក្រឹត្យច្បាប់នេះត្រូវបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ៣៣ ក្រច ចុះ ថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋ ដែលរួមមាន៦ជំពូក និង៤៨មាត្រា។ ក្រឹត្យច្បាប់នេះត្រូវបានប្រើជាឧបករណ៍គតិយុត្តសម្រាប់គ្រប់គ្រងវិស័យជលផល រហូតដល់ឆ្នាំ២០០៦ទើបរាជរដ្ឋាភិបាលរៀបចំឱ្យមានច្បាប់ស្ដីពីជលផលថ្មីមួយទៀតដើម្បីឱ្យស្របតាមស្ថានភាពរីកចម្រើននៃសង្គម។ ច្បាប់ស្ដីពីជលផលឆ្នាំ២០០៦ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលរួមមាន ១៧ជំពូក និង ១០៩មាត្រា។

រាជរដ្ឋាភិបាលបានរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីវិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្ដីពីជលផល ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ នេះឡើង សំដៅធានាការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព ជាពិសេសដើម្បីឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលលើវិស័យជលផល/.

ក៏ដូចជាយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ នីតិកាលទី៥នៃរដ្ឋសភាផងដែរ និងឆ្លើយតបនឹងសំណូមពររបស់ប្រជាពលរដ្ឋ។ បន្ថែមពីលើនេះទៀត គឺដើម្បីផ្ទេរធនធានធម្មជាតិ និងផ្ទេរអំណាចគ្រប់គ្រងជូនរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរួមចំណែកធានាដល់ការការពារ គ្រប់គ្រង ប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព និងការទប់ស្កាត់បទល្មើសនេសាទប្រកបដោយប្រសិទ្ធភាពខ្ពស់។

សេចក្តីព្រាងច្បាប់នេះ ត្រូវបានប្រជុំពិនិត្យពិភាក្សាយ៉ាងល្អិតល្អន់ជាច្រើនលើកច្រើនសារជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់មុននឹងដាក់ជូនក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ហើយការធ្វើវិសោធនកម្មនេះទៀតសោតគឺមានពាក់ព័ន្ធតែមាត្រានៃច្បាប់ស្តីពីជលផលឆ្នាំ២០០៦ចំនួន៥មាត្រាប៉ុណ្ណោះ គឺមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ ដែលមានខ្លឹមសារសង្ខេបដូចខាងក្រោម៖

- **មាត្រា៦ថ្មី** ចែងអំពីការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលជលផល ដោយបែងចែកជាថ្នាក់ជាតិ និងថ្នាក់រាជធានី/ខេត្ត ស្ថិតនៅចំណុះមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី/ខេត្ត។
- **មាត្រា៤១ថ្មី** ចែងអំពីការហាមឃាត់ធ្វើនេសាទដោយប្រើឧបករណ៍នេសាទគ្រប់ប្រភេទរួមផ្សំរបាំងព្រួល ឬលូសសំណាញ់ នៅរដូវបើកនេសាទ ដែលមានបណ្តោយលើស៥០ម៉ែត្រ ឬលាតសន្ធឹងលើស ២/៣ នៃទទឹងមុខទឹក អូរ ព្រែក ស្ទឹង និងហាមការប្រើសាច់មង អួន ឬលូសសំណាញ់ដែលមានក្រឡាតូចជាង៣សង្ទីម៉ែត្រ ធ្វើជារបាំងព្រួល។
- **មាត្រា៤២ថ្មី** ចែងអំពីការអនុញ្ញាតឱ្យធ្វើនេសាទនៅក្នុងកន្លែងនេសាទបម្រុងនៃបឹងទន្លេសាប ដោយប្រើឧបករណ៍លបណ ឬភ៉ាវ ឬលបឡុក។ ឯប្រវែង ទំហំ ទីតាំង និងពេលវេលាអនុញ្ញាតឱ្យធ្វើនេសាទ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
- **មាត្រា៤៣ថ្មី** ចែងអំពីការផ្តល់សិទ្ធិជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំណត់ប្រវែង និងទីតាំងសម្រាប់ធ្វើនេសាទដោយឧបករណ៍អួន។
- **មាត្រា៩៥ថ្មី** ចែងអំពីការកែសម្រួលទោសប្បញ្ញត្តិនៅចំណុច៧ "ការធ្វើនេសាទដោយឧបករណ៍លបណ ឬភ៉ាវ ឬលបឡុក ហួសសុពលភាពនៃលិខិតអនុញ្ញាត" ចំណុច៨ "នេសាទដោយឧបករណ៍អួនលើសប្រវែង និងខុសទីតាំងដែលបានកំណត់" និងចំណុចទី១១ "ការធ្វើនេសាទដោយលបណ ឬភ៉ាវ ឬលបឡុក ខុសពេលវេលា ទីតាំង ប្រវែង និងទំហំដែលបានកំណត់"។

សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ត្រូវបានគណៈរដ្ឋមន្ត្រីសម្រេចយល់ព្រមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ដើម្បីបញ្ជូនទៅសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិរួមមាន២មាត្រា។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់នេះជាការប្រញាប់ដោយសេចក្តីអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីព្រាង

## ច្បាប់

## ស្តីពី

## វិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧**

## មាត្រាមួយ ._

មាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥នៃច្បាប់ស្ដីពីជលផល ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ៖

## មាត្រា៦ ._ ថ្មី

រដ្ឋបាលជលផលគឺជាអាជ្ញាធររដ្ឋបាលដែលចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចគ្រប់គ្រងជលផលនិងធនធានជលផល ស្របតាមគោលនយោបាយវិស័យជលផលជាតិនិងខ្លឹមសារនៃច្បាប់នេះ។ រដ្ឋបាលជលផលមានរចនាសម្ព័ន្ធគ្រប់គ្រងដែលបែងចែកជាថ្នាក់ជាតិនិងថ្នាក់រាជធានី ខេត្ត ស្ថិតនៅចំណុះមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពរបស់រដ្ឋបាលជលផលត្រូវបានកំណត់ដោយអនុក្រឹត្យ។

## មាត្រា៤១ ._ ថ្មី

ហាមឃាត់ការធ្វើនេសាទ៖

១- ជាលក្ខណៈសិប្បកម្មឬឧស្សាហកម្មនៅរដូវបិទនេសាទ។

២- ជាលក្ខណៈឧស្សាហកម្មនៅក្នុងកន្លែងនេសាទបម្រុង។

៣- នៅរដូវបើកនេសាទ ដោយប្រើឧបករណ៍គ្រប់ប្រភេទ រួមផ្សំដោយរបាំងព្រួលឬលួសសំណាញ់ មានបណ្ដោយលើសពី៥០(ហាសិប)ម៉ែត្រឬលាតសន្ធឹងលើសពី២/៣ (ពីរភាគបី)នៃទទឹងមុខទឹក អូរ ព្រែក ស្ទឹង ឬធ្វើឲ្យរាំងស្ទះផ្លូវជលយានគ្រប់ប្រភេទ។

៤- រាល់ការប្រើសាច់មង អួន ឬលួសសំណាញ់ដែលមានក្រឡាតូចជាង៣(បី)សង់ទីម៉ែត្រ ធ្វើជារបាំងព្រួល។

៥- ការធ្វើនេសាទដោយប្រើឧបករណ៍ជាយចាប់ត្រីឬជាយចាប់បង្គងខុសទីតាំងកំណត់របស់ឡូត៍ជាយចាប់ត្រីឬជាយបង្គង។

## មាត្រា៤២ ._ ថ្មី

ការធ្វើនេសាទនៅក្នុងកន្លែងនេសាទបម្រុងដោយប្រើឧបករណ៍លបណ ឬរ៉ាវ ឬលបឡុក នៅបឹងទន្លេសាបអាចអនុញ្ញាតឲ្យធ្វើបានពីថ្ងៃទី១ ខែកុម្ភៈ ដល់ថ្ងៃទី២០ ខែឧសភា។ ការបោះទីតាំងលបណ ឬរ៉ាវ ឬលបឡុក មិនត្រូវធ្វើឲ្យរាំងស្ទះផ្លូវជលយានគ្រប់ប្រភេទឡើយ។ ទីតាំងលបណ ឬរ៉ាវ ឬលបឡុកទាំងឡាយត្រូវដកចេញឲ្យអស់មុនថ្ងៃទី៣១ ខែឧសភា ជាដាច់ខាត។

ចំពោះប្រវែង ទំហំនៃឧបករណ៍នេសាទនិងទីតាំងដែលត្រូវបានអនុញ្ញាតឲ្យធ្វើនេសាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## មាត្រា៤៣ ._ ថ្មី

ការធ្វើនេសាទជាលក្ខណៈសិប្បកម្មដោយអួន ទោះជាមួយវង់ឬច្រើនវង់តភ្ជាប់គ្នាក៏ដោយអាចប្រព្រឹត្តទៅបានលុះត្រាតែអួននោះមានបណ្ដោយតិចជាង៖

- ៣០០(បីរយ)ម៉ែត្រ ចំពោះកន្លែងនេសាទបម្រុងនៅក្រៅបឹងទន្លេសាប

- ៦០០(ប្រាំមួយរយ)ម៉ែត្រ ចំពោះកន្លែងនេសាទបម្រុងនៅក្នុងបឹងទន្លេសាប។

មិនអនុញ្ញាតឲ្យធ្វើនេសាទជាលក្ខណៈសិប្បកម្មដោយអួននៅក្នុងកន្លែងនេសាទដែលទុកសម្រាប់តែប្រជាពលរដ្ឋ នៅក្នុងកន្លែងនេសាទដែលធ្វើឲ្យរំខានដល់ការធ្វើអាជីវកម្មឡូត៍នេសាទ និងនៅក្នុងកន្លែងនេសាទដែលមានទម្លាប់ធ្វើអាជីវកម្មនេសាទដោយប្រើឧបករណ៍តូចៗ។

ចំពោះប្រវែងជាក់ស្តែងនៃឧបករណ៍អួននិងកន្លែងនេសាទ សម្រាប់ការធ្វើនេសាទជាលក្ខណៈសិប្បកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៩៥ _ ថ្មី**

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលជលផល ជាប្រាក់សមាមាត្រទៅនឹងថ្លៃឈ្នួលនេសាទ ឯវត្ថុតាងទាំងអស់ត្រូវប្រគល់ឲ្យសាមីជនវិញ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម៖

១- ផ្ទេរលិខិតអនុញ្ញាតឲ្យធ្វើអាជីវកម្មនេសាទដោយគ្មានការអនុញ្ញាត។

២- ប្រើប្រាស់នាវានេសាទគ្មានលិខិតអនុញ្ញាត រៀបចំឧបករណ៍នេសាទដែលមានលក្ខណៈត្រៀមធ្វើនេសាទក្នុងដែននេសាទសមុទ្រ។

៣- ប្រើប្រាស់នាវានេសាទធ្វើនេសាទក្នុងដែននេសាទគ្មានលិខិតអនុញ្ញាត ឬគ្មានសៀវភៅនាវា នេសាទ។

៤- ប្រើប្រាស់នាវានេសាទមានឧបករណ៍អួនអូសដោយកម្លាំងម៉ាស៊ីននៅក្នុងកន្លែងនេសាទតាមឆ្នេរដោយរៀបចំមានលក្ខណៈត្រៀមធ្វើនេសាទ។

៥- ប្រើប្រាស់ទូក កាណូត កប៉ាល់នេសាទដោយគ្មានចុះបញ្ជីពីរដ្ឋបាលជលផល។

៦- មិនអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងសៀវភៅនាវានេសាទ។

៧- នេសាទដោយលបលួច ឬរ៉ាវ ឬលបឡុកក្នុងតំបន់កំណត់ហួសសុពលភាពនៃការអនុញ្ញាត។

៨- នេសាទជាលក្ខណៈសិប្បកម្មដោយអួនលើសពី៣០០(បីរយ)ម៉ែត្រនៅក្រៅបឹងទន្លេសាប និងលើសពី៦០០(ប្រាំមួយរយ)ម៉ែត្រនៅក្នុងបឹងទន្លេសាប និងខុសពីប្រវែងជាក់ស្តែងនៃឧបករណ៍អួននិងកន្លែងនេសាទសម្រាប់ការធ្វើនេសាទជាលក្ខណៈសិប្បកម្ម ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៩- នេសាទជាលក្ខណៈសិប្បកម្មដោយអួននៅក្នុងកន្លែងនេសាទដែលទុកសម្រាប់តែប្រជាពលរដ្ឋ នៅក្នុងកន្លែងដែលធ្វើឲ្យរំខានដល់ការធ្វើអាជីវកម្មក្នុងឡូត៍នេសាទ និងក្នុងកន្លែងដែលទម្លាប់ធ្វើអាជីវកម្មនេសាទដោយប្រើឧបករណ៍តូចៗ។

១០- នេសាទជាលក្ខណៈសិប្បកម្មគ្មានលិខិតអនុញ្ញាត ខុសទីតាំងនេសាទ ខុសយថាប្រភេទឧបករណ៍នេសាទ ឬប្រើប្រាស់លិខិតអនុញ្ញាតហួសសុពលភាព។

១១- នេសាទដោយលបលួច ឬរ៉ាវ ឬលបឡុក ខុសពេលកំណត់ ខុសទីតាំងកំណត់ លើសពីប្រវែង និងទំហំដែលកំណត់ រាំងស្ទះដល់ផ្លូវជលយានគ្រប់ប្រភេទ ឬមិនដកចេញតាមពេលកំណត់ក្នុងតំបន់កំណត់។

១២- នេសាទជាលក្ខណៈឧស្សាហកម្មដោយគ្មានលិខិតអនុញ្ញាត ឬហួសសុពលភាពនៃលិខិតអនុញ្ញាត។

១៣- នេសាទប៉ះពាល់ឬខូចខាតដល់ស្មៅសមុទ្រឬផ្កាថ្ម។

១៤- មិនព្រមផ្អាកធ្វើនេសាទតាមការបញ្ឈប់ជាបណ្តោះអាសន្នរបស់រដ្ឋបាលជលផលមានសមត្ថកិច្ច។

១៥- ប្រើសាច់មង អួន ឬលួសសំណាញ់ដែលមានក្រឡាតូចជាង៣(បី)សង់ទីម៉ែត្រ ធ្វើរបាំងរួមផ្សំ ឬជំនួសរបាំងព្រួល។

១៦- ធ្វើអាជីកម្មនេសាទដោយមិនអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងសៀវភៅបន្ទុកឡូត៍នេសាទ ឬលិខិតអនុញ្ញាតឲ្យធ្វើនេសាទ។

១៧- បោះរបាំងក្នុងឡូត៍នេសាទឬផ្លូវទឹកនៃតំបន់ឆ្នេរសមុទ្រដោយមិនបើកមុខទឹកឲ្យជលយានធ្វើចរាចរណ៍បាន។

១៨- ធ្វើឲ្យចាល់ទឹកនៅមុខរបាំង។

១៩- បោះទីតាំងឡូត៍ជាយខុសពីការកំណត់។

២០- ប្រើប្រាស់ឧបករណ៍នេសាទឬពេលវេលានេសាទនៅក្នុងកន្លែងនេសាទសហគមន៍ខុសពីការកំណត់របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ជនណាប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះចាប់ពី២(ពីរ)ដងឡើងទៅ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលទ្វេដងនៃប្រាក់ដែលត្រូវពិន័យអន្តរការណ៍ក្នុងមាត្រានេះ និងវត្ថុតាងពិតប្រាកដទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

**មាត្រាពីរ.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។/.

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ខែ ឆ្នាំ២០១៧
នាសម័យប្រជុំរដ្ឋសភាលើកទី នីតិកាលទី ។
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៧

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

# ឧបសម្ព័ន្ធ២ ៖

# លិខិតអញ្ជើញប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

- ៦៩១. ៣៥៨.នស.

# លិខិតអញ្ជើញ

សូមគោរពអញ្ជើញ..ឯកឧត្តម...ហ៊ុ..ស្រី..............................

..............................................................................

មកចូលរួមប្រជុំការងារគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា នាថ្ងៃ ចន្ទ ទី ១៦ ខែ តុលា ឆ្នាំ ២០១៧ វេលាម៉ោង ៧:៣០ ព្រឹកនៅសាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ។ ក្នុងករណីដែលឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មការអវត្តមាន សូមអញ្ជើញអនុប្រធានគណៈកម្មការចូលរួមប្រជុំជំនួស ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៧

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

**ចម្លងជូន:**

**-អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ**

**-អគ្គនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ពិធីការ និងពត៌មាន**

**-ដើម្បីសហការចាត់ចែង-**

# ឧបសម្ព័ន្ធ៣ ៖

# លិខិតបញ្ជូនច្បាប់ឱ្យគណៈកម្មការសិក្សា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**
-លេខ: ៣៤៣ .រស.

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៧

**ជម្រាបជូន**
**ឯកឧត្តមប្រធានគណៈកម្មការផែនការ វិនិយោគ កសិកម្ម**
**អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក**

សូមជ្រាប ។

**កម្មវត្ថុ** : **ការពិនិត្យលើសេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា ៦ មាត្រា ៤១ មាត្រា ៤២ មាត្រា ៤៣ និងមាត្រា ៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ។**

**យោង** : ការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាប្រជុំថ្ងៃ អង្គារ ទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៧ ។

ខ្ញុំ សូមជម្រាបជូនឯកឧត្តមជ្រាបថា រដ្ឋសភាទើបបានទទួលសេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា ៦ មាត្រា ៤១ មាត្រា ៤២ មាត្រា ៤៣ និងមាត្រា ៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ តាមរយៈលិខិតលេខ ៦០០ លស.កបច ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៧ ។

យោងយោបល់សម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដែលបានឯកភាពប្រគល់ភារកិច្ចជូន **គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក ដោយសហការជាមួយគណៈកម្មការនីតិកម្ម និងយុត្តិធម៌ ដើម្បីធ្វើការពិនិត្យ សិក្សាស្រាវជ្រាវ** ខ្ញុំសូមប្រគល់ឯកសារនេះជូនឯកឧត្តម ដើម្បីចាត់ការ និងធ្វើការរាយការណ៍ជូនអង្គសភានាពេលខាងមុខនេះ។

សូមឯកឧត្តមជ្រាប និងសម្រួលការងារឲ្យមានប្រសិទ្ធិភាព ។

សូមឯកឧត្តម ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

**ចម្លងជូន:**
**-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា**
**-អគ្គលេខាធិការដ្ឋានរដ្ឋសភា**
**"ដើម្បីជ្រាបជាព័ត៌មាន"**

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៩ សារអេឡិចត្រូនិច: sg@national-assembly.org.kh គេហទំព័រ: www.national-assembly.org.kh

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

**គណៈកម្មការ ផែនការ វិនិយោគ កសិកម្ម**

**អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក**

លេខ.....០២២/១៧.............រ.ស.គ៣

# លិខិតអញ្ជើញ

## គណៈកម្មការផែនការ វិនិយោគ

## កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក នៃរដ្ឋសភា

សូមគោរពអញ្ជើញ **ឯកឧត្តម លោកជំទាវ** លេខាធិការ សមាជិក សមាជិកា គណៈកម្មការ ទីប្រឹក្សាច្បាប់អមរដ្ឋសភានិងទីប្រឹក្សាច្បាប់ប្រចាំគណៈកម្មការ ដើម្បីចូលរួមប្រជុំផ្ទៃក្នុងគណៈកម្មការ។

**របៀបវារៈ** : ប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្ម មាត្រា៦ មាត្រា៩១ មាត្រា៩២ មាត្រា៩៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ។

**កាលបរិច្ឆេទ**: ថ្ងៃចន្ទ ទី០២ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង ០៩:០០ នាទីព្រឹក ។

**ទីកន្លែង** : សាលប្រជុំគណៈកម្មការទី៣ នៃវិមានរដ្ឋសភា ។

អាស្រ័យហេតុនេះសូម **ឯកឧត្តម លោកជំទាវ** អញ្ជើញចូលរួមប្រជុំតាមការគួរ ។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅ ពីខ្ញុំ ។

រាជធានីភ្នំពេញ,ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧

**ជ.គណៈកម្មការទី៣**

**អនុប្រធាន**

**ចម្លងជូន**

-គណៈកម្មាធិការអចិន្ត្រៃយ៍

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គនាយកដ្ឋាននីតិកម្ម និងស្រាវជ្រាវ

-នាយកដ្ឋាននីតិវិធី

• ដើម្បីជូនជ្រាប

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

**គណៈកម្មការ ផែនការ វិនិយោគ កសិកម្ម**

**អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក**

លេខ.....០០៣/១៧...........រ.ស.គ៣

# លិខិតអញ្ជើញ

## ប្រធានគណៈកម្មការផែនការ វិនិយោគ

## កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក នៃរដ្ឋសភា

សូមគោរពអញ្ជើញ **ឯកឧត្តម លោកជំទាវ** អនុប្រធាន លេខាធិការ សមាជិក សមាជិកា គណៈកម្មការ ទីប្រឹក្សាច្បាប់អមរដ្ឋសភានិងទីប្រឹក្សាច្បាប់ប្រចាំគណៈកម្មការ ដើម្បីចូលរួមប្រជុំជាមួយគណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ។

**របៀបវារៈ** : ប្រជុំពិនិត្យពិភាក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពីវិសោធនកម្ម មាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្ដីពីជលផល ។

**កាលបរិច្ឆេទ**: ថ្ងៃពុធ ទី០៤ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង ០៨:៣០ នាទីព្រឹក ។

**ទីកន្លែង** : សាលប្រជុំបន្ទាយស្រី(អតីតលេខ២៧) នៃវិមានរដ្ឋសភា ។

អាស្រ័យហេតុនេះសូម **ឯកឧត្តម លោកជំទាវ** អញ្ជើញចូលរួមប្រជុំតាមការគួរ ។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅ ពីខ្ញុំ ។

រាជធានីភ្នំពេញ,ថ្ងៃទី ខែតុលា ឆ្នាំ២០១៧

**ជ.គណៈកម្មការទី៣**

**ប្រធាន**

**ចម្លងជូន**

- -គណៈកម្មាធិការអចិន្ត្រៃយ៍
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គនាយកដ្ឋាននីតិកម្ម និងស្រាវជ្រាវ
- -នាយកដ្ឋាននីតិវិធី
- ដើម្បីជូនជ្រាប

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋសភា**

**គណៈកម្មការ ផែនការ វិនិយោគ កសិកម្ម**
**អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក**

លេខ......០១២/១៧........រ.ស.គ៣

# <u>លិខិតអញ្ជើញ</u>

## ប្រធានគណៈកម្មការផែនការ វិនិយោគ
## កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក នៃរដ្ឋសភា

សូមគោរពអញ្ជើញ **ឯកឧត្តម** ជាប្រធានគណៈកម្មការ និងឯកឧត្តម លោកជំទាវ ជាអនុប្រធាន លេខាធិការ សមាជិក សមាជិក គណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ចូលរួមជាមួយគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក នៃរដ្ឋសភា ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្ម មាត្រា៦ មាត្រា៨១ មាត្រា៨២ មាត្រា៨៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ។

**<u>របៀបវារៈ</u>** : ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ *ស្តីពីវិសោធនកម្ម មាត្រា៦ មាត្រា៨១ មាត្រា៨២ មាត្រា៨៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល។*

**<u>កាលបរិច្ឆេទ</u>** : ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង ០៨:៣០ នាទីព្រឹក

**<u>ទីកន្លែង</u>** : សាលប្រជុំបន្ទាយស្រី ( អតីតលេខ២៧) នៃវិមានរដ្ឋសភា។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ** មេត្តាអញ្ជើញប្រជុំ តាមការគួរ ។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវការអានជំរាបលជ្រៅ អំពីខ្ញុំ ។

រាជធានីភ្នំពេញ.,ថ្ងៃទី ៣ ខែតុលា ឆ្នាំ២០១៧

**ជ.គណៈកម្មការទី៣**

**ប្រធាន**

**<u>ចម្លងជូន</u>**

-គណៈកម្មាធិការអចិន្ត្រៃយ៍
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គនាយកដ្ឋាននីតិកម្ម និងស្រាវជ្រាវ
-នាយកដ្ឋាននីតិវិធី
"ដើម្បីជូនប្រាប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា
គណៈកម្មការ ផែនការ វិនិយោគ កសិកម្ម
អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក
លេខ ១៣៦/១៧ រ.ស.គ៣

# លិខិតអញ្ជើញ

## ប្រធានគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក នៃរដ្ឋសភា

សូមគោរពអញ្ជើញ **ឯកឧត្តម លោកជំទាវ** ជាអនុប្រធាន លេខាធិការ សមាជិក សមាជិកា គណៈកម្មការ ទីប្រឹក្សាច្បាប់អមរដ្ឋសភា ទីប្រឹក្សាច្បាប់ប្រចាំគណៈកម្មការ និងមន្ត្រីជំនួយការ ដើម្បីចូលរួមប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ។

**របៀបវារៈ** : ប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី*វិសោធនកម្ម មាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦* ។

**កាលបរិច្ឆេទ** : ថ្ងៃពុធទី១១ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង ០២:៣០ នាទីរសៀល ។

**ទីកន្លែង** : សាលប្រជុំបន្ទាយស្រី(អតីតលេខ២៧) នៃវិមានរដ្ឋសភា ។

អាស្រ័យហេតុនេះសូម **ឯកឧត្តម លោកជំទាវ** អញ្ជើញចូលរួមប្រជុំតាមការគួរ ។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅ ពីខ្ញុំ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែតុលា ឆ្នាំ២០១៧

**ជ. គណៈកម្មការទី៣**

**ប្រធាន**

**ចម្លងជូន**
-គណៈកម្មាធិការអចិន្ត្រៃយ៍
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គនាយកដ្ឋាននីតិកម្ម និងស្រាវជ្រាវ
-នាយកដ្ឋាននីតិវិធី
  · ដើម្បីជូនជ្រាប

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

**គណៈកម្មការ ផែនការ វិនិយោគ កសិកម្ម**
**អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក**

លេខ ០១៦/១៧ រ.ស.គ₃

# <u>លិខិតអញ្ជើញ</u>

## ប្រធានគណៈកម្មការផែនការ វិនិយោគ
## កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក នៃរដ្ឋសភា

សូមគោរពអញ្ជើញ **ឯកឧត្តម** ជាប្រធានគណៈកម្មការ និងឯកឧត្តម លោកជំទាវ ជាអនុប្រធាន លេខាធិការ សមាជិក សមាជិកា គណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ចូលរួមជាមួយតំណាងរាជរដ្ឋាភិបាល ដែលអញ្ជើញមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**<u>របៀបវារៈ</u>** : ប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី *វិសោធនកម្ម មាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦* ។

**<u>កាលបរិច្ឆេទ</u>** : ថ្ងៃពុធទី១១ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង ០២:៣០ នាទីរសៀល ។

**<u>ទីកន្លែង</u>** : សាលប្រជុំបន្ទាយស្រី(អតីតលេខ២៧) នៃវិមានរដ្ឋសភា ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ** មេត្តាអញ្ជើញប្រជុំ តាមការគួរ ។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវរាប់អានដ៏ជ្រាលជ្រៅ អំពីខ្ញុំ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែតុលា ឆ្នាំ២០១៧

**ជ.គណៈកម្មការទី៣**

**ប្រធាន**

**<u>ចម្លងជូន</u>**

-គណៈកម្មាធិការអចិន្ត្រៃយ៍
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គនាយកដ្ឋាននីតិកម្ម និងស្រាវជ្រាវ
-នាយកដ្ឋាននីតិវិធី
"ដើម្បីជូនព្រាប

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥-២៣) ២១៩ ៩៣១ ទូរសារ : (៨៥៥-២៣) ២១៩ ៩៣១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

**គណៈកម្មការ ផែនការ វិនិយោគ កសិកម្ម**
**អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក**

លេខ.....០៧៥............រ.ស.គ៣ ១៤

## សូមគោរពជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**
**នៃព្រះរាជាណាចក្រកម្ពុជា**

**តាមរយៈ** : ឯកឧត្តមបណ្ឌិត **ឈួន ញឹល** ប្រធានស្តីទី នៃរដ្ឋសភា

**កម្មវត្ថុ** : សំណើសុំចាត់តំណាងរាជរដ្ឋាភិបាល និងសហការីជំនាញ មកចូលរួមប្រជុំជាមួយ គណៈកម្មការទី៣ និងគណៈកម្មការទី៥ នៃរដ្ឋសភា ។

**យោង** : -មាត្រា ៩៧ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-ប្រការ ៣៤ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
-លិខិតលេខ: ១១៦ រ.ស ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៤ របស់រដ្ឋសភា

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពស្នើសុំ **សម្តេចនាយករដ្ឋមន្ត្រី** មេត្តាចាត់តំណាងរាជរដ្ឋាភិបាល និងសហការីជំនាញ អញ្ជើញមកចូលរួមប្រជុំជាមួយគណៈកម្មការទី៣ នៃរដ្ឋសភា **នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ វេលាម៉ោង ១៤ : ៣០ នាទីរសៀល** នៅសាលប្រជុំលេខ ២៧ អ.រ.ស នៃវិមានរដ្ឋសភា ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារ ស្តីពីវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការជំរុញ និងការការពារវិនិយោគ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **សម្តេចនាយករដ្ឋមន្ត្រី** មេត្តាចាត់តំណាងរាជរដ្ឋាភិបាល និងសហការីជំនាញមកចូលរួមប្រជុំតាមការគួរ ។

សូម សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ។

រាជធានីភ្នំពេញ,ថ្ងៃទី២៦ខែមីនា ឆ្នាំ២០១៤
**ប្រធានគណៈកម្មការទី៣**

[illegible]

លេខ : ១២៤ រ.ស
បានឃើញនិងបញ្ជូនមក
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**
**នៃព្រះរាជាណាចក្រកម្ពុជា**
"សូមចាត់តំណាងរាជរដ្ឋាភិបាល ចូលរួមប្រជុំតាមការគួរ"
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤
**ប្រធានរដ្ឋសភាស្តីទី**

**បណ្ឌិត. ឈួន ញឹល**

**ចម្លងជូន**
- គណៈកម្មការអចិន្ត្រៃយ៍នៃរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការក្រុមប្រឹក្សាស្តីនៃកម្ពុជា
- អគ្គនាយកដ្ឋានសេវានិងបច្ចេកទេស
- នាយកដ្ឋាននីតិវិធី
"ដើម្បីជូនជ្រាប"
- ឯកសារកាលប្បវត្តិ

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥-២៣) ២១៥ ៩៣១ ទូរសារ : (៨៥៥-២៣) ២១៥ ៩៣១

# ឧបសម្ព័ន្ធ៤ ៖

# លិខិតស្នើសុំដាក់បញ្ចូលក្នុងរបៀបវារៈប្រជុំ
# គណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គរដ្ឋសភា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

**គណៈកម្មការ ផែនការ វិនិយោគ កសិកម្ម**
**អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក**

លេខ ០១៧/១៧ រ.ស.គ៣

**<u>សូមគោរពជូន</u>**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា**

**កម្មវត្ថុ** : សំណើសុំបញ្ចូលសេចក្តីព្រាងច្បាប់ស្តីពី *វិសោធនកម្ម មាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦* ទៅក្នុងរបៀបវារៈសម័យប្រជុំរដ្ឋសភា ។

**<u>យោង</u>** : -ការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ប្រជុំថ្ងៃអង្គារ ទី២៦ ខែកញ្ញា ឆ្នាំ២០១៧
-លិខិតលេខ: ៣៤៣ រ.ស ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧របស់រដ្ឋសភា

គណៈកម្មការមានកិត្តិយសសូមគោរពជម្រាបជូន **សម្តេចប្រធានរដ្ឋសភា** ជ្រាបថា: គណៈកម្មការបានទទួល នូវសេចក្តីព្រាងច្បាប់ដូចបានជម្រាបជូនខាងលើនេះ ហើយបានដំណើរការប្រជុំពិនិត្យ សិក្សាស្រាវជ្រាវក្នុងគណៈកម្មការ ប្រជុំសហការជាមួយគណៈកម្មការទី៦ ដែលមានការចូលរួមពីទីប្រឹក្សាច្បាប់ប្រចាំគណៈកម្មការ និងទីប្រឹក្សាច្បាប់អមរដ្ឋសភា ព្រមទាំង បានប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ដែលមាន ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហការីជំនាញ ដោយមានការចូលរួមពីតំណាងគណៈកម្មការនានា នៃរដ្ឋសភា ចប់ជាស្ថាពរ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **សម្តេចប្រធានរដ្ឋសភា** មេត្តាពិនិត្យ និងអនុញ្ញាតបញ្ចូលសេចក្តីព្រាងច្បាប់នេះ ចូលក្នុងរបៀបវារៈសម័យប្រជុំរដ្ឋសភា ដោយសេចក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់ ។

សូម **សម្តេចប្រធានរដ្ឋសភា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ ពីខ្ញុំ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែតុលា ឆ្នាំ២០១៧

**ឋ.គណៈកម្មការទី៣ នៃរដ្ឋសភា**

**ប្រធាន**

**ប៉ុល ហំម**

**<u>ចម្លងជូន</u>**

-គណៈកម្មាធិការអចិន្ត្រៃយ៍
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គនាយកដ្ឋាននីតិកម្ម និងស្រាវជ្រាវ
-នាយកដ្ឋាននីតិវិធី
"ដើម្បីជូនជ្រាប"
-ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

គណៈកម្មការ ផែនការ វិនិយោគ កសិកម្ម
អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក

លេខ................................រ.ស.គ៣

# របាយការណ៍
# ស្តីពី
# ការពិនិត្យ សិក្សា លើសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្ម មាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឲ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦

- សូមគោរពសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់
- សូមគោរពឯកឧត្តមបណ្ឌិត **ខួន ញ៉ិល** អនុប្រធានទី២ រដ្ឋសភា
- សូមគោរពអង្គប្រជុំ នៃរដ្ឋសភា
- សូមគោរព ឯកឧត្តម លោកជំទាវ តំណាងរាជរដ្ឋាភិបាល

ក្នុងនាមគណៈកម្មការ ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និង ធនធានទឹក និងគណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ខ្ញុំបាទសូមនាំមកនូវយោបល់របស់គណៈកម្មការទាំងពីរ មកជម្រាបជូនអង្គប្រជុំ នៃរដ្ឋសភា អំពីការពិនិត្យ អត្ថបទសេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្ម មាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឲ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ជូនអង្គប្រជុំ នៃរដ្ឋសភា ដើម្បីពិភាក្សានិងអនុម័ត ។

**១- អំពីនីតិវិធីនៃការពិនិត្យ:**

សេចក្តីព្រាងច្បាប់នេះត្រូវបានរាជរដ្ឋាភិបាលបញ្ជូនមករដ្ឋសភា កាលពីថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០១៧ តាមលិខិតលេខ:៦០០ លស.កបចចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ដោយភ្ជាប់មកជាមួយនូវសេចក្តីថ្លែងហេតុលេខ:១៣ សជណ.កបច ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ជូនរដ្ឋសភាពិនិត្យ និងអនុម័ត ស្របតាមមាត្រា៩១ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមានសេចក្តីព្រាងច្បាប់ថតចម្លងចែកជូនតំណាងរាស្ត្ររួចហើយ ។

បន្ទាប់ពីគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបានទទួលពិនិត្យ ហើយបានសម្រេចបញ្ជូនសេចក្តីព្រាងច្បាប់នេះមកគណៈកម្មការ ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និង ធនធានទឹក ដោយសហការជាមួយគណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា តាមរយៈលិខិត



វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥-២៣) ២១៥ ៩៣១ ទូរសារ : (៨៥៥-២៣) ២១៥ ៩៣១

លេខៈ៣៨៣ រ.ស ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ ដើម្បីពិនិត្យ សិក្សាស្រាវជ្រាវ និងធ្វើសេចក្តីរាយការណ៍ជូនអង្គប្រជុំ នៃរដ្ឋសភា ទៅតាមនីតិវិធី ដែលបានកំណត់ក្នុងប្រការ២១ និង ប្រការ២៤ នៃបទបញ្ជាផ្ទៃក្នុង នៃរដ្ឋសភា ។

ឆ្លើយតបចំពោះភារកិច្ចនេះ គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក និងគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា បានបើកកិច្ចប្រជុំផ្ទៃក្នុងរៀងៗខ្លួន ដោយមានកូរ៉ុមគ្រប់គ្រាន់ស្របតាមប្រការ ១០ថ្មី(ពីរ) បទបញ្ជាផ្ទៃក្នុង នៃរដ្ឋសភា ។

ក្រោយមកគណៈកម្មការទាំងពីរបានប្រជុំរួមគ្នានៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧ ដើម្បីពិនិត្យលើសេចក្តីព្រាងច្បាប់ ហើយបានអនុម័តលើខ្លឹមសារ និងកែសម្រួលពាក្យពេចន៍ និងឃ្លា ឃ្លោងមួយចំនួន ដើម្បីឲ្យងាយស្តាប់ និងស្របតាមច្បាប់ចាស់ ។ គណៈកម្មការទាំងពីរ ក៏បានលើកជាសំណួរមួយចំនួន ដើម្បីទទួលបានការបំភ្លឺពីតំណាងរាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់នេះផងដែរ ។

នៅថ្ងៃទី១១ ខែតុលា ឆ្នាំ ២០១៧ គណៈកម្មការទី៣ និងគណៈកម្មការទី៦ នៃរដ្ឋសភា បានជួបប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ដែល ជាម្ចាស់សេចក្តីព្រាងច្បាប់នេះ ដែលមានឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហការី ហើយបានឯកភាពគ្នារក្សាខ្លឹមសារដើម និងទម្រង់នៅដដែល ប៉ុន្តែកែសម្រួលកំហុសបច្ចេកទេសមួយចំនួន។

**២- គោលបំណង និងខ្លឹមសារ នៃសេចក្តីព្រាងច្បាប់:**

តាមរយៈការពិនិត្យ សិក្សាស្រាវជ្រាវលើសេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្ម មាត្រា៦ មាត្រា៩១ មាត្រា៩២ មាត្រា៩៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ រួចមក គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក និងគណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា យល់ឃើញថា ៖

ក-សេចក្តីព្រាងច្បាប់នេះធ្វើឡើងដោយអនុលោមតាមបទប្បញ្ញត្តិ មាត្រា៩១ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថា សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រីមាន សិទ្ធិផ្តើមគំនិតធ្វើច្បាប់ ។

ខ-សេចក្តីព្រាងច្បាប់នេះ មានគោលបំណង៖

- ធានាការគ្រប់គ្រងធនធានជលផលប្រកដោយនិរន្តរភាព
- ឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលលើវិស័យជលផល ក៏ដូចជាយុទ្ធសាស្រ្តចតុកោណជំណាក់កាលទី៣ នីតិកាលទី៥ នៃរដ្ឋសភា
- ឆ្លើយតបនឹងសំណូមពរជាក់ស្តែងរបស់ប្រជាពលរដ្ឋ

➤ ផ្ទេរធានធានធម្មជាតិ និងផ្ទេរអំណាចគ្រប់គ្រងជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកធានាដល់ការការពារ គ្រប់គ្រង ប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព និងការទប់ស្កាត់បទល្មើសនេសាទប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

គ- សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្ម មាត្រា៦ មាត្រា៨១ មាត្រា៨២ មាត្រា៨៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឲ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ នេះមាន ០២មាត្រា គឺ

**មាត្រាមួយ**.-

មាត្រា៦ មាត្រា៨១ មាត្រា៨២ មាត្រា៨៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ត្រូវធ្វើវិសោធនកម្ម ។

**មាត្រាពីរ**.-

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

**៣- សេចក្តីសន្និដ្ឋាន:**

គណៈកម្មការទាំងពីរយល់ឃើញថា សេចក្តីព្រាងច្បាប់នេះមានលក្ខណៈសមស្របទាំងទម្រង់ និងគតិច្បាប់ ហើយសេចក្តីព្រាងច្បាប់នេះនឹងក្លាយទៅជាឧបករណ៍គតិយុត្តិថ្មីមួយទៀត ដើម្បីជំរុញការងារគ្រប់គ្រងលើវិស័យជលផលឲ្យកាន់តែមានលទ្ធភាពខ្ពស់ បន្ថែមលើច្បាប់ជលផលចាស់ដែលត្រូវប្រកាសឲ្យប្រើកាលពីឆ្នាំ២០០៦ ។

អាស្រ័យហេតុនេះ តាងនាមគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក និងគណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ខ្ញុំសូមដាក់ជូនអង្គរដ្ឋសភាពិភាក្សា និងអនុម័ត លើសេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្ម មាត្រា៦ មាត្រា៨១ មាត្រា៨២ មាត្រា៨៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឲ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ តាមនីតិវិធី មួយមាត្រាម្តងៗ ស្របតាមប្រការ២៩ (ថ្មី) នៃបទបញ្ជាផ្ទៃក្នុង នៃរដ្ឋសភា ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម សម្តេចប្រធានរដ្ឋសភា និងរដ្ឋសភាទាំងមូល មេត្តាពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់នេះមួយមាត្រាម្តងៗ ជាការប្រញាប់ តាមការគួរ ។

**សូមអរគុណ !**

រាជធានីភ្នំពេញ.ថ្ងៃទី ខែតុលា ឆ្នាំ២០១៧

**ជ.គណៈកម្មការទី៣ និងទី៦ នៃរដ្ឋសភា**

**ប្រធានគ៣**

# ឧបសម្ព័ន្ធ៥ ៖

# លិខិតកោះប្រជុំពេញអង្គរដ្ឋសភា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**
-០៦៦១.៤៧៥.រស.

# លិខិតយាង និងអញ្ជើញ

## សូមទូលថ្វាយ និងជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ តំណាងរាស្ត្រ

សូមជ្រាប ។

ទូលបង្គំ ខ្ញុំ មានកិត្តិយសសូមយាង និងអញ្ជើញ សម្តេច ឯកឧត្តម លោកជំទាវ តំណាងរាស្ត្រ ចូលរួមបន្តសម័យប្រជុំរដ្ឋសភាលើកទី ៩ នីតិកាលទី ៥ ដែលនឹងប្រព្រឹត្តទៅ **នៅថ្ងៃ អង្គារ ទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៧ វេលាម៉ោង ៨:០០ ព្រឹក** នៅសាលប្រជុំរដ្ឋសភាតាមរបៀបវារៈដូចមានជូនភ្ជាប់មកជាមួយ ។

ថ្ងៃពុធ ៣ កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ២០១៧

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

**សំលៀកបំពាក់:ធំ**

របៀបវារៈ

សម័យប្រជុំរដ្ឋសភាលើកទី ៩ នីតិកាលទី ៥

ថ្ងៃ អង្គារ ទី ២៦ ខែ ធ្នូ ឆ្នាំ២០១៧

២២-ការប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកថ្មី នៃរដ្ឋសភា នីតិកាលទី ៥ ចំនួន ១ រូប ។

២៣-ការបោះឆ្នោតជ្រើសតាំងឯកឧត្តម លី ឆេង ជាសមាជិកគណៈកម្មការ នីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

**អគ្គលេខាធិការដ្ឋាន**

លេខ ១៤៤០/១៧ អ.រ.ស.សចណ

# សេចក្ដីជូនដំណឹង

អគ្គលេខាធិការដ្ឋានរដ្ឋសភាមានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នៅថ្ងៃ អង្គារ ទី ២៦ ខែ ធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ៨: ០០ ព្រឹក រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នឹងបន្តសម័យប្រជុំលើកទី ៩ នីតិកាលទី ៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** តាមរបៀបវារៈដូចតទៅ :

**១-ការប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកថ្មី នៃរដ្ឋសភា នីតិកាលទី ៥ ចំនួន ១ រូប ។**

**២-ការបោះឆ្នោតជ្រើសតាំងឯកឧត្តម លី ឆេង ជាសមាជិកគណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ។**

អាស្រ័យហេតុនេះ សូមសាធារណជនជ្រាប ។

ថ្ងៃ ពុធ ៣ កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៧

**អគ្គលេខាធិការ**

**ឡេង ប៉េងឡុង**

# ឧបសម្ព័ន្ធ៦ ៖

# លិខិតអញ្ជើញតំណាងរាជរដ្ឋាភិបាលការពារច្បាប់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

**អគ្គលេខាធិការដ្ឋាន**

លេខ ១៤៦......... អ.រ.ស.[illegible]

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកប្រចាំការ**

**រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

សូមជ្រាប ។

**កម្មវត្ថុ** : **សេចក្តីស្នើសុំអញ្ជើញតំណាងរាជរដ្ឋាភិបាលមកការពារសេចក្តីព្រាងច្បាប់នៅសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី ៥ ។**

**យោង** : -លិខិតលេខ ១៣០ លស.កបច ចុះថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជា

-លិខិតលេខ ៨៤ លស.កបច ចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជា

-លិខិតលេខ ៨៦ លស.កបច ចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជា

-លិខិតលេខ ៣៤ លស.កបច ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជា

-លិខិតស្នើសុំកោះប្រជុំរដ្ឋសភាជាវិសាមញ្ញលេខ ១៣១ លស.កបច ចុះថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជា

ខ្ញុំ បាទមានកិត្តិយសសូមជម្រាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកប្រចាំការ មេត្តាជ្រាបថា នៅថ្ងៃ ពុធ ១៤ រោច ខែ មាឃ ឆ្នាំ រកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹង ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៨ វេលាម៉ោង ៨:០០ ព្រឹក រដ្ឋសភាបើកសម័យប្រជុំវិសាមញ្ញ នីតិកាលទី ៥ នឹងធ្វើ **ការពិភាក្សា និង អនុម័តសេចក្តីព្រាងច្បាប់តាមរបៀបវារៈដូចមានភ្ជាប់មកជាមួយ** ។

អាស្រ័យហេតុនេះ ខ្ញុំបាទសូមឯកឧត្តមឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកប្រចាំការ មេត្តាចាត់អញ្ជើញតំណាងរាជរដ្ឋាភិបាលមកការពារសេចក្តីព្រាងច្បាប់តាមកាលបរិច្ឆេទដូចមានជម្រាបជូនខាងលើនេះ តាមការគួរ ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកប្រចាំការ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ថ្ងៃពុធ ១៤ រោច ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៨

**អគ្គលេខាធិការ**

**ឡេង ប៉េងឡុង**

ចម្លងជូន:

-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា

"ដើម្បីជ្រាបជាព័ត៌មាន"

# ឧបសម្ព័ន្ធ៧ ៖

# លិខិតសុំបញ្ចេញយោបល់ក្នុងសម័យប្រជុំពេញអង្គរដ្ឋសភា

**សម័យប្រជុំរដ្ឋសភាជាតិសាមញ្ញ នីតិកាលទី ៥**

**រដ្ឋសភា**

# ពាក្យស្នើសុំមានមតិពិភាក្សា

**ខ្ញុំបាទ-នាងខ្ញុំ** :............................**តំណាងរាស្ត្រក្រុមទី**..................
**តាមរយៈ** :............................**ប្រធានក្រុមទី**...........................

**សូមគោរពជូន**
**សម្តេចអគ្គមហាពញាចក្រីប្រធានរដ្ឋសភា**

**ខ្ញុំបាទ-នាងខ្ញុំ សូមអនុញ្ញាតមានមតិលើ** :

១-.......................................................................................

២-.......................................................................................

**សូមសម្តេចអគ្គមហាពញាចក្រីប្រធានរដ្ឋសភា មេត្តាអនុញ្ញាតតាមការគួរ ។**

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨
ហត្ថលេខាតំណាងរាស្ត្រស្នើសុំ

**បានឯកភាព**
**ប្រធានក្រុមទី.....**

# ឧបសម្ព័ន្ធ៨ ៖

# លិខិតស្នើសុំយោបល់ពីថ្នាក់ដឹកនាំព្រឹទ្ធសភា
# លើការកំណត់កាលបរិច្ឆេទប្រជុំនានារបស់ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# សូមគោរពជម្រាបជូន
# សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា

**កម្មវត្ថុ :** អំពីការគ្រោងកម្មវិធីប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងបន្តសម័យប្រជុំលើកទី១១ ព្រឹទ្ធសភានីតិកាលទី៣

**យោង :** មាត្រា១០៧ ថ្មី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

ដូចកម្មវត្ថុ និងយោងខាងលើ អគ្គលេខាធិការដ្ឋាន សូមគោរពរាយការណ៍ជូន **សម្តេចប្រធានព្រឹទ្ធសភា** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ខាងមុខនេះ រដ្ឋសភានឹងបន្តសម័យប្រជុំលើកទី៩ នីតិកាលទី៥ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងច្បាប់មួយចំនួនទៀតតាមរបៀបវារៈដែលបានកំណត់ជាអាទិ៍ ដូចខាងក្រោម៖

១- សេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ។

២- សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើ ៖

១- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

២- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

៣- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះចៅស៊ុលតង់ និងយ៉ាងឌីពើរតួននៃប្រទេសព្រុយណេដារូសាឡឹម ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

៤- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

៣- សេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦។
៤- សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើធម្មនុញ្ញនៃមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី។

សេចក្តីព្រាងច្បាប់ទាំងនេះ រដ្ឋសភានឹងបញ្ជូនមកព្រឹទ្ធសភា ដើម្បីពិនិត្យ និងឲ្យយោបល់ដោយចាត់ទុកជាការប្រញាប់ ។

ហេតុនេះ ដើម្បីត្រៀមលក្ខណៈសម្បត្តិ និងចាត់ចែងនីតិវិធីបានទាន់ពេលវេលាស្របតាមការកំណត់ក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ អគ្គលេខាធិការដ្ឋានយល់ថាព្រឹទ្ធសភាគួរដំណើរការតាមកម្មវិធី ដូចខាងក្រោម ៖

- ថ្ងៃចន្ទ ទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង ១៥:០០ នាទីរសៀល ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យ និងសម្រេចបញ្ជូនសេចក្តីព្រាងច្បាប់ដែលរដ្ឋសភាបញ្ជូនមក ទៅគណៈកម្មការពិនិត្យសិក្សាតាមវិស័យជាសមត្ថកិច្ច ។

- ថ្ងៃសុក្រ ទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង ០៨:០០ នាទីព្រឹក ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីស្តាប់របាយការណ៍របស់គណៈកម្មការ អំពីលទ្ធផលនៃការពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ព្រមទាំងពិនិត្យ និងសម្រេចអំពីរបៀបវារៈ និងកាលបរិច្ឆេទបន្តសម័យប្រជុំលើកទី១១ ព្រឹទ្ធសភានីតិកាលទី៣ ។

- ថ្ងៃចន្ទ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង០៨:០០ នាទីព្រឹក បន្តប្រជុំសម័យលើកទី១១ ព្រឹទ្ធសភានីតិកាលទី៣ ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ដែលរដ្ឋសភានឹងបញ្ជូនមក។

សេចក្តីដូចបានគោរពរាយការណ៍ជូនខាងលើ សូម **សម្តេចប្រធានព្រឹទ្ធសភា** មេត្តាជ្រាប និងពិនិត្យសម្រេចដ៏ខ្ពង់ខ្ពស់ ។

សូម **សម្តេចប្រធានព្រឹទ្ធសភា** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧

**អគ្គលេខាធិការ**

**អ៊ុំ សារិទ្ធ**

វ៤៩៣
15.11.2017
ស.វ.

# ឧបសម្ព័ន្ធ៩ ៖

# កំណត់បង្ហាញលើលិខិតផ្លូវការរបស់រដ្ឋសភា បញ្ជូនមកព្រឹទ្ធសភា

នាយកដ្ឋាន[illegible]
ចូល
លេខ: ១៧
ថ្ងៃទី ១៧/២១ ១៧ ម៉ោង [illegible]
ហត្ថលេខា..........

# កំណត់បង្ហាញ

## សូមគោរពជម្រាបជូន

## សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា

**អគ្គនាយកដ្ឋានសេវាច្បាប់ និងសមាហរណកម្មភាពដែនដី** : សូមគោរពរាយការណ៍ជូនឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា

**ឯកសារទទួលបានពី** : រដ្ឋសភា

**គោរពផ្ញើជូន** : **សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា**

**កម្មវត្ថុ** : *ការអនុម័តសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨*

ឯកសារជូនភ្ជាប់មាន :

- *លិខិតរបស់រដ្ឋសភាលេខ: ៤១៩ រស ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ជូនព្រឹទ្ធសភាពិនិត្យ និងឲ្យយោបល់ ដោយចាត់ទុកជាការប្រញាប់*
- *សេចក្តីថ្លែងហេតុលេខ: ១៧ សជណ.កបច ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧*
- *សេចក្តីព្រាងច្បាប់នេះមាន: ០៦ជំពូក និង ១៥មាត្រា*
- *របាយការណ៍របស់គណៈកម្មការទី២ រដ្ឋសភា*

ស្របតាមនីតិវិធីកំណត់នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។

**យោបល់អគ្គនាយកដ្ឋាន** : សូមគោរពស្នើសុំយោបល់ដ៏ខ្ពង់ខ្ពស់ពី សម្តេចប្រធានព្រឹទ្ធសភា ដើម្បី :

- *រៀបចំរបៀបវារៈដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យ និងសម្រេចបញ្ជូនទៅគណៈកម្មការពិនិត្យសិក្សាទៅតាមវិស័យជាសមត្ថកិច្ច*
- *ចែកជូនគ្រប់សមាជិក សមាជិកាព្រឹទ្ធសភាពិនិត្យសិក្សា បន្ទាប់ពីបានការសម្រេចពីគណៈកម្មាធិការអចិន្ត្រៃយ៍*
- *ត្រៀមរៀបចំរបៀបវារៈប្រជុំព្រឹទ្ធសភានាពេលខាងមុខ ។*

*រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧*

**អគ្គនាយក**

(ហត្ថលេខា)

**ម៉ុន ឧត្តរា**

| **យោបល់សម្តេចប្រធានព្រឹទ្ធសភា** | **យោបល់អគ្គលេខាធិការព្រឹទ្ធសភា** |
|---|---|
| [illegible]<br>1[illegible].11.2017<br>[illegible] | ឯកភាពយោបល់អគ្គនាយកដ្ឋាន<br>គោរពសុំយោបល់សម្តេចប្រធានព្រឹទ្ធសភា<br>ដើម្បីបញ្ចូលក្នុងរបៀបវារៈប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា<br>នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧<br>វេលាម៉ោង ១៥: ០០ នាទីរសៀល ។<br>(ហត្ថលេខា)<br>**អ៊ុំ សារឹទ្ធ** |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**
លេខ: ៦៣៧៥ រ.ស.

**សូមជម្រាបជូន**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា**

សូមជ្រាប ។

**កម្មវត្ថុ** : **ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា ៦ មាត្រា ៤១ មាត្រា ៤២ មាត្រា ៤៣ និងមាត្រា ៩៥ នៃច្បាប់ស្តីពីវិលវល ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ។**

**យោង** : -មាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-លិខិតលេខ ៦០០ លស.កបច ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៧ របស់រាជរដ្ឋាភិបាលកម្ពុជា

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន **សម្តេចប្រធានព្រឹទ្ធសភា** ជ្រាបថា រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានទទួលសេចក្តីស្នើរបស់រាជរដ្ឋាភិបាល សុំឱ្យរដ្ឋសភាពិនិត្យ និងអនុម័ត **សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា ៦ មាត្រា ៤១ មាត្រា ៤២ មាត្រា ៤៣ និងមាត្រា ៩៥ នៃច្បាប់ស្តីពីវិលវល ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ។**

រដ្ឋសភាបានអនុម័តយល់ព្រមលើសេចក្តីព្រាងច្បាប់ខាងលើដោយទទួលបានចំនួន ៦៦ សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល នៅថ្ងៃ ចន្ទ ទី ១៦ ខែ តុលា ឆ្នាំ ២០១៧ នាសម័យប្រជុំរដ្ឋសភា លើកទី ៩ នីតិកាលទី ៥។

អាស្រ័យហេតុនេះ ខ្ញុំសូមជូនភ្ជាប់មកជាមួយនូវសេចក្តីព្រាងច្បាប់ខាងលើ ដើម្បីជូនព្រឹទ្ធសភាពិនិត្យ ហើយឲ្យយោបល់ ដោយចាត់ទុកជាការប្រញាប់ តាមការគួរ ។

សូម **សម្តេចវិបុលសេនាភក្តីប្រធានព្រឹទ្ធសភា** ទទួលនូវការរាប់អានដ៏ស្មោះស្មគ្រ័អំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៧
**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

**ចម្លងជូន:**
**-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា**
**-អគ្គលេខាធិការដ្ឋានរដ្ឋសភា**
**"ដើម្បីជ្រាបជាព័ត៌មាន"**

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៩ សារអេឡិចត្រូនិច:sg@nac.org.kh គេហទំព័រ: www.nac.org.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧ សជណ.កបក

ទទួល
លេខ ៤៥៨១
ថ្ងៃទី៣១/១០ឆ្នាំ ២០១៧ម៉ោង ៣
បញ្ជូនទៅ..................

# សេចក្តីថ្លែងហេតុ
# អំពី
# សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

១- ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ និងស្ថិរភាពនយោបាយ ដែលកើតចេញពីនយោបាយ **ឈ្នះ-ឈ្នះ** និងការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់ ព្រះរាជាណាចក្រកម្ពុជា សម្រេចបាននូវការអភិវឌ្ឍរីកចម្រើនលូតលាស់លើគ្រប់វិស័យ គួរឱ្យកត់សម្គាល់ នៅក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនេះ ជាពិសេសការសម្រេចបាននូវបង្គោលចរមួយដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន គឺការក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតទាបនៅក្នុងឆ្នាំ២០១៥កន្លងទៅ ក៏ដូចជាការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗផ្សេងទៀត។ សមិទ្ធផលខាងលើនេះ គឺជាសក្ខីភាពនៃការឈានឡើងរបស់កម្ពុជា ដោយចាប់ផ្តើមពីបាតដៃទទេ និងក្នុងដំណើរឆ្លងកាត់ដ៏វែងឆ្ងាយ បត់បែន និងលំបាកជាច្រើនរាប់មិនអស់ ហើយទទួលបាននូវការសាទរ និងការទទួលស្គាល់ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ដោយស្មើមុខ និងស្មើសិទ្ធិ ជាពិសេសបានផ្តល់នូវក្តីសង្ឃឹម និងភាពជឿជាក់ ចំពោះជោគវាសនាអនាគតរបស់ប្រជាជនគ្រប់រូប និងប្រទេសជាតិទាំងមូល នៅក្នុងដំណើរឆ្ពោះទៅសម្រេចបាននូវបង្គោលចរថ្មីទៀត គឺប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានសមធម៌សង្គម និងការថែរក្សាបរិស្ថានកាន់តែល្អប្រសើរ។ ឈរលើមូលដ្ឋាននេះ សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ត្រូវបានរៀបចំឡើង ក្នុងគោលដៅដើម្បីបង្ហាញអំពីលទ្ធផលការងារដែលរាជរដ្ឋាភិបាលសម្រេចបាន ព្រមទាំងវិធានការគោលនយោបាយសំខាន់ៗ នៅក្នុងឆ្នាំចុងក្រោយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ឆ្ពោះទៅរកការសម្រេចឱ្យបានជាអតិបរមានូវគោលដៅសំខាន់ៗ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ដែលបាននិងកំពុងអនុវត្តយ៉ាងសស្រាក់សស្រាំតាំងពីដើមនីតិកាលមក ដើម្បីឆ្លើយតបទៅនឹងឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត ក៏ដូចជាដើម្បីឆ្លើយតបទៅនឹងដំណើរការនៃការផ្លាស់ប្តូរជារចនាសម្ព័ន្ធរបស់សង្គម-សេដ្ឋកិច្ចកម្ពុជា នៅក្នុងបរិការណ៍ថ្មី ទាំងកម្រិតជាតិ និងអន្តរជាតិ។

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ

ធនាគារ និងសវនកម្ម

# របាយការណ៍
## ស្តីពី
## ការពិនិត្យលើសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

សូមគោរពសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា
សូមគោរពសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
សូមគោរពឯកឧត្តមបណ្ឌិត **ខួន សុឌារី** អនុប្រធានទី២ នៃរដ្ឋសភា
សូមគោរពលោកជំទាវឯកឧត្តមសមាជិកា សមាជិករដ្ឋសភានិងភ្ញៀវកិត្តិយសទាំងអស់ជាទីគោរពស្នេហា!

ជាបឋមតាងនាមគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភាខ្ញុំសូមអនុញ្ញាតនាំមកនូវយោបល់របស់គណៈកម្មការ ជម្រាបជូនអង្គសភាក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដូចតទៅ៖

### ១-ទស្សនៈរួមនៃសេចក្តីព្រាងច្បាប់ ៖

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដែលកំពុងស្ថិតក្នុងបរិការណ៍សុខសន្តិភាព ពេញលេញ ឯកភាពទឹកដី ឯកភាពជាតិ និងស្ថិរភាពនយោបាយដែលកើតចេញពីនយោបាយ ឈ្នះ ឈ្នះ និងប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្សនៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់របស់រដ្ឋ។ ព្រះរាជាណាចក្រកម្ពុជាសម្រេចបាននូវការអភិវឌ្ឍរីកចម្រើនល្អគួរលាស់លើគ្រប់វិស័យ ៉ គួរឲ្យកត់សម្គាល់នៅក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនេះ ជាពិសេសការសម្រេចបាននៅក្នុងប្រវត្តិសាស្ត្រ គឺកម្ពុជាបានក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនៅក្នុងឆ្នាំ២០១៥កន្លងទៅ ក៏ដូចជាការ



វិមានរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៥ សារអេឡិចត្រូនិច: sg@national-assemby.org.kh គេហទំព័រ: www.national-assembly.org.kh

សម្រេចបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗផ្សេងទៀត។ ឈរលើគោលការណ៍រីកចម្រើនរបស់ប្រទេសជាតិ ដែលជាកត្តាអំណោយផលទាំងនេះហើយ ដែលធ្វើឲ្យរាជរដ្ឋាភិបាលកម្ពុជា ទទួលបានការសាទរ និងការទទួលស្គាល់ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ដោយស្មើមុខ និងស្មើសិទ្ធិ ជាពិសេសបានផ្តល់នូវក្តីសង្ឃឹម និងភាពជឿជាក់ចំពោះជោគវាសនាអនាគតរបស់ប្រជាជនគ្រប់រូប និងប្រទេសជាតិទាំងមូល នៅក្នុងដំណើរឆ្ពោះទៅសម្រេចបាននូវបង្គោលចរថ្មីទៀត គឺប្រទេស កម្ពុជា មានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានសមធម៌សង្គម ព្រមទាំងការថែរក្សា បរិស្ថានកាន់តែល្អប្រសើរឡើង។

## ២-ឧសុរនៈស្តីពីការពិនិត្យសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

### ក-មូលដ្ឋានគតិយុត្ត

ក្រោយពីបានទទួលសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ពីគណៈកម្មាធិការអចិន្ត្រៃយ៍ នៃរដ្ឋសភាមក គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារនិង សវនកម្ម នៃរដ្ឋសភា បានពិនិត្យឃើញថា មូលដ្ឋាននៃការកសាងថវិកាជាតិឆ្នាំ២០១៨ ដែលរាជរដ្ឋាភិបាលបានរៀបចំឡើងគឺស្របតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ជំពូកទី៥ មាត្រា៥៦ និងមាត្រា៥៧ ជំពូកទី៧ មាត្រា៩០ថ្មី(ពីរ) និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ជំពូកទី១ មាត្រា៨ ជំពូកទី៣ មាត្រា៣៩ ព្រមទាំងបទដ្ឋាននានា ដែលនៅជាធរមាន ហើយមានការពាក់ព័ន្ធ និងវិស័យសេដ្ឋកិច្ចជាតិ ពិសេសគឺស្របតាមការកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈដោយផ្អែកលើលទ្ធផលនៃកិច្ចប្រតិបត្តិការថវិកាឆ្នាំ២០១៧ និងការគណនាក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៨។

### ខ-អំពីកិច្ចប្រតិបត្តិការថវិកាជាតិ

#### I- អំពីគម្រោងចំណូលថវិកាជាតិ

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ គឺពិតជានឹងសម្រេចបានលទ្ធផលក្រោមការចង្អុលបង្ហាញ និងត្រួតពិនិត្យជាប្រចាំរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ដែលជាអាណាប៉ាក់ដើមខ្សែតែមួយគត់ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសេដ្ឋកិច្ចទូទៅ របស់ព្រះរាជាណាចក្រកម្ពុជា។

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ត្រូវបានរាជរដ្ឋាភិបាលគ្រោងប្រមូលចំណូលថវិការដ្ឋឆ្នាំ២០១៨ចំនួន **១៨ ៥៨៧ ០០៣**លានរៀលស្មើនឹង ១៨,៧៥% នៃផ.ស.ស និងមានកំណើន ១១,៩%ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ដោយក្នុងនោះចំណូលចរន្តនៃថវិការដ្ឋត្រូវបានគ្រោងស្មើនឹង១៨,៥៧% នៃផ.ស.ស ដែលមានកំណើន០,១៧ពិន្ទុភាគរយនៃផ.ស.ស ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ថ្វីត្បិតតែកំណើននៃចំណូលចរន្តថវិការដ្ឋបង្ហាញថា មិនដល់គោលដៅដែលត្រូវកើន០,៥ពិន្ទុភាគរយនៃផ.ស.ស ក្នុងមួយឆ្នាំ តែផ្ទុយទៅវិញទំហំចំណូលឆ្នាំ២០១៨ គឺលើសពីគោលដៅចំណូលដែលបានកំណត់ត្រឹមតែ ១៧,៣៥%នៃផ.ស.សសម្រាប់ឆ្នាំ២០១៨ នៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ២០១៤ - ២០១៨។

ថវិកាឆ្នាំ២០១៨ មានការបង្កើនចំណូលក្នុងប្រទេសថ្នាក់ជាតិឲ្យស្មើនឹង១៧,៨០%នៃផ.ស.សគឺស្មើនឹង១៧ ៦៤០ ១៩៩លានរៀលដែលមានកំណើន១២,៧%ធៀបនឹងច្បាប់ឆ្នាំ២០១៧ តាមគោលដៅ៖

+ **ចំណូលចរន្ត៖**ត្រូវសំរេចឲ្យបាន១៧ ៨៦០ ០០៦លានរៀល ត្រូវជា១៧,៦២% នៃផ.ស.សគឺមានកំណើនស្មើនឹង១២,៦%ធៀបនឹងច្បាប់ឆ្នាំ២០១៧។

    - **ចំណូលសារពើពន្ធ៖**ត្រូវសំរេចអោយបាន ១៥ ០៧៥ ៥៦២លានរៀលត្រូវជា ១៥,២១% នៃផ.ស.ស មានកំណើន១៤,១% ធៀបនឹងច្បាប់ឆ្នាំ២០១៧។
    - **ចំណូលមិនមែនសារពើពន្ធ៖**ត្រូវបានគ្រោងចំនួន ២ ៣៨៤ ៨៤៤លានរៀល ត្រូវជា២,៨១%នៃផ.ស.ស មានកំណើន៤,០%ធៀបនឹងច្បាប់ឆ្នាំ២០១៧។

+ **ចំណូលមូលធន៖**ត្រូវបានគ្រោងចំនួន ៤ ៧៩៩ ១៣២លានរៀលត្រូវជា ៥,០២% នៃផ.ស.ស មានកំណើន ៦,៣% ធៀបនឹងច្បាប់ឆ្នាំ២០១៧។

    - **ចំណូលមូលធនក្នុងប្រទេស** (ចំណូលពីប្រភពផ្ទាល់) ត្រូវសំរេចឲ្យបានចំនួន ១៨០ ១៩៣លានរៀលត្រូវជា ០,១៨% នៃផសស គឺមានកំណើន១,៨% ធៀបនឹងច្បាប់ឆ្នាំ២០១៧។ (ជាចំណូលមានប្រភពពីការសងត្រឡប់មកវិញនូវប្រាក់ដើមនៃការខ្ចីពីសហគ្រាសសាធារណៈរបស់រដ្ឋ)។
    - **ចំណូលមូលធនក្រៅប្រទេស**ត្រូវសម្រេចឲ្យបានចំនួន៤ ៧៩៦ ៩៣៩លានរៀលត្រូវជា ៤,៨៤% នៃផ.ស.ស មានកំណើន៥,៨% ធៀបនឹងច្បាប់ឆ្នាំ២០១៧។

**II- តំរាងចំណាយថវិកាជាតិ ៖**

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ត្រូវបានរាជរដ្ឋាភិបាលរៀបចំនូវថវិកាចំណាយដូចតទៅ៖

**ក- ចំណាយសរុបថវិកាថ្នាក់ជាតិនៅឆ្នាំ២០១៨** ត្រូវបានគ្រោងក្នុងទឹកប្រាក់២៣ ៤២៨ ២៩៨ លានរៀល ស្មើនឹង២៣,៦៤%នៃផសស គឺមានកំណើន ១៦,១%ធៀបនឹងច្បាប់ឆ្នាំ ២០១៧។

- **ចំណាយចរន្ត**ត្រូវបានកំណត់ឲ្យស្ថិតក្នុងកម្រិតចំនួន ១៥ ២១៨ ១៦៦លានរៀល ត្រូវជា១៥,៣៥% នៃផ.ស.សគឺមានកំណើន១៦,៦% ធៀបនឹងច្បាប់ឆ្នាំ២០១៧ដែលក្នុងនោះ៖**ចំណាយលើបន្ទុកបុគ្គលិក**ត្រូវបានគ្រោងចំនួន ៧ ៩១៤ ៩២៤លានរៀល មានសមាមាត្រ៥២,០% នៃចំណាយចរន្តថវិកាថ្នាក់ជាតិត្រូវជា ៧,៩៩% នៃផ.ស.សគឺមានកំណើន ១៦,៣% ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះត្រូវបានគ្រោង (១)- ការដំឡើងប្រាក់បៀវត្សក្នុងអត្រា១២,០% ដោយដំឡើងបៀវត្សមូលដ្ឋានតាមតម្លៃឯកតាសន្ទស្សន៍ ២១៣០ រៀល ដោយគិតចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៨ និង(២)- ការដំឡើងប្រាក់បំណាច់មុខងារនឹងចាប់អនុវត្តពីខែមេសា ដល់ខែធ្នូ ឆ្នាំ២០១៨ របស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ (នគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ)។ **ចំណាយក្រៅបន្ទុកបុគ្គលិក** ត្រូវបានគ្រោងចំនួន ៧ ៣០៣ ២៤៣លានរៀល មានសមាមាត្រ៤៨,០% នៃចំណាយចរន្តថវិកាថ្នាក់ ជាតិ ត្រូវជា៧,៣៧% នៃផ.ស.ស គឺមានកំណើន១៦,៩% ធៀបនឹងឆ្នាំ២០១៧។

ចំណាយចរន្តថវិកាថ្នាក់ជាតិនេះ ត្រូវបានវិភាជន៍ទៅតាមវិស័យគ្របដណ្តប់លើក្រសួង ស្ថាប័នទាំង៣៩ ហើយនៅកម្រិតក្រសួងស្ថាប័ននីមួយៗវិញ ត្រូវធ្វើការវិភាជបន្តទៅតាមកម្មវិធី អនុកម្មវិធី រហូតដល់ចង្កោមសកម្មភាព តាមរយៈការឆ្លុះបញ្ចាំងយ៉ាងលម្អិតទៅតាមមាតិកាសេដ្ឋកិច្ចនៃចំណាត់ថ្នាក់ថវិកា ដោយផ្អែកលើតម្រូវការ និងអាទិភាពចាំបាច់ ដូចតទៅ៖

- **ចំណាយរដ្ឋបាលទូទៅ**៖ត្រូវបានគ្រោងចំនួន ២ ២៦៣ ៣០៤លានរៀល មានសមាមាត្រនឹង១៤,៩% នៃចំណាយចរន្តថវិកាថ្នាក់ជាតិមានកំណើន ១៣,៩%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ត្រូវជា ២,២៨%នៃផ.ស.ស។

- <u>**ចំណាយវិស័យការពារជាតិសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ៖**</u> ត្រូវបានគ្រោងចំនួន៣ ៨៩៤ ៣៧៦លានរៀលមានសមាមាត្រស្មើនឹង ២៥,៦% នៃចំណាយចរន្តថវិកាថ្នាក់ជាតិមាន កំណើន១៦,៧% ធៀបនឹងច្បាប់ឆ្នាំ២០១៧ ត្រូវជា ៣,៩៣%នៃផ.ស.ស។

- <u>**ចំណាយវិស័យសង្គមកិច្ច៖**</u> ត្រូវបានគ្រោងចំនួន ៥ ៦៥៨ ៩៥៩លានរៀលមានសមាមាត្រស្មើនឹង៣៧,២%នៃចំណាយចរន្តថវិកាថ្នាក់ជាតិត្រូវជា៥,៧១%នៃផ.ស.ស មានកំណើន១៧,០% ធៀបនឹងច្បាប់ឆ្នាំ២០១៧។

**ខ- ចំណាយថវិកាថ្នាក់ក្រោមជាតិ (រាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់)** ត្រូវបានគ្រោងក្នុងទឹកប្រាក់១ ៦៨៤ ៦៧៤ លានរៀល មានសមាមាត្រ ស្មើនឹង៦,៩%នៃចំណាយថវិការដ្ឋសរុប ដែលត្រូវជា១,៧០%នៃផសស គឺមានកំណើន ៤,៩%ធៀបនឹងច្បាប់ឆ្នាំ២០១៧។

**III- អំពីថវិកាខ្ចីពីបរទេស៖**

នៅឆ្នាំ២០១៨ ខាងមុខនេះរាជរដ្ឋាភិបាលកម្ពុជាបានស្នើសុំឲ្យអង្គការនីតិប្បញ្ញត្តិអនុម័ត ជូននូវទឹកប្រាក់កម្រិត១ ០០០ ០០០ ០០០SDR (មួយប៊ីលានអេសឌីអរ)ជាប្រាក់ខ្ចីដែលមានលក្ខណៈ ជាការខ្ចីសម្បទានដោយត្រូវសងវិញជាការប្រាក់អនុគ្រោះបំផុត។

ចំពោះការខ្ចីប្រាក់ពីបរទេសនេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅតែបន្តណែនាំឲ្យធ្វើតាមលក្ខខណ្ឌ៤យ៉ាងដោយប្រុងប្រយ័ត្ន (១)- ត្រូវខ្ចីឥណទានមានទំហំសមស្របនឹងស្ថានភាពថវិកានិងសេដ្ឋកិច្ចជាតិដែលអាចទ្រាំទ្រសងគេបាន (២)- ត្រូវខ្ចីឥណទានដែលមានកម្រិតសម្បទានខ្ពស់ (៣)- ត្រូវខ្ចីឥណទានសម្រាប់តែវិស័យអាទិភាព សំដៅទ្រទ្រង់ចីរភាពនៃកំណើន និងបង្កើនផលិតភាពសេដ្ឋកិច្ច និង(៤)- ត្រូវប្រើប្រាស់ឥណទានប្រកបដោយតម្លាភាព និងមានប្រសិទ្ធខ្ពស់បំផុត ពិសេសអនុវត្តនូវគោលការណ៍អភិបាលកិច្ចល្អ។

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ នេះ មាន៦ ជំពូក និងមាន ១៥មាត្រា មានទម្រង់ដូចនឹងសេចក្តីព្រាងច្បាប់មុនៗ ប៉ុន្តែខុសពីសេចក្តីព្រាងច្បាប់មុនៗ ដោយនៅក្នុងជំពូកទី៣ មានការដាក់បញ្ចូលបទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ ក្នុងច្បាប់ស្តីពីសារពើពន្ធ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នូវបទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងការប្រមូលពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ។ រីឯច្បាប់ស្តីពីសត្តឃាតត្រូវទុកជានិរាករណ៍។

**៣.សេចក្តីសន្និដ្ឋាន៖**

សេចក្តីព្រាងច្បាប់នេះគឺជាឧបករណ៍ នៃគោលនយោបាយដ៏សំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៥ នៃរដ្ឋសភា ដែលបានបំពើជាតិមាតុភូមិ និងប្រជាជនប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ព្រមទាំងបានបុកគ្រឹះសម្រាប់បម្រើឲ្យការអភិវឌ្ឍរបស់កម្ពុជាតទៅមុខទៀត។ ដើម្បីបន្តជំរុញការអនុវត្តនូវ **"គោលដៅជាយុទ្ធសាស្ត្រ"** និង **"វិស័យអាទិភាព"** នៃ **"យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣"** ដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដែលជា **"របៀបវារៈគោលនយោបាយសង្គម - សេដ្ឋកិច្ច"** នៃ **"កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា"**។ រាជរដ្ឋាភិបាលកម្ពុជាអាចធានាបាននូវដំណើរផ្លាស់ប្តូរមួយឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយគុណភាព និងចីរភាព ដោយផ្សារភ្ជាប់ការគិតគូរអំពីតុល្យភាពនៃកំណើនសេដ្ឋកិច្ច និងការបែងចែកផលនៃកំណើននេះឲ្យឈានទៅរកជីវភាពរស់នៅប្រចាំថ្ងៃនិងបំណងប្រាថ្នារបស់ប្រជាជន។

ថវិកាឆ្នាំ២០១៨ អាចប្រសិទ្ធនាមបានថា " ថវិកាយុទ្ធសាស្ត្រ នៃការពូនផ្តុំកម្លាំង និងធនធានជាអតិបរិមា ដើម្បីសម្រេចឲ្យខាងតែបាននូវគោលដៅសំខាន់ៗ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៥ នៃរដ្ឋសភា នៅក្នុងសភាពការណ៍តំបន់ និងលើសកលលោកដើម្បីបន្តរក្សាសន្តិភាព និងស្ថិរភាព ក៏ដូចជា ការទ្រទ្រង់នូវដំណើរការវិវត្តឈានឡើងរបស់កម្ពុជាលើវិថីនៃការអភិវឌ្ឍប្រកប ដោយគុណភាព និងចីរភាពតទៅមុខឥតឈប់ឈរក្នុងនីតិកាលនៃរដ្ឋសភាបន្តបន្ទាប់ទៀត"។

តាងនាមគណៈកម្មការសេដ្ឋកិច្ចហិរញ្ញវត្ថុធនាគារ និងសវនកម្មនៃរដ្ឋសភា ខ្ញុំស្នើសូមដាក់សេចក្តីព្រាងច្បាប់នេះជូនអង្គសភាមេត្តាពិនិត្យពិភាក្សានិងអនុម័តមួយជំពូកម្តងៗ ស្របតាមប្រការ២៥ថ្មីនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដោយចាត់ទុកជាការប្រញាប់តាមការគួរ។

សូមអរគុណ !

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០១៧

**ជ.គណៈកម្មការសេដ្ឋកិច្ចហិរញ្ញវត្ថុធនាគារនិងសវនកម្ម**

**ប្រធាន**

**បណ្ឌិតរដ្ឋ ចាម ប្រសិទ្ធ**

# ឧបសម្ព័ន្ធ១០ ៖

# លិខិតអញ្ជើញប្រជុំ
# គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាលើកទី១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
លេខ ២៣៤/២០១៧ ពស/ន.វ

# ប្រធានព្រឹទ្ធសភា

សូមអញ្ជើញ ឯកឧត្តមអនុប្រធានទី១ ឯកឧត្តមអនុប្រធានទី២ ព្រឹទ្ធសភា ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកា គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា មកចូលរួមប្រជុំ នៅថ្ងៃចន្ទ ទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង ១៥ : ០០ នាទីរសៀល នៅសាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។

សូមជូនភ្ជាប់ជាមួយនូវរបៀបវារៈប្រជុំ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧

**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ**

សំណៀកបំពាក់ : ធំ

# របៀបវារៈ

# ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

(ថ្ងៃចន្ទ ទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ ម៉ោង ១៥ : ០០នាទីរសៀល)

---

១- ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ។

២- ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើ៖

១. កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

២. កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

៣. កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះចៅស៊ុលតង់ និងយ៉ាងឌីពើរតួននៃប្រទេសប្រ៊ុយណេដារូសាឡឹម ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

២. កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបគេងបន្ទុំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

៣- ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ។

៤- ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើធម្មនុញ្ញនៃមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី ។

# ឧបសម្ព័ន្ធ១១ ៖

# លិខិតបញ្ជូនសេចក្តីព្រាងច្បាប់ ទៅគណៈកម្មការទទួលបន្ទុកដើម្បីសិក្សា

ព្រឹទ្ធសភា

លេខ ៦៣៥.២០១៧/ពស/ន៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សូមជម្រាបជូន**

**ឯកឧត្តម ប្រធានគណៈកម្មការ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម**

**កម្មវត្ថុ** : អំពីការពិនិត្យ សិក្សាលើសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

**យោង** : ប្រការ ៣២ ជំពូកទី ៦ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

តាមខ្លឹមសារដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម** ជ្រាបថា ព្រឹទ្ធសភាបានទទួលសេចក្តីព្រាងច្បាប់នេះពីរដ្ឋសភា តាមលិខិតលេខ: ៤១៩ រស ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នាកិច្ចប្រជុំថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ សម្រេចប្រគល់ការកិច្ចជូនគណៈកម្មការទី២ ដើម្បីពិនិត្យសិក្សា ដោយចាត់ទុកជាការប្រញាប់ ។ ខ្ញុំសូមប្រគល់ឯកសារនេះជូន **ឯកឧត្តម** ដើម្បីចាត់ការតាមនីតិវិធីបន្ត និងនាំយកយោបល់របស់គណៈកម្មការ មកជម្រាបជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គព្រឹទ្ធសភា នាពេលខាងមុខ ។

សូម **ឯកឧត្តម** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រ អំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧

ជ.ប្រធានព្រឹទ្ធសភា

អនុប្រធានទី២

**តេព ងន**

**ចម្លងជូន :**

- គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា (ដើម្បីជ្រាបជាព័ត៌មាន)
- ឯកសារ - កាលប្បវត្តិ

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

# ឧបសម្ព័ន្ធ១២ ៖

# លិខិតរបស់គណៈកម្មការទទួលបន្ទុកស្នើសុំ
# បញ្ចូលក្នុងរបៀបវារៈនៃកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា

ព្រឹទ្ធសភា
គណៈកម្មការ សេដ្ឋកិច្ច
ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
លេខ: ១០០/១១១៧/គ.សហធស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សូមគោរពជម្រាបជូន
# សម្តេចប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

**កម្មវត្ថុ** : សំណើសុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ចូលក្នុងរបៀបវារៈនៃសម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៣ ។

**យោង** : -ប្រការ៣៣ ជំពូកទី៦ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
-លិខិតរបស់ព្រឹទ្ធសភាលេខ១៣៥/១១១៧/ពស/នវ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **សម្តេចប្រធាន** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា បានទទួលការប្រគល់ភារកិច្ចពីគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យ សិក្សា និងរាយការណ៍ជូនអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គប្រជុំព្រឹទ្ធសភា លើសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ។ គណៈ-កម្មការបានធ្វើការប្រជុំពិនិត្យ សិក្សាចប់សព្វគ្រប់រួចជាស្ថាពរ នៅថ្ងៃព្រហស្បតិ៍ ទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ដោយមានការចូលរួមឆ្លើយបំភ្លឺពីតំណាងរាជរដ្ឋាភិបាល (ក្រសួងសេដ្ឋ-កិច្ច និងហិរញ្ញវត្ថុ) ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចប្រធាន** មេត្តាពិនិត្យ និងសម្រេច ដាក់បញ្ចូលសេចក្តីព្រាងច្បាប់នេះ ក្នុងរបៀបវារៈប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គប្រជុំព្រឹទ្ធសភា ចាត់ទុកជាការប្រញាប់ ដោយក្តីអនុគ្រោះ ។

សូម **សម្តេចប្រធាន** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុត អំពីខ្ញុំបាទ ។

<u>សូមជូនភ្ជាប់</u> : របាយការណ៍ពិនិត្យលើសេចក្តីព្រាងច្បាប់ចំនួន ០១ ច្បាប់ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧
**ប្រធានគណៈកម្មការ**

**ជា ចេដ្ឋ**

**<u>ចម្លងជូន</u>** :
- គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា
- ខុទ្ទកាល័យឯ.ឧអគ្គលេខាធិការព្រឹទ្ធសភា
- ខុទ្ទកាល័យឯ.ឧអគ្គលេខាធិការរងព្រឹទ្ធសភា
- អគ្គនាយកដ្ឋានទាំងបី ចំណុះ អ.ព.ស
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ព្រឹទ្ធសភា**
**គណៈកម្មការ សេដ្ឋកិច្ច**
**ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម**

# របាយការណ៍
# ស្តីពី
# ការពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់
# ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

**- សូមគោរពសម្តេចវិបុលសេនាភក្តីប្រធានព្រឹទ្ធសភា**
**- សូមគោរពឯកឧត្តមអនុប្រធានទី១ និង ឯកឧត្តមអនុប្រធានទី២ ព្រឹទ្ធសភា**
**- សូមគោរពសមាជិក សមាជិកាព្រឹទ្ធសភា**
**- សូមគោរពតំណាងរាជរដ្ឋាភិបាល និងសហការី**
**- សូមគោរពភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ដែលមានវត្តមាននៅទីនេះ!**

*តាងនាមគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា ខ្ញុំបាទ សូមគោរពអនុញ្ញាត នាំយកយោបល់ស្តីពីការពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ មកជម្រាបជូនដូចតទៅ ៖*

*គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានបញ្ជូនសេចក្តីព្រាងច្បាប់នេះ ដោយភ្ជាប់ជាមួយនូវសេចក្តីថ្លែងហេតុ មកគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម តាមលិខិតលេខ ១៣៥/១១១៧/ពស/ន.រ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ដើម្បីពិនិត្យសិក្សា និងនាំយកយោបល់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គប្រជុំព្រឹទ្ធសភា ស្របតាមប្រការ៣២ ជំពូកទី៦ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។*

*ក្រោយពីបានទទួលសេចក្តីព្រាងច្បាប់នេះ គណៈកម្មការបានសុំយោបល់ពីគ្រប់សមាជិកព្រឹទ្ធសភាទាំងអស់តាមលិខិតលេខ ០៩២/១១១៧/គ.សហធស ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ស្របតាមប្រការ៣២ ជំពូកទី៦ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។*

*គណៈកម្មការទទួលយោបល់ឆ្លើយតបពីសមាជិក សមាជិកាព្រឹទ្ធសភាវិញ មានយោបល់យល់ព្រមដោយឥតកែប្រែចំនួន ៤៨រូប ។ សមាជិក សមាជិកាព្រឹទ្ធសភាចំនួន ១៣រូប ពុំបានឆ្លើយតប (សុំអនុញ្ញាតច្បាប់ចំនួន ០១ រូប និងមរណភាពចំនួន ០១ រូប) ។*

*នារសៀលថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៧ គណៈកម្មការបានបើកកិច្ចប្រជុំ ដោយមានការអញ្ជើញចូលរួមឆ្លើយបំភ្លឺពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងមានការចូលរួមពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធចំណុះអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ហើយបានទទួលលទ្ធផលដូចខាងក្រោម៖*



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855-23) 630 08 09 ទូរសារ: (855-23) 211 446 Email: senatecom2@gmail.com

១- **អំពីទម្រង់នៃសេចក្តីព្រាងច្បាប់**

*សេចក្តីព្រាងច្បាប់នេះ តាក់តែងឡើងជាលាយលក្ខណ៍អក្សរ មានចំណងជើងនៃច្បាប់ រួមមាន ០៦ ជំពូក ចែកជា ១៩ មាត្រា និងមានតារាងឧបសម្ព័ន្ធចំនួន ២២ទំព័រ ព្រមទាំងសេចក្តីថ្លែងហេតុ បញ្ជាក់អំពីហេតុផល និងគោលបំណងភ្ជាប់មកជាមួយ ។*

*សេចក្តីព្រាងច្បាប់នេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមជាលើកដំបូងចំនួន ៦៥ សំឡេង នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ ។ រដ្ឋសភាបានបញ្ជូនសេចក្តីព្រាងច្បាប់នេះ មកព្រឹទ្ធសភាដើម្បីពិនិត្យ និងឲ្យយោបល់ តាមលិខិតលេខ ៤១៩រ.ស ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ស្របតាមមាត្រា ១១៣ថ្មី ជំពូកទី៨ថ្មី នៃរដ្ឋធម្មនុញ្ញ ។*

២- **អំពីខ្លឹមសារនៃសេចក្តីព្រាងច្បាប់**

*សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ គឺជាសេចក្តីព្រាងច្បាប់ដែលបង្ហាញឲ្យឃើញពីភាពជោគជ័យ និងលទ្ធផលការងារដែលរាជរដ្ឋាភិបាលសម្រេចបាន ព្រមទាំងវិធានការសំខាន់ៗនៅក្នុងឆ្នាំចុងក្រោយរបស់រាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា និងក្នុងបរិការណ៍ដែលព្រះរាជាណាចក្រកម្ពុជា បាននឹងកំពុងទទួលផលពីសុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ និងស្ថិរភាពនយោបាយ ដែលកើតចេញពីនយោបាយឈ្នះឈ្នះ និងការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់ ។ ជាមួយគ្នានេះដែរ ថវិកាឆ្នាំ២០១៨ គឺជាថវិកាបំរើឲ្យសង្គមកិច្ចដែលផ្តល់ជាគុណប្រយោជន៍ដល់ប្រជាពលរដ្ឋទូទៅ ជាពិសេសអ្នកមានចំណូលទាប រួមទាំងមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករ-និយោជិត ក៏ដូចជាអ្នកប្រកបអាជីវកម្មតូចតាច ឲ្យទទួលបាននូវប្រាក់ចំណូលកាន់តែខ្ពស់ពីមួយឆ្នាំទៅមួយឆ្នាំ តាមរយៈការអនុវត្តនូវគោលនយោបាយ និងវិធានការចាំបាច់មួយចំនួនរបស់រាជរដ្ឋាភិបាលរួមមានការតម្លើងប្រាក់បៀវត្សក្នុងគោលដៅជាង ១ លានរៀល ឲ្យបាននៅត្រឹមឆ្នាំ២០១៨ ហើយនិវត្តជនក៏បានទទួលនូវការបង្កើនប្រាក់សោធននិវត្តន៍ និងរបបតាវកាលិកផ្សេងទៀត ជាបន្តបន្ទាប់ផងដែរ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលសម្រេចផ្តល់ និងតម្លើងប្រាក់ឧបត្ថម្ភគោលនយោបាយគាំពារសង្គមចំនួន ២ មុខទៀតគឺ (១)-ផ្តល់ប្រាក់ឧបត្ថម្ភមាតុភាពដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទជាស្ត្រី ដោយបង្កើនពី ៦០ម៉ឺនរៀល ទៅ ៨០ម៉ឺនរៀល សម្រាប់ការសម្រាលបានកូនមួយ និងចំនួន ១លាន ៦សែនរៀល សម្រាប់សម្រាលបានកូនភ្លោះពីរ និង(២)-ផ្តល់ប្រាក់ឧបត្ថម្ភបុណ្យសពមន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព ដោយក្នុងម្នាក់ៗត្រូវបានតម្លើងពីចំនួន ១លាន ២សែនរៀល ទៅ ២លានរៀល ចំពោះមរណភាពដោយជម្ងឺធម្មតា និងតម្លើងពីចំនួន ១លាន ៥សែនរៀល ទៅ ២លានរៀល ចំពោះមរណភាព*

*ក្នុងពេលបំពេញបេសកកម្ម ឬគ្រោះថ្នាក់ការងារ ។ ចំណែកកម្មករ-និយោជិតរាប់សែននាក់ទៀត ដែលកំពុងតែបម្រើការងារក្នុងវិស័យឯកជន ក៏ទទួលបាននូវឱកាសបង្កើនប្រាក់ចំណូលរបស់ខ្លួន តាមរយៈគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការតម្លើងប្រាក់ឈ្នួលអប្បបរមាជារៀងរាល់ឆ្នាំ ដែលនៅឆ្នាំ២០១៨ ប្រាក់ឈ្នួលអប្បបរមានេះ នឹងត្រូវកើនឡើងដល់ចំនួន* **១៧០ ដុល្លារអាមេរិក** *ព្រមទាំងការទទួលបាននូវអត្ថប្រយោជន៍បន្ថែមផ្សេងទៀតពីការអនុវត្តគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាលដូចជា (១)-ការគាំទ្រដល់ការពង្រីកមូលនិធិសមធម៌ ដើម្បីផ្តល់សេវាសុខាភិបាលដោយឥតគិតថ្លៃដូចប្រជាជនដែលមានប័ណ្ណក្រីក្រដែរ និង(២)-ការគាំទ្រដល់ការឧបត្ថម្ភមាតុភាព ដោយបើកផ្តល់ថវិកាចំនួន ៤០ម៉ឺនរៀល ចំពោះការសម្រាលបានកូនមួយ និងថវិកាចំនួន ៨០ម៉ឺនរៀល ចំពោះការសម្រាលបានកូនភ្លោះពីរ ។ ក្រៅពីនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវវិធានការគោលនយោបាយចាំបាច់នានា ជាបន្តបន្ទាប់ក្នុងគោលដៅដោះស្រាយការលំបាក ក្តីកង្វល់ និងបំណងប្រាថ្នារបស់ប្រជាជនដូចជា ការលុបចោលមិនយកកម្រៃពីសេវាសាធារណៈចាំបាច់មួយចំនួន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរួមមាន ការលុបប័ណ្ណបើកបរទោចក្រយានយន្ត ការលើកលែងពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ទោចក្រយានយន្ត និងត្រីចក្រយានយន្តកម្លាំងក្រោម ១៥០ សេះ កម្រៃសេវាសាធារណៈលើលិខិតបញ្ជាក់កំណើត អាពាហ៍ពិពាហ៍ អត្តសញ្ញាណប័ណ្ណជាដើម ការបញ្ចុះថ្លៃថាមពលអគ្គិសនី និងទឹកស្អាត ការលុបចោលរបបពន្ធម៉ៅការ ការតម្លើងកម្រិតអប្បបរមានៃប្រាក់បៀវត្សត្រូវជាប់ពន្ធ ការលើកលែងពន្ធប្រថាប់ត្រាក្នុងវង្វង់សាច់ញាតិ ការលុបចោលការបង់កាស៊ី និងថ្លៃផ្សេងៗទៀត ចំពោះការលក់ដូររបស់ប្រជាពលរដ្ឋតាមកញ្ច្រែង កញ្ជើ ល្អី ការអនុញ្ញាតឲ្យអាជីវករដែលមានតូប រាន ស្តង់ ឬកន្លែងលក់ដូរដទៃទៀត ទទួលបានសិទ្ធិកាន់កាប់ ប្រើប្រាស់អាស្រ័យផល ហើយអាចផ្ទេរសិទ្ធិនេះបាន ការលុបចោលពន្ធសត្តឃាត និងការគ្រប់គ្រងផ្តាច់មុខនៅក្នុងអាជីវកម្មសត្តឃាតដ្ឋាន ជាពិសេសការសម្រេចទិញយកមកគ្រប់គ្រងវិញនូវគម្រោងផ្លូវ និងស្ពានមួយចំនួនពីវិស័យឯកជន ព្រមទាំងការផ្តល់ថវិកាចំនួន ២០ប៊ីលានរៀលដល់មូលនិធិទ្រទ្រង់និរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា បន្ថែមលើថវិកា ៤០ប៊ីលានរៀល ដើម្បីធានាថាមន្ទីរពេទ្យនេះនៅតែអាចរក្សាបាននូវស្តង់ដាគុណភាព និងការផ្តល់សេវាព្យាបាលដោយឥតគិតថ្លៃដដែល ។*

*ម៉្យាងវិញទៀតឆ្នាំ២០១៨ គឺជាឆ្នាំនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៤ ផង និងជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ផង ដែលតម្រូវឲ្យរាជរដ្ឋាភិបាលធានាឲ្យការបោះឆ្នោតទាំងពីរនេះ ប្រព្រឹត្តទៅដោយភាពរលូន មានសណ្តាប់ធ្នាប់ និងប្រកបដោយតម្លាភាព ទន្ទឹមនឹងការធានាឲ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាទូទៅ ជាពិសេស ការធានារក្សាការពារឲ្យបានដាច់ខាត នូវសុខសន្តិភាព និងស្ថិរភាពសង្គម ដែលសម្រេចបានមកដោយលំបាក ឲ្យស្ថិតស្ថេរគង់វង្សចីរកាល ។*

ក្នុងក្របខ័ណ្ឌថវិកាឆ្នាំ២០១៨ ការគ្រប់គ្រងបានល្អ រឹងមាំ និងដោយចីរភាពនៃថវិកាជាតិ ទាំងនៅក្នុងផ្នែកចំណូល និងទាំងក្នុងផ្នែកចំណាយ ជាពិសេស ការសម្រេចបាននូវកំណើនចំណូលដ៏ខ្ពស់ និងមិនធ្លាប់មាននៅក្នុងរយៈពេល ២០ ឆ្នាំចុងក្រោយនេះ បាននាំកម្ពុជាដែលធ្លាប់មានចំណូលថវិកាជាតិធៀបនឹង ផ.ស.ស ទាបជាងគេក្នុងតំបន់ ឲ្យឈានឡើងដល់កម្រិតកណ្តាលធៀបនឹងគេវិញ ហើយមូលនិធិរូបិយវត្ថុអន្តរជាតិ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដទៃទៀត ក៏បានផ្តល់ការវាយតម្លៃខ្ពស់លើសមិទ្ធផលនៃការខិតខំប្រឹងប្រែងនេះផងដែរថា មិនធ្លាប់មានពីមុនមកនៅក្នុងបណ្តាប្រទេសក្នុងតំបន់ ។ បើគិតពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៨ ចំណូលចរន្តថវិការដ្ឋកើនឡើងជាងពីរដង ពីប្រមាណ ២២៦៤ លានដុល្លារអាមេរិក ដល់ប្រមាណ ៤៥៦០ លានដុល្លារអាមេរិក។ ជាលទ្ធផល ការកើនឡើងនៃទំហំចំណូលនេះ បានផ្តល់លទ្ធភាពឲ្យរាជរដ្ឋាភិបាលបង្កើនចំណាយយ៉ាងច្រើនទៅលើការលើកកម្ពស់គុណភាព និងការពង្រីកវិសាលភាពនៃសេវាសាធារណៈ ទាំងតាមរយៈចំណាយចរន្តជាតិ និងទាំងតាមរយៈចំណាយវិនិយោគសាធារណៈ ដើម្បីធ្វើឲ្យការផ្តល់សេវាសាធារណៈមានភាពកាន់តែប្រសើរឡើង និងកាន់តែខិតជិតប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់ ។ បើគិតពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៨ ចំណាយសរុបថវិការដ្ឋត្រូវបានបង្កើនជិតពីរដង ក្នុងនោះ ចំណាយសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡាត្រូវបានបង្កើនជាងបីដង ចំណាយសរុបរបស់ក្រសួងសុខាភិបាល ត្រូវបានបង្កើនជិតពីរដងកន្លះ ចំណាយសរុបរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានបង្កើនជិតបីដង ហើយចំណាយវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានបង្កើនជិតពីរដងកន្លះ ។

មួយវិញទៀត សមាមាត្រនៃចំណូលថវិកាពីប្រភពហិរញ្ញប្បទានក្រៅប្រទេសក្នុងចំណែកថវិកាជាតិបានថយចុះពីប្រមាណជិត ៧០% នៅក្នុងឆ្នាំ១៩៩៨ មកនៅត្រឹមតែប្រមាណ ២១,៤% ប៉ុណ្ណោះ ក្នុងឆ្នាំ២០១៧ ហើយនឹងបន្តថយចុះថែមទៀត នៅមិនដល់ ២០% ផងទេ នៅឆ្នាំ ២០១៨ ។ **ប្រការនេះ គឺជាការសបញ្ជាក់ឲ្យឃើញថា កម្ពុជាកាន់តែមានឯករាជ្យភាពខាងថវិកាជាងមុន និងកាន់តែមានភាពជាម្ចាស់ជាងមុន ដែលនេះគឺជាផ្លែផ្កានៃកិច្ចខិតខំប្រឹងប្រែងអនុវត្តក្នុងឆន្ទៈប្តូរផ្តាច់ឥតងាករេនូវវិធានការមុតស្រួចទាំងឡាយ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលដែលត្រូវបានចាប់ផ្តើមតាំងពីនីតិកាលមុនមក ។**

ឈរលើមូលដ្ឋានខាងលើនេះ ថវិកាឆ្នាំ២០១៨ គឺជាគោលនយោបាយវិត្តារកម្មថវិកាប្រយ័ត្នប្រយែង ក្នុងគោលដៅថែរក្សានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងទ្រទ្រង់កំណើនរយៈពេលខ្លី ព្រមទាំងបង្កើតលក្ខខណ្ឌចាំបាច់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម និងវែង ជាពិសេស ដើម្បីធានាចលនការនៃការកែទម្រង់ដែលរាជរដ្ឋាភិបាលបាន និងកំពុងបន្តជំរុញអនុវត្តយ៉ាងសស្រាក់សស្រាំ តាំងពីដើមនីតិកាលមក ហើយក៏កំពុងបន្តតម្រង់ តម្រឹម និងពន្លឿន ការអនុវត្តបញ្ចប់នូវកម្មវិធី និងអាទិភាពគោលនយោបាយសំខាន់ៗ ស្របតាមបំណងប្រាថ្នារបស់ប្រជាជនកម្ពុជា ព្រមទាំងគិតគូរផងដែរ ទៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៤ និងជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ និងការត្រៀមទប់ទល់នឹងវិបត្តិ ដែល

*អាចកើតមានឡើងដោយថាហេតុ ក៏ដូចជាផ្តល់ការឆ្លើយតបទៅនឹងបរិការណ៍ថ្មីរបស់កម្ពុជា ទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងប្រទេស ទាំងក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក ជាពិសេស ដើម្បីសម្រេចឱ្យបានជាអតិបរមា នូវគោលដៅជាយុទ្ធសាស្ត្រទាំង៤ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បី កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ។*

*ក្នុងគោលដៅខាងលើនេះ ថវិកាឆ្នាំ២០១៨ ត្រូវបានរៀបចំឡើងដោយផ្អែកលើគោល-ការណ៍គ្រឹះជាយុទ្ធសាស្ត្រសំខាន់ចំនួន៤ ដែលក្នុងនោះរួមមាន៖*

(១)- *ធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧% ដើម្បីបន្តបង្កើតការងារថ្មីកាន់តែច្រើនជូនប្រជាជន*

(២)- *ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច*

(៣)- *បន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដោយផ្តោតជាពិសេសលើសកម្មកែទម្រង់ដែលផ្តល់លទ្ធផលភ្លាមៗ និង*

(៤)- *ផ្តល់ការលើកទឹកចិត្តដល់ក្រសួងស្ថាប័នណា ដែលអនុវត្តសកម្មភាពការងាររបស់ខ្លួនប្រកបដោយបុរេសកម្ម និងមានសមិទ្ធកម្ម ឬលទ្ធផលការងារល្អ ។*

*ឈរលើគោលការណ៍គ្រឹះទាំងនេះ ថវិកាឆ្នាំ២០១៨ ត្រូវបានផ្តោតជាពិសេសទៅលើ៖*

(១)- *ការបន្តតម្លើងប្រាក់បៀវត្សជូនដល់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធឱ្យបានជាង ១លានរៀល*

(២)- *ការបន្តវិនិយោគលើធនធានមនុស្ស ព្រមជាមួយនឹងការជំរុញអនុវត្តនូវក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៧-២០២៥ របស់រាជរដ្ឋាភិបាល*

(៣)- *ការកែទម្រង់សំដៅលើកកម្ពស់ និងកែលម្អប្រសិទ្ធភាព និងគុណភាពសេវាសាធារណៈគ្រប់វិស័យ និង*

(៤)- *ការផ្តល់អាទិភាពលើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលត្រូវបានកសាងរួច ។*

***ក្របខ័ណ្ឌថវិកាឆ្នាំ២០១៨ ត្រូវបានរៀបចំឡើងក្រោមការកំណត់ដូចតទៅ៖***

*តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចកម្ពុជា នៅឆ្នាំ២០១៨ នឹងអាចបន្តសម្រេចបានប្រមាណ ៦,៩% ដូចឆ្នាំ២០១៧ ដែលធ្វើឱ្យទំហំសេដ្ឋកិច្ចជាតិ (ផ.ស.ស ថ្លៃបច្ចុប្បន្ន) កើនឡើងដល់ជាង ៩៩,១ ទ្រីលានរៀល សមមូលនឹងប្រមាណជាង ២៤,៥ ប៊ីលានដុល្លារអាមេរិក ខណៈដែល ផ.ស.ស សម្រាប់មនុស្សម្នាក់ ត្រូវបានរំពឹងថានឹងកើនឡើងដល់ ១៥៦៨ ដុល្លារអាមេរិក។*

*ចំណូលក្នុងប្រទេសថវិការដ្ឋ ឬចំណូលក្នុងប្រទេសថវិកាជាតិ ត្រូវបានគ្រោងប្រមាណ ៤៦០៤ លានដុល្លារអាមេរិក ត្រូវជា ១៨,៧៥% នៃផ.ស.ស និងមានកំណើន ១១,៩% ធៀបនឹងច្បាប់ឆ្នាំ២០១៧ ។ ក្របខ័ណ្ឌថវិកាឆ្នាំ២០១៨ មានគោលដៅបង្កើនចំណូលចរន្តថវិការដ្ឋឱ្យបានស្មើនឹង ១៨,៥៧% នៃផ.ស.ស ដែលមានកំណើនចំនួន ០,១៧ ពិន្ទុភាគរយ នៃផ.ស.ស ធៀបនឹងច្បាប់ឆ្នាំ២០១៧ ។*

ចំណាយសរុបថវិការដ្ឋ ឬចំណាយសរុបថវិកាជាតិ ត្រូវបានគ្រោងប្រមាណ ៦ ប៊ីលានដុល្លារអាមេរិក ត្រូវជា ២៤,៥៩% នៃផ.ស.ស និងមានកំណើន ១៥,២% ធៀបនឹងច្បាប់ឆ្នាំ ២០១៧ ក្នុងនោះ ចំណាយចរន្តថវិការដ្ឋ ត្រូវបានគ្រោងប្រមាណ ៣,៩ ប៊ីលានដុល្លារអាមេរិក ត្រូវជា ១៦,០៩% នៃផ.ស.ស និងមានកំណើន ១៥,៦% ធៀបនឹងច្បាប់ឆ្នាំ២០១៧ ។

អំពីគម្រោងចំណូលថវិកាថ្នាក់ជាតិ: ថវិកាឆ្នាំ២០១៨ មានគោលដៅបង្កើនចំណូលក្នុងប្រទេសថ្នាក់ជាតិ ឲ្យមានទំហំស្មើនឹង ១៧,៦ ទ្រីលានរៀល សមមូលនឹងប្រមាណជាង ៤,៣ ប៊ីលានដុល្លារអាមេរិក ត្រូវជា ១៧,៨០% នៃផ.ស.ស គឺមានកំណើន ១២,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៧ ។

អំពីគម្រោងចំណាយចរន្តថវិកាថ្នាក់ជាតិ: ថវិកាឆ្នាំ២០១៨ មានទិសដៅជាយុទ្ធសាស្ត្រកំណត់ចំណាយចរន្តឲ្យស្ថិតក្នុងកម្រិតប្រមាណជាង ៣,៧ ប៊ីលានដុល្លារអាមេរិក ត្រូវជា ១៥,៣៥% នៃផ.ស.ស គឺមានកំណើន ១៦,៦% ធៀបនឹងច្បាប់ឆ្នាំ២០១៧ ដែលក្នុងនោះ៖

ក-ចំណាយលើបន្ទុកបុគ្គលិក មានកំណើន ១៦,៣% ធៀបនឹងច្បាប់ឆ្នាំ២០១៧ ត្រូវជាប្រមាណ ៨% នៃផ.ស.ស និងមានសមាមាត្រស្មើនឹង ៥២,០% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ក្នុងនោះបានគ្រោងសម្រាប់ (១)-ការតម្លើងបៀវត្សមូលដ្ឋានក្នុងអត្រា ១២,០% ដោយតម្លើងបៀវត្សមូលដ្ឋានតាមតម្លៃឯកតាសន្ទស្សន៍ ២១៣០រៀល គិតចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៨ និង (២)-ការតម្លើងប្រាក់បំណាច់មុខងារនឹងត្រូវអនុវត្តចាប់ពីខែមេសា ដល់ខែធ្នូ ឆ្នាំ២០១៨ ។

ខ-ចំណាយក្រៅបន្ទុកបុគ្គលិក មានកំណើន ១៦,៩% ធៀបនឹងច្បាប់ឆ្នាំ២០១៧ ត្រូវជា ៧,៣៧% នៃផ.ស.ស និងមានសមាមាត្រស្មើនឹង ៤៨,០% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ។

អំពីគម្រោងចំណូល-ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់) ឆ្នាំ២០១៨ មានឱនភាពថវិកាចំនួនប្រមាណ ១៨៣ លានដុល្លារអាមេរិក ហើយដែលត្រូវបានគ្រោងឧបត្ថម្ភដោយថវិកាថ្នាក់ជាតិ ដែលការឧបត្ថម្ភនេះ មានកំណើន ១៥,៦% ធៀបនឹងច្បាប់ឆ្នាំ២០១៧ ត្រូវជា ០,៧៤% នៃផ.ស.ស ។ ជារួម ពីឆ្នាំ២០១៣ ដល់ឆ្នាំ ២០១៨ ចំណាយសរុបនៃរដ្ឋបាលថ្នាក់ក្រោមជាតិ បានកើនឡើងជាងពីរដងកន្លះ ពីប្រមាណ ១៦០ លានដុល្លារអាមេរិក ដល់ប្រមាណ ៤១៧ លានដុល្លារអាមេរិក ។

នៅក្នុងក្របខ័ណ្ឌថវិការដ្ឋ ឬថវិកាជាតិខាងលើនេះ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលអាចរក្សាអតិរេកថវិកាចរន្តឲ្យបានក្នុងកម្រិតប្រមាណ ២,៤៥% នៃផ.ស.ស នៅឆ្នាំ ២០១៨ ធៀបនឹងច្បាប់ឆ្នាំ២០១៧ ដែលមាន ២,៩៨% នៃផ.ស.ស ។ ជាលទ្ធផល ឱនភាពថវិកាជាតិសរុប នឹងមានទំហំស្មើ -៥,៨៤% នៃផ.ស.ស គឺកើនឡើងពីកម្រិតនៃឱនភាពដែលបានគ្រោងក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ ស្មើនឹង -៥,០៧% នៃផ.ស.ស ។ ឱនភាពនេះ ត្រូវបានបំពេញបន្ថែមដោយហិរញ្ញប្បទានក្រៅប្រទេសក្នុងទំហំ ៤,៥៩% នៃផ.ស.ស និងមូលនិធិទ្រទ្រង់ថវិកាប្រមាណជា ០,២៥% នៃផ.ស.ស និងប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាលប្រមាណ ១,០០% នៃផ.ស.ស។

ចំពោះការអនុម័តយល់ព្រមឲ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេក្នុងកម្រិត ១ប៊ីលានអេសដេអឺរ (SDR) សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ គឺស្របទៅតាមយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨ ។

៣- **<u>សេចក្តីសន្និដ្ឋាន</u>**

*ក្រោយពីបានពិនិត្យសិក្សាលើទម្រង់ និងខ្លឹមសារនៃសេចក្តីព្រាងច្បាប់ ដោយឆ្លងតាមរយៈនៃការផ្តល់យោបល់ ដែលទទួលបានពីសមាជិក សមាជិកាព្រឹទ្ធសភា និងការពិនិត្យសិក្សាយ៉ាងល្អិតល្អន់ និងការឆ្លើយបំភ្លឺពីតំណាងរាជរដ្ឋាភិបាល*

*គណៈកម្មការយល់ឃើញថា សេចក្តីព្រាងច្បាប់ស្តីពី* ***ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨*** *នេះ បានបង្ហាញឲ្យឃើញពីភាពជោគជ័យ និងលទ្ធផលការងារដែលរាជរដ្ឋាភិបាលសម្រេចបាន ព្រមទាំងវិធានការសំខាន់ៗនៅក្នុងឆ្នាំចុងក្រោយរបស់រាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា ដែលបានអនុវត្តយ៉ាងសស្រាក់សស្រាំតាំងពីដើមនីតិកាលមក ហើយក៏កំពុងបន្តតម្រង់ តម្រឹម និងពន្លឿនការអនុវត្តបញ្ចប់នូវកម្មវិធី និងអាទិភាពគោលនយោបាយសំខាន់ៗស្របតាមបំណងប្រាថ្នារបស់ប្រជាជនកម្ពុជា ព្រមទាំងគិតគូរផងដែរទៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ និងជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ និងការត្រៀមខ្លួនទប់ទល់នឹងវិបត្តិដែលអាចកើតមានឡើងជាយថាហេតុ ក៏ដូចជា ផ្តល់ការឆ្លើយតបទៅនឹងបរិការណ៍ថ្មីរបស់កម្ពុជា ទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងប្រទេស តំបន់ និង ពិភពលោក ជាពិសេសដើម្បីសម្រេចឲ្យបានជាអតិបរមានូវ* ***គោលដៅជាយុទ្ធសាស្ត្រទាំង៤ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បី កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាពនៅកម្ពុជា ។***

*គណៈកម្មការយល់ឃើញថា ថវិកាឆ្នាំ២០១៨ អាចប្រសិទ្ធនាមបានថា ជាថវិកាយុទ្ធសាស្ត្រនៃការពូនផ្តុំកម្លាំង និងធនធានជាអតិបរមា និងសម្រួចវិធានការគោលនយោបាយ ដើម្បីសម្រេចឲ្យខានតែបាននូវគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នៅក្នុងសភាពស្មុគស្មាញនៃបរិការណ៍តំបន់ និងពិភពលោក ដើម្បីបន្តរក្សាសន្តិភាព ស្ថិរភាព ក៏ដូចជាការទ្រទ្រង់ នូវដំណើរការរីកវឌ្ឍន៍ឈានឡើងរបស់កម្ពុជាលើវិថី នៃការអភិវឌ្ឍប្រកបដោយគុណភាព និងចីរភាព តទៅមុខឥតឈប់ឈរ ក្នុងនីតិកាលបន្តបន្ទាប់ទៀត ។*

*តាមអត្ថន័យ និងខ្លឹមសារដូចបានជម្រាបជូនខាងលើ គណៈកម្មការទី២ យល់ឃើញថា សេចក្តីព្រាងច្បាប់ស្តីពី* ***ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨*** *មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ហើយបានអនុម័តយល់ព្រមជាឯកច្ឆន្ទ ដោយស្នើសុំ* ***គណៈកម្មាធិការអចិន្ត្រៃយ៍ / អង្គប្រជុំព្រឹទ្ធសភា*** *ដើម្បីពិនិត្យ និងអនុម័ត ដោយចាត់ទុកជាការប្រញាប់តាមការគួរ ។/.*

***សូមអរគុណ !***

*រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៧*

**ប្រធានគណៈកម្មការ**

**ជា ចេដ្ឋ**

# ឧបសម្ព័ន្ធ១៣ ៖

# លិខិតអញ្ជើញប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍លើកទី២

**ព្រឹទ្ធសភា**

លេខ ១៣៨/១១១៧ ពស/ន.រ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រធានព្រឹទ្ធសភា

សូមអញ្ជើញ ឯកឧត្តមអនុប្រធានទី១ ឯកឧត្តមអនុប្រធានទី២ ព្រឹទ្ធសភា ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកាគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា មកចូលរួមប្រជុំ នៅថ្ងៃសុក្រ ទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង ៨:០០ នាទីព្រឹក នៅសាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។

សូមជូនភ្ជាប់ជាមួយនូវរបៀបវារៈប្រជុំ ។

រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

*សំណៀកបំពាក់ : ធំ*


វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

# របៀបវារៈ
# ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

(ថ្ងៃសុក្រ ទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ម៉ោង ៨:០០ នាទីព្រឹក)

---

១- ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី២ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៨ ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី១១ ព្រឹទ្ធសភា នីតិកាលទី៣ ។

២- ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី២ ព្រឹទ្ធសភា សុំដាក់ទៅក្នុងរបៀបវារៈនៃសម័យប្រជុំលើកទី១១ ព្រឹទ្ធសភានីតិកាល ទី៣ នូវសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើ៖

១. កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

២. កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

៣.កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះចៅស៊ុលតង់ និងយ៉ាងឌីពើរតួន នៃប្រទេសប្រ៊ុយណេដារូសាឡឹម ស្តីពីការចៀសវាងការយក

ពន្ធត្រួតគ្នា និងការបង្ការការគេចវេសបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

៤. កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល ។

៣- ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី២ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី១១ ព្រឹទ្ធសភានីតិកាលទី៣ ។

៤- ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៣ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើធម្មនុញ្ញនៃមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី១១ ព្រឹទ្ធសភានីតិកាលទី៣ ។

៥- កំណត់របៀបវារៈ និងកាលបរិច្ឆេទ បន្តសម័យប្រជុំលើកទី១១ ព្រឹទ្ធសភានីតិកាលទី៣ ។

៦- ពិនិត្យ និងសម្រេចអំពីកាតព្វកិច្ចពាក់ព័ន្ធនឹងព្រឹទ្ធសភាក្នុងការអនុវត្តសាលដីកាលេខៈ ៣៤០ (ឧ) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់តុលាការកំពូល ។

# ឧបសម្ព័ន្ធ១៤ ៖

# សេចក្តីប្រកាសព័ត៌មានអំពីលទ្ធផល
# នៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍លើកទី២

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**
**លេខ ........../២០១៨/អគល/ពស**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា៖ នាថ្ងៃចន្ទ ទី២២ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ៨:០០នាទីព្រឹក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានបើកកិច្ចប្រជុំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា។

បន្ទាប់ពីបានពិនិត្យ និងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានកំណត់យកថ្ងៃពុធ ទី២៤ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង៨:០០នាទីព្រឹក ដើម្បីបើកសម័យប្រជុំលើកទី២ ព្រឹទ្ធសភា នីតិកាលទី៤ ដោយមានរបៀបវារៈតែមួយគឺ ស្តាប់របាយការណ៍គណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី១ និងលើកទី២ នីតិកាលទី៤។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ១៣ កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨
**អគ្គលេខាធិការ**

អ៊ុំ សារិទ្ធ

វិមានរដ្ឋសភា មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446 E-mail: oum_sarith@camnet.com.kh

# ឧបសម្ព័ន្ធ១៥ ៖

# លិខិតអញ្ជើញប្រជុំពេញអង្គព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា

លេខ ១.៦៤.៦.២០១៧ ពស/សន

# ប្រធានព្រឹទ្ធសភា

សូមអញ្ជើញ ឯកឧត្តមអនុប្រធានទី១ ឯកឧត្តមអនុប្រធានទី២ ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកាព្រឹទ្ធសភាទាំងអស់ មកចូលរួមប្រជុំ ក្នុងសម័យប្រជុំលើកទី១១ ព្រឹទ្ធសភានីតិកាលទី៣ នៅថ្ងៃចន្ទ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង ០៨:០០ នាទីព្រឹក នៅវិមានព្រឹទ្ធសភា ។

សូមជូនភ្ជាប់ជាមួយនូវរបៀបវារៈប្រជុំ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០១៧

ហ.ត.

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

សំណៀកបំពាក់ : ធំ

# របៀបវារៈ
# សម័យប្រជុំលើកទី១១ ព្រឹទ្ធសភានីតិកាលទី៣

(ថ្ងៃចន្ទ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ម៉ោង ៨:០០ នាទីព្រឹក)

---

១- ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ។

២- ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើៈ

១. កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបគេងបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

២. កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបគេងបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

៣.កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះចៅស៊ុលតង់ និងយ៉ាងឌីពើរតួននៃប្រទេសប្រ៊ុយណេដារូសាឡឹម ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបគេងបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

៤. កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

៣- ពិនិត្យ និងឲ្យយោបល់លើសេចក្ដីព្រាងច្បាប់ ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ។

៤- ពិនិត្យ និងឲ្យយោបល់លើសេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើធម្មនុញ្ញនៃមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី ។

## ឧបសម្ព័ន្ធ១៦ ៖

## លិខិតអញ្ជើញតំណាងរាជរដ្ឋាភិបាល
## មកបំភ្លឺលើសេចក្តីព្រាងច្បាប់

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ព្រឹទ្ធសភា**

លេខ ៦៤០.០.០១១៧ពស/ស.រ

# សូមគោរពជម្រាបជូន
# ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីស្តីទី ទីស្តីការគណៈរដ្ឋមន្ត្រី

**កម្មវត្ថុ** : អំពីការចាត់អញ្ជើញតំណាងរាជរដ្ឋាភិបាល មកបំភ្លឺលើសេចក្តីព្រាងច្បាប់ ស្តីពីៈ

១- ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ។

២- ការអនុម័តយល់ព្រមលើៈ

១. កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី ស្តីពីការជៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

២. កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការជៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

៣. កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះចៅស៊ុលតង់ និងយ៉ាងឌីពើរតួន នៃប្រទេសប្រ៊ុយណេដារូសាឡឹម ស្តីពីការជៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

៤. កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការជៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល ។

៣- ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ។

៤- ការអនុម័តយល់ព្រមលើធម្មនុញ្ញនៃមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី

**យោង** : - មាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ

- លិខិតរបស់រដ្ឋសភាលេខ : ៦១៩ រស, ៦២០ រស, ៦២១ រស និងលេខ : ៦២២ រស ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ជ្រាបថា ព្រឹទ្ធសភានឹងបន្តសម័យប្រជុំលើកទី១១ នីតិកាលទី៣ នៅថ្ងៃចន្ទ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង ៨:០០ នាទីព្រឹក នៅវិមានព្រឹទ្ធសភា ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ដូចមានចែងក្នុងកម្មវត្ថុខាងលើ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាប និងចាត់តំណាងរាជរដ្ឋាភិបាលមកបំភ្លឺ តាមកាលបរិច្ឆេទខាងលើ តាមការគួរ ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែវិច្ឆិកា ឆ្នាំ២០១៧

ជ. ប្រធានព្រឹទ្ធសភា

អនុប្រធានទី២

**ទេព ងន**

<u>ចម្លងជូន</u> :

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

-គណៈកម្មការទី២ និងទី៣ នៃព្រឹទ្ធសភា

(ដើម្បីជូនជ្រាប)

-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ១៧ ៖

# ពាក្យស្នើសុំមានមតិយោបល់ក្នុងអង្គប្រជុំព្រឹទ្ធសភា

**ព្រឹទ្ធសភា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## សម័យប្រជុំលើកទី..... ព្រឹទ្ធសភានីតិកាលទី....

## ពាក្យស្នើសុំមានមតិយោបល់ពិភាក្សា

**ខ្ញុំបាទ/នាងខ្ញុំ :** ............................................សមាជិកព្រឹទ្ធសភា ក្រុមទី............

**តាមរយៈ:** : ប្រធានក្រុមទី ................

**សូមគោរពជូន**
**ប្រធានអង្គប្រជុំ**

ខ្ញុំបាទ/នាងខ្ញុំ សូមអនុញ្ញាតមានមតិយោបល់លើ:

១- ..........................................................................................................

..........................................................................................................

២- ..........................................................................................................

..........................................................................................................

៣- ..........................................................................................................

..........................................................................................................

សូម **ប្រធានអង្គប្រជុំ**មេត្តាអនុញ្ញាត តាមការគួរ ។

ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ...........

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ...........

**ឯកភាព** **ហត្ថលេខា**

**ប្រធានក្រុមទី** ........

# ឧបសម្ព័ន្ធ១៨ ៖

# សេចក្តីប្រកាសព័ត៌មាន
# អំពីលទ្ធផលនៃកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**
លេខ ១១១៩/២០១៨/អលពស

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃសម័យប្រជុំលើកទី២ ព្រឹទ្ធសភា នីតិកាលទី៤
# នាថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា៖ នាថ្ងៃពុធ ទី២៤ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ៨:០០នាទីព្រឹក ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបើកសម័យប្រជុំលើកទី២ ព្រឹទ្ធសភានីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សាយ ឈុំ** ប្រធានស្តីទីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា។

សមាជិកព្រឹទ្ធសភាមានវត្តមានចំនួន ៥៣រូប។

សម័យប្រជុំលើកទី២នេះ បានដំណើរការដោយមានរបៀបវារៈតែមួយគឺ ស្តាប់របាយការណ៍គណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី១ និងលើកទី២ នីតិកាលទី៤។

ក្នុងអំឡុងពេលចន្លោះសម័យប្រជុំព្រឹទ្ធសភារយៈពេលបីខែនេះ ថ្នាក់ដឹកនាំ គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការនានា ក្រុមសមាជិកាព្រឹទ្ធសភា ក្រុមភូមិភាគ និងក្រុមនានា ព្រមទាំងសមាជិក សមាជិកាព្រឹទ្ធសភា នីតិកាលទី៤ បានរួមគ្នាខិតខំបំពេញការកិច្ចរៀងៗខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបានលទ្ធផលផ្លែផ្កា ជាគុណប្រយោជន៍ដល់ជាតិ និងប្រជាពលរដ្ឋ។

ព្រឹទ្ធសភាបានប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន២លើក ដើម្បីរៀបចំរបៀបវារៈ និងកំណត់កាលបរិច្ឆេទប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ និងបើកសម័យប្រជុំលើកទី២ ព្រឹទ្ធសភានីតិកាលទី៤។

ព្រឹទ្ធសភាបានប្រជុំវិសាមញ្ញចំនួន១លើក ដើម្បីប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី នីតិកាលទី៤ និងបោះឆ្នោតជ្រើសរើសអនុប្រធានទី១ ព្រឹទ្ធសភា នីតិកាលទី៤។

ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន ១៣ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446 E-mail: [illegible]

ស្ថាប័នមានសមត្ថកិច្ចដើម្បីដោះស្រាយចំនួន ៥ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្ដឹងចំនួន ២ករណី ធ្វើកំណត់បង្ហាញពាក្យបណ្ដឹងចំនួន ២ករណី ទទួលឯកសារជូនជ្រាបពីក្រសួងស្ថាប័នពាក់ព័ន្ធចម្លងជូនព្រឹទ្ធសភាចំនួន ១៩ករណី ឆ្លើយតបទៅម្ចាស់បណ្ដឹងអំពីចំណាត់ការរបស់គណៈកម្មការចំនួន ២ករណី ព្រមទាំងធ្វើលិខិតរំលឹកជំរុញការដោះស្រាយពាក្យបណ្ដឹងបានចំនួន ២ករណី។

ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគនានា បានអញ្ជើញចុះឈ្វេងយល់អំពីវឌ្ឍនភាពព្រមទាំងផ្ដល់ និងស្រាវជ្រាវប្រមូលព័ត៌មានអំពី បញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន ១០លើក នៅខេត្តព្រៃវែង តាកែវ កំពត កែប ត្បូងឃ្មុំ កំពង់ធំ ប៉ៃលិន ឧត្តរមានជ័យ សៀមរាប និងរាជធានីភ្នំពេញ។ ក្រៅពីនេះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគបានចុះជួបសំណេះសំណាល សួរសុខទុក្ខ និងចែកអំណោយជូនប្រជាពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់នៅតាមបណ្ដារាជធានី ខេត្ត និងសម្ពោធអណ្ដូងទឹកស្អាតចំនួន២កន្លែង នៅខណ្ឌពោធិ៍សែនជ័យ និងខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ក្រុមសមាជិកាព្រឹទ្ធសភា បានរៀបចំកិច្ចពិគ្រោះយោបល់ស្ដីពី ពង្រឹងភាពជាតំណាងរបស់សមាជិកាព្រឹទ្ធសភា និងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ (ភូមិភាគទី៣ ខេត្តកណ្ដាល)។

នៅក្នុងការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចូលរួមមហាសន្និបាត កិច្ចប្រជុំអន្តរជាតិ វេទិកា និងទស្សនកិច្ចផ្លូវការនានាចំនួន ១១លើក។

នៅចន្លោះសម័យប្រជុំលើកទី១ និងលើកទី២ គណៈកម្មការនានារបស់ព្រឹទ្ធសភា បានយកចិត្តទុកដាក់ខ្ពស់ តាមដានការអនុវត្តរដ្ឋធម្មនុញ្ញ ច្បាប់ និងគោលនយោបាយនានា ដែលរាជរដ្ឋាភិបាល បាននិងកំពុងដាក់ឱ្យអនុវត្ត ដើម្បីលើកកម្ពស់ជីវភាពរស់នៅលើគ្រប់វិស័យរបស់ប្រជាជននៅទូទាំងប្រទេស។

ព្រឹទ្ធសភា សូមវាយតម្លៃខ្ពស់ចំពោះលទ្ធផល និងសមិទ្ធផលដ៏ធំធេងលើគ្រប់វិស័យ ដែលរាជរដ្ឋាភិបាលខិតខំសម្រេចបានដោយសកម្ម ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីបន្តអភិវឌ្ឍន៍ប្រទេសជាតិ ក្នុងប្រសិទ្ធភាព និងគុណភាពមួយថ្មី ដែលឈរលើកំណែទម្រង់លើគ្រប់វិស័យជាពិសេស ការតម្រង់ទិសអនុវត្តគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលអាណត្តិថ្មី នីតិកាលទី៦ នៃរដ្ឋសភា។

ព្រឹទ្ធសភា សូមសម្ដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះការគាំទ្រដ៏ថ្លៃថ្លាពីគ្រប់

មជ្ឈដ្ឋាន និងគ្រប់ស្ថាប័ន ជាពិសេសការចូលរួមកោតទានដ៏ថ្លៃថ្លាពីប្រទេសជាមិត្ត និងដៃគូនានា ដែលញ៉ាំងឱ្យព្រឹត្តិការណ៍ដំណើរការទៅមុខដោយរលូន និងល្អប្រពៃ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន៕

ថ្ងៃពុធ ១៥កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨

អគ្គលេខាធិការស្តីទី

ឡេង_ឆាយ

## ឧបសម្ព័ន្ធ១៩ ៖

## លិខិតជូនដំណឹងទៅប្រធានរដ្ឋសភា
## អំពីការពិនិត្យ និងឱ្យយោបល់លើសេចក្ដីព្រាងច្បាប់

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ព្រឹទ្ធសភា**

លេខ ១.១៤៣/២២.១១/១៧ ពស/ន.វ

**សូមគោរពជម្រាបជូន**
**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា**

**កម្មវត្ថុ** : *អំពីការពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨*

**យោង** : *- មាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ*
*- លិខិតរបស់រដ្ឋសភាលេខ : ៤១៩ រស ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧*

*តបតាមសេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន* **សម្តេចប្រធានរដ្ឋសភា** *មេត្តាជ្រាបថា ព្រឹទ្ធសភាបានទទួលសេចក្តីព្រាងច្បាប់ខាងលើពីរដ្ឋសភាកាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ កន្លងមកនេះ ហើយព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ និងចាត់ទុកជាការប្រញាប់ ក្នុងសម័យប្រជុំលើកទី១១ ព្រឹទ្ធសភានីតិកាលទី៣ នាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ដោយមានសំឡេងគាំទ្រ ចំនួន៤៥ សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។*

*សេចក្តីដូចបានជម្រាបជូនខាងលើ សូម* **សម្តេចប្រធានរដ្ឋសភា** *មេត្តាជ្រាប និងចាត់ចែងនីតិវិធីបន្ត តាមការគួរ ។*

*សូម* **សម្តេចប្រធានរដ្ឋសភា** *មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុត ។*

*រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧*

**ជ. ប្រធានព្រឹទ្ធសភា**
**អនុប្រធានទី២**

**ទេព ងន**

**<u>ចម្លងជូន</u>**
*-ក្រសួងព្រះបរមរាជវាំង*
*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*(ដើម្បីជូនជ្រាប)*
*-ឯកសារ-កាលប្បវត្តិ*

បោះពុម្ពដោយ

**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

**ខែមេសា ឆ្នាំ ២០២១**